# អ្នកនាំសារ
THE MESSENGER

ឆ្នាំគ្រួសារ ២០១៧-២០២០

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

សម្រាប់ខែ មករា ឆ្នាំ ២០២០ | តម្លៃលក់ ១០០០រៀល

លេខ #១២៤


■ អំពើជួញដូរមនុស្ស នៅតែក្ដៅសម្រាប់កម្ពុជា ទំព័រ-៨



■ កុមារប្រមាណ ៣០០០នាក់ ទទួលអំណរសប្បាយ បុណ្យកំណើតព្រះយេស៊ូ ទំព័រ-២៥





## ការព្រួយបារម្ភរឿង បាត់ប្រព័ន្ធអនុគ្រោះពន្ធ ពីអឺរ៉ុបនៅតែមាន ប៉ុន្តែពលរដ្ឋខ្លះ ហាក់មានជំនឿចិត្តលើអាជ្ញាធរ

ទំព័រ ១៤-១៥



## ក្រុមយុវជនស្ម័គ្រចិត្តមួយក្រុម ចូលរួមថត សត្វស្លាបកម្រ



ទំព័រ-១០

## វិចារណកថា

# អរគុណសន្តិភាព ២០២០

*ដោយៈ លី សុវណ្ណា*



អរគុណសន្តិភាព នេះជាប្រធានបទដ៏សំខាន់មួយ សម្រាប់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។ ប្រទេសកម្ពុជាបានទទួលសន្តិភាពពិតប្រាកដ ក្នុងពេលចប់ចំបាំងប្រយុទ្ធគ្នា រវាងកងកម្លាំងប្រដាប់អាវុធគ្រប់ភាគី ប្រមាណជាង២០ឆ្នាំចុងក្រោយនេះប៉ុណ្ណោះ។ សក្ខីកម្មដែលយើងខ្ញុំបានឆ្លងកាត់ផ្ទាល់ គឺបើទោះបីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ក៏ប្រទេសកម្ពុជានៅតែមានការប្រយុទ្ធគ្នា ។ ក្រោយបោះឆ្នោតក្នុងឆ្នាំ១៩៩៣ ក៏នៅតែបន្តប្រយុទ្ធគ្នា ព្រោះខ្មែរក្រហមមិនទាន់រំលាយអង្គការចាត់តាំងរបស់ខ្លួន បក្សនីមួយៗដែលជាភាគីហត្ថលេខី ក៏មានកងទ័ពផ្ទាល់ខ្លួន មិនទាន់មានបញ្ចូលជាកងព័ទជាតិតែមួយនោះទេ។

ការរៀបរាប់ខាងលើជាសក្ខីកម្មដែលយើងខ្ញុំឆ្លងកាត់ផ្ទាល់ ផ្ដាប់រត់គេចព្រោះតែការបាញ់ផ្ដោងដាក់គ្នា និងគេចចេញពីសមរភូមិប្រយុទ្ធ។ ចុងក្រោយក្នុងឆ្នាំ១៩៩៨ មកដល់ពេលនេះគឺទទួលបានសន្តិភាពពេញលេញ ហើយជាពិសេសបំផុតក្នុងដំណាក់កាលចុងក្រោយនេះ គឺប្រទេសកម្ពុជាបានរីកចម្រើនយ៉ាងខ្លាំងតែម្ដង មានមុខមាត់ក្នុងចំណោមប្រទេសនានាលើឆាកអន្តរជាតិ។

បងប្អូនដែលធ្លាប់បានចេញដំណើរទៅក្រៅប្រទេស គឺប្រាកដជាបានដឹងហើយ កុំថាឡើយត្រឹមប្រទេសថៃ គឺត្រូវសុំទិដ្ឋការដោយដាក់នូវឯកសារជាច្រើន ទៅប្រទេសខាងអឺរ៉ុបក៏ដូចគ្នា។

សរុបទៅគឺពិបាកខ្លាំងណាស់ ព្រោះតែគេថាយើងក្រ គ្មានលទ្ធភាពយកលុយទៅចាយនៅប្រទេសគេទេ មានតែចង់ទៅរស់នៅ ធ្វើជាបន្ទុកសម្រាប់រដ្ឋរបស់គេប៉ុណ្ណោះ។

ប៉ុន្តែពេលនេះវិញ ក្នុងមួយឆ្នាំៗ ប្រជាជនកម្ពុជាបានចេញទៅដំណើរកំសាន្តទេសចរនៅក្រៅប្រទេសមិនតិចទ ហើយក៏បានចំណាយប្រាក់លើការព្យាបាលនៅក្រៅប្រទេសរាប់ម៉ឺនដុល្លារទៀតផង។

ភាពរីកចម្រើននានា ប្រជាជននៅភ្នំពេញខ្លួនឯងបានដឹង និងបានឃើញផ្ទាល់ភ្នែកហើយ។ នេះជាតថភាពដែលយើងត្រូវទទួលស្គាល់ការពិត។ យើងត្រូវរួមគ្នាដើម្បីការពារសន្តិភាពនេះឲ្យបាន ដែលវីរៈជនជាតិយើងបានកសាងទុកមកដោយលំបាកបំផុត។

យើងក៏បានមើលឃើញដែរថា នៅមានសង្គ្រាមថ្មីដែលយើងត្រូវប្រយុទ្ធរួមជាមួយគ្នា ទាំងរាជរដ្ឋាភិបាល និងរាស្ត្រ ត្រូវរួមគ្នាយ៉ាងសកម្មបំផុត។

អ្វីដែលត្រូវធ្វើគឺ ការពារសេចក្ដីថ្លៃថ្នូររបស់មនុស្ស អយុត្តិធម៌សង្គម ការរើសអើងគ្រឿងញៀន អំពើពុករលួយ ការប្រើអំណាចសង្កត់សង្កិនអ្នកក្រីក្រតូចតាចទន់ខ្សោយ។ ការរើសអើងពូជសាសន៍ សាសនា និងការលាបពណ៌ដាក់គ្នាទៅវិញទៅមក។

កិច្ចការអ្វីៗទាំងប៉ុន្មានខាងលើនេះគឺគ្រប់គ្នាត្រូវចូលរួម ដើម្បីផលប្រយោជន៍រួម។ សម័យឌីជីថល ប្រមុខរដ្ឋាភិបាល ក៏បានប្រកាសដែរថា ក្នុងបច្ចុប្បន្ននេះជារដ្ឋាភិបាលឌីជីថលដែរ មិនមានអ្វីអាចត្រូវលាក់បាំងបានទេ។

គ្រប់គ្នាមានកាព្វកិច្ចតាមដានការអនុវត្តនានារបស់អ្នកមានអំណាច របស់អាជ្ញាធររបស់សមត្ថកិច្ចជាដើម ដើម្បីរាយការណ៍ទៅប្រមុខរដ្ឋាភិបាល គឺមិនអាចលាក់កំបាំងបានទេ។

ចំពោះវប្បធម៌អន្តរគមន៍ខុសច្បាប់ ក៏គ្រប់គ្នាត្រូវចូលរួមប្រឆាំងដាច់ខាតផងដែរ មិនខ្វះទេក្នុងសង្គមកម្ពុជាយើងនេះ ហេតុនេះចូលរួមទាំងអស់គ្នា គឺអ្នកដែលប្រព្រឹត្តពុករលួយ អ្នកអន្តរគមន៍ខុសច្បាប់ អ្នកផលិត និងលក់គ្រឿងញៀន អ្នកប្រើអំណាចកេងយកប្រយោជន៍ផ្ទាល់ខ្លួន យកដីរាស្ត្រ យកដីព្រៃ បំផ្លាញព្រៃឈើ បំផ្លាញបរិស្ថានជនបង្កភាពអយុត្តិធម៌ គឺជាអ្នកបំផ្លាញសន្តិភាព បំផ្លាញសេចក្ដីសុខរបស់ពលរដ្ឋ ផ្ទុយពីគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលតែងយកចិត្តទុកដាក់ចំពោះប្រជាជនជាពិសេសកម្មករជាដើម។ ត្រូវរួមគ្នាដោយកិច្ចសន្ទនាល្អ សាមគ្គីភាព និងភាតរភាព ប្រឆាំងដាច់ខាតចំពោះជនខាងលើទាំងនោះ ទោះបីអ្នកជាប្រជាជនធម្មតា ឬអ្នកមានអំណាចណាមួយក៏ដោយ។

បើគ្រប់គ្នាមិនឆ្លើយតប មានន័យថាបងប្អូនគាំទ្រនូវទង្វើអាក្រក់របស់ពួកគេ ហើយបងប្អូនក៏ចូលរួមបំផ្លាញសន្តិភាពដែរ។ ដោយសារបានបង្កឲ្យមានភាពក្ដៅក្រហាយក្នុងចំណោមប្រជាជន។ តែសូមចាំថា មិនត្រូវប្រឆាំងនិងការអភិវឌ្ឍរបស់ជាតិឡើយ។

សរុបមកវិញ គឺគ្រប់គ្នាជាចលករនៃការកសាង និងថែរក្សាសន្តិភាពដែលកំពុងកើតមានបន្តទៅទៀត ព្រោះថាទំរាំបានដូចថ្ងៃនេះ គឺពិតជាលំបាកពេកណាស់ហើយ។

ត្រូវរួមគ្នាជានិច្ច បន្តកិច្ចសន្ទនា និងត្រូវមានសេចក្ដីសង្ឃឹមព្រមទាំងកែប្រែចំណុចដែលខ្វះខាត ចំណុចអសកម្មផងដែរ។

សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូមានបន្ទូលថា សន្តិភាពគឺជាមាគ៌ានៃក្ដីសង្ឃឹមនិងជាមាគ៌ានៃការសន្ទនា ការផ្សះផ្សានិងការប្រែចិត្តគំនិត។ សម្ដេចក៏បានមានប្រសាសន៍ថា សន្តិភាពជាដំណើរនៃការស្ដាប់ដោយផ្អែកលើការចងចាំ សាមគ្គីភាព និងភាតរភាព៕

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក
ចាងហ្វាង : លោក លី សុវណ្ណា
សេចក្ដីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh






*កិច្ចប្រជុំកំពូលប្រចាំឆ្នាំអាស៊ាន-សហរដ្ឋអាមេរិក លើកទី៧ នៅទីក្រុងបាងកក ប្រទេសថៃ កាលពីថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៩ កន្លងទៅ។ រូបភាព៖ សហការី*

# អាមេរិកមិនអាចមើលស្រាលអាស៊ានបានឡើយ!

*ដោយ៖ អរិយបុត្រ*

រដ្ឋបាលរបស់លោកប្រធានាធិបតីអាមេរិក ដូណាល់ ត្រាំ ហាក់មើលស្រាលទំនាក់ទំនងរវាងអាមេរិក និង អាស៊ាន ដោយនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានកាលពីខែ វិច្ឆិកាកន្លងទៅនេះ រដ្ឋាភិបាលអាមេរិក បានបញ្ជូនត្រឹមតែមន្ត្រីពីររូប ដែលឋានៈនិងតួនាទីរបស់ពួកគេបានឆ្លុះបញ្ចាំងយ៉ាងប្រត្យក្សនៅទង្វើរបស់អាមេរិកចំពោះអាស៊ាន ។

នៅឯកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៥ ជាពិសេសនាកិច្ចប្រជុំកំពូលអាស៊ាន-អាមេរិក លើកទី៧ មេដឹកនាំអាស៊ានភាគច្រើនបានឆ្លើយតបនឹងការមើលស្រាលផ្នែកការទូតរបស់អាមេរិកមកលើតំបន់ អាស៊ាន ដែលពេលនេះប្រទេសមហាអំណាចនានាកំពុងតែសម្លឹងមកមើលយ៉ាងយកចិត្តទុកដាក់និងប្រុងប្រយ័ត្នចំពោះនយោបាយការបរទេសអាមេរិកចំពោះអាស៊ាន ។

នៅក្នុងកិច្ចប្រជុំកំពូលនោះ លោកដូណាល់ ត្រាំ បានបញ្ជូនមន្ត្រីដែលមិនមែននៅក្នុងជួរគណរដ្ឋមន្ត្រី អាមេរិក ។ ខណៈដែលលោក ដូណាល់ ត្រាំ មិនបានចូលរួម មន្ត្រីដែលតំណាងឲ្យរូបលោក គឺមិនមែន ជាអនុប្រធានាធិបតីអាមេរិក គឺ លោក ម៉ាយ ផែន ប៉ុណ្ណោះទេ ហើយក៏មិនមែនជារដ្ឋមន្ត្រីក្រសួងការ បរទេស លោក ម៉ាយ ថមផេវ ដែរ តែ ជាលោក រ៉ូបឺត អូ ប្រេន ដែលមានតួនាទីត្រឹមតែជា ទីប្រឹក្សាផ្នែក សន្តិសុខជាតិអាមេរិក តែប៉ុណ្ណោះ ។ នេះគឺជាការមើលស្រាលមួយរបស់រដ្ឋបាលរបស់លោកដូណាល់ត្រាំចំពោះអាស៊ានខណៈដែលកាលពីឆ្នាំទៅ គឺនៅពេលដែលប្រទេសសិង្ហបុរីធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំកំពូលអាស៊ាន លោក ដូណាល់ ត្រាំ ក៏មិនបានមកដែរ តែលោកបានឲ្យអនុប្រធានាធិបតីរបស់លោក មកចូលរួម ។

ជាការឆ្លើយតបនិងការទម្លាក់ទំនាក់ទំនងការទូតរបស់រដ្ឋបាលលោកត្រាំចំពោះអាស៊ាន បណ្ដាមេដឹកនាំ អាស៊ានភាគច្រើន គឺបានបញ្ជូនត្រឹមតែតំណាងរបស់ខ្លួនប៉ុណ្ណោះចូលរួមកិច្ចប្រជុំកំពូលអាស៊ាន-អាមេរិក លើកទី ៧នោះដែរ ដោយរួមទាំងមេដឹកនាំកម្ពុជាផងដែរ ។ មេដឹកនាំអាស៊ានដែលមានមុខនៅក្នុង កិច្ចប្រជុំកំពូលនោះ គឺមានតែនាយករដ្ឋមន្ត្រីថៃ ដែលជាប្រធានអាស៊ាន នាយករដ្ឋមន្ត្រី ឡាវ និង វៀតណាម តែប៉ុណ្ណោះ ខណៈដែលអាស៊ានភាគច្រើនគឺបញ្ជូនត្រឹម រដ្ឋមន្ត្រីការបរទេសចូលរួមជំនួស ។

កន្លងមកនៅក្នុងនយោបាយការបរទេសរបស់អាមេរិក ជាពិសេសគឺនៅក្រោមរដ្ឋបាលរបស់ លោក ដូណាល់ ត្រាំ អាស៊ានហាក់ដូចជាមិននៅក្នុងគោលនយោបាយចំបង និងអតិភាពរបស់លោកឡើយ ។ នយោបាយការបរទេសរបស់រដ្ឋបាលលោកដូណាល់ត្រាំ ប្រហែលជា ដាក់បន្ទុកខ្លាំងទៅលើសង្គ្រាមពាណិជ្ជកម្មជាមួយនឹងចិន បញ្ហានៅមជ្ឈឹមបូពារ បញ្ហានយោបាយអាមេរិកកាំងលេខ១ បញ្ហានៅ អាមេរិកខាងត្បូង ដូចជានៅប្រទេសវេណេហ្ស៊ុយអេឡា បញ្ហានៅអាហ្គានីស្ថាន... ប៉ុន្តែអាស៊ានហាក់នៅក្នុង គោលនយោបាយបន្ទាប់បន្សំមួយរបស់រដ្ឋបាលនៃប្រទេសនេះ ។

ការមើលស្រាលរបស់រដ្ឋបាលលោក ដូណាល់ ត្រាំ ចំពោះអាស៊ាន គឺជារឿងខុសឆ្គងមួយ ដោយសារតែ ពេលនេះ អាស៊ានគឺជាប្លុកតំបន់មួយ ដែលមានសក្ដានុពលផ្នែកពាណិជ្ជកម្ម នយោបាយ និងការទូត មួយ ដែលមានទំហំ និង សក្ដានុពលមិនអន់ជាង សហភាពអឺរ៉ុប ប៉ុន្មានឡើយ ។ ពីមុនមក អាស៊ាន មិនមាននៅក្នុងបញ្ជីនយោបាយអតិភាពរបស់រុស្ស៊ីនោះទេ ប៉ុន្តែរុស្ស៊ី បានហាក់មកហើយ ក្រោយពីសហភាពអឺរ៉ុបនិងប្រទេសមហាអំណាចនៅបច្ចឹមប្រទេសជាច្រើនបានមកចាប់ដៃគូជាមួយនឹងអាស៊ាន ។

ការមើលស្រាលទំនាក់ទំនងជាមួយអាស៊ាន គឺជារឿងដ៏គួរឲ្យសោកស្ដាយមួយរបស់រដ្ឋបាលលោក ប្រធានាធិបតីអាមេរិក ដូណាល់ ត្រាំ ខណៈដែលមកដល់ពេលនេះ បណ្ដាប្រទេសមួយចំនួន នៅក្នុង អាស៊ានក៏អាចនិយាយបានថា ជាសម្ព័ន្ធមិត្តមួយ របស់អាមេរិកនៅក្នុងការប្រឆាំងនឹងឥទ្ធិពលរបស់ចិន ផងដែរ ។

នៅពេលបច្ចុប្បន្ននេះ បណ្ដាប្រទេសនៅអាស៊ានសឹងតែពាក់កណ្ដាលគឺមានទំនាស់រឿងទឹកដី នៅដែនកោះនៅសមុទ្រចិនខាងត្បូង ប៉ុន្តែសូមកុំភ្លេចថា ទោះបីជាយ៉ាងណាក៏ដោយ ក៏ពួកគេហាក់ដូចជា មាន គំនិតវិជ្ជមានចំពោះគោលនយោបាយរបស់ចិន ដើម្បីពង្រីកសក្ដានុពលសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ខណៈដែលអាមេរិក និង ប្រទេសមួយចំនួនខ្លាចគោលនយោបាយ ដែលចិន រៀបចំឡើង គឺ គំនិតផ្ដួចផ្ដើម ខ្សែក្រវាត់មួយ ផ្លូវមួយ ដែលកំពុងតែមានការគាំទ្រ ហើយសូម្បីតែមហាអំណាចនៅបច្ចឹមប្រទេស មួយចំនួន គឺជានយោបាយអនុគរភាពរបស់ចិន ។ ឆ្លើយតបនឹងគំនិតផ្ដួចផ្ដើមនេះ អាមេរិកបានដាក់ចេញនូវ គោលនយោបាយ អន្តរឥណ្ឌូ-ប៉ាស៊ីហ្វិក បើកចំហរមួយ ។

គោលនយោបាយរបស់លោក ដូណាល់ត្រាំចំពោះអាស៊ាន គឺខុសពីរដ្ឋបាលនៃប្រធានាធិបតីអាមេរិក មុន ។ នៅក្រោមរដ្ឋបាលរបស់លោកប្រធានាធិបតីអាមេរិក ប៉ារ៉ាក់ អូបាម៉ា អាមេរិកបានយកចិត្តទុកដាក់បំផុតចំពោះគោលនយោបាយការបរទេសចំពោះអាស៊ាន ដោយកាលពីឆ្នាំ២០១៥ លោក បានប្រកាសបើកចំហរប្រទេសអញ្ជើញ មេដឹកនាំអាស៊ានទាំងអស់ ទៅចូលរួមកិច្ចប្រជុំកំពូលអាមេរិក-អាស៊ានពិសេសនៅកាលីហ្វ័ញ៉ា នៅក្នុងខែកុម្ភៈ ឆ្នាំ ២០១៦ ។

ក្រោយពេលដែលមេដឹកនាំអាស៊ានបានវាយបកការទូតវិញ ទំនងជា លោក ដូណាល់ ត្រាំ ភ្ញាក់ ក៏បាន ព្យាយាមស្វះស្វែងរក ការផ្សះផ្សារផ្នែកការទូតជាមួយនឹងអាស៊ានវិញ។

ថ្មីៗនេះ លោក ដូណាល់ ត្រាំ បានផ្ញើលិខិតពីរច្បាប់ជូនសម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃ រាជរដ្ឋាភិបាលកម្ពុជា ដែលនៅក្នុងខ្លឹមសារនៃលិខិតនោះ គឺបានឆ្លុះបញ្ចាំងអំពីនយោបាយរបស់ អាមេរិក ចំពោះកម្ពុជា និងអញ្ជើញសម្ដេចតេជោ ហ៊ុន សែន ទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ាន-អាមេរិក ពិសេសដែលគ្រោងនឹងរៀបចំឡើងនូវក្នុងរង្វង់ដើមឆ្នាំ២០២០ ខាងមុខនេះ ។ ក្រៅពីមេដឹកនាំកម្ពុជា បណ្ដាមេដឹកនាំអាស៊ានផ្សេងទៀតក៏ប្រហែលជាបានទទួលលិខិត ដែលប្រគល់ដោយដៃ ឯកអគ្គរដ្ឋទូត អាមេរិក ផងដែរ ។

សរុបមកវិញ នៅក្នុងដំណាក់កាលបច្ចុប្បន្ននេះ អាស៊ានគឺជាតំបន់មួយដែលមិនអាចមើលស្រាលបាន ហើយ អាស៊ានថ្វីត្បិតតែមានភាសា មានការអភិវឌ្ឍន៍ខុសគ្នា មានវប្បធម៌ ប្រពៃណី និង សាសនា ខុសគ្នា ប៉ុន្តែគឺជាតំបន់ដែលមានលក្ខណៈពិសេសមួយ ដែលអាចឲ្យអាស៊ានក្លាយជាដៃគូសន្ទនា និងតួនាទី ដ៏ចំបងនៅលើពិភពលោក ។ នៅក្នុងគោលនយោបាយប្រឆាំងនិងឥទ្ធិពលរបស់ចិននៅលើពិភពលោកអាមេរិកគឺពិតជាមិនអាចអត់អាស៊ានបានឡើយ។នៅក្នុងគោលនយោបាយក៏ដូចជា យុទ្ធសាស្ត្រឥណ្ឌូ-ប៉ាស៊ីហ្វិក ដែលអាមេរិករៀបចំឡើងដើម្បីទប់ទល់នឹងឥទ្ធិពលចិន គឺពិតជាមិនអាច អត់ អាស៊ានបានឡើយ៕

# កម្មការិនីទទួលស្គាល់ថា ការយកចិត្តទុកដាក់ និងស្ថានភាពការងារកាន់តែប្រសើរ

*ដោយ៖ អរិយបុត្រ*





*កម្មការិនីកំពុងបំពេញការក្នុងរោងចក្រវាយនភណ្ឌកាត់ដេរស្ថិតនៅក្នុងតំបន់សូនឧស្សាហកម្មពិសេសកាណាឌីយ៉ា។ រូបភាព៖ ស៊ីអេសស៊ី*

បណ្ដាកម្មការិនីដែលកំពុងតែប្រឡូកផ្ទាល់នឹងរោងចក្រកាត់ដេរនៅកម្ពុជាពួកគេបានថ្លែងថា មកដល់ពេលនេះ ស្ថានភាពការងារ និងការយកចិត្តទុកដាក់លើសុខមាលភាព ក៏ដូចជាបរិយាកាសការងារគឺកាន់តែប្រសើរ ជាពិសេសគឺស្ត្រីដូចជាពួកគាត់ ។

លោកស្រី ដាំ សុភាព ដែលជាកម្មការិនីរោងចក្រនៅក្នុងតំបន់សួនឧស្សាហកម្មកាណាឌីយ៉ាមួយរូប បាននិយាយថា សព្វថ្ងៃនេះការងាររាងធូរដៃជាងមុន ប៉ុន្តែកម្មករគឺដូចជាទទួលបានអត្ថប្រយោជន៍ច្រើនជាងមុន ។

លោកស្រីបានបញ្ជាក់កាលពីថ្ងៃអាទិត្យពេលកំពុងតែដើរទៅផ្សារមួយថា៖ «កាលពីមុនពេលនេះម៉ោងនេះខ្ញុំកំពុងតែថែមម៉ោងអង្គុយដេរកោងខ្នងនៅឡើយទេ ប៉ុន្តែពេលនេះមានពេលសម្រាកថ្ងៃអាទិត្យ គ្រាន់ដើរទៅនេះទៅនោះ រីឯប្រាក់ខែក៏ច្រើន» ។

តាមការរៀបរាប់របស់លោកស្រី ដាំ សុភាព មកដល់ពេលនេះ លោកស្រីរស់នឹងជីវភាពជានារីនៃរោងចក្រកាត់ដេរនេះ តែម្ដង។ លោកស្រីបានរៀបរាប់ថា លោកស្រីបានមកកាន់ដេរតាំងពីអាយុ ១៥ ឆ្នាំ នៅពេលនេះអាយុ ៣០ ហើយ។

លោកស្រីបានបញ្ជាក់ថា៖ «មិនដឹងធ្វើអីមានតែដេរនៅរោងចក្រតាំងពីក្រមុំមិនដឹងអី ឥឡូវកូនពីរចង់បិទខ្ញុំហើយ»។

ដូចគ្នានឹងការអះអាងរបស់លោកស្រី ដាំ សុភាព ដែរ យុវតី ជុំលាងស៊ី ដែលបានអះអាងថា បច្ចុប្បន្ននេះការងារ នៅរោងចក្រគឺមានការយកចិត្តទុកដាក់ច្រើនណាស់ខុសពីពេលដែលកញ្ញាបានចូលមកធ្វើការដំបូងកាលពី ៥ ទៅ ៦ ឆ្នាំមុន។

កញ្ញាបានបញ្ជាក់ថា៖ «កាលពីចូលធ្វើការដំបូងខ្ញុំធ្លាប់សន្លប់ពីរទៅបីដងដែរ ដោយសារតែបរិយាកាសការងារ ដូចជាអាប់អួរពេក ប៉ុន្តែឥឡូវនេះ រោងចក្រភាគច្រើនគឺមានការកែលំអរ មានខ្យល់ចេញចូលច្រើន ដូច្នេះដូចជា មិនអីទៀតទេ» ។

ជុំលាងស៊ីបានបន្តទៀតថា ក្រៅពីបរិយាកាសការងារ រឿងប្រាក់ខែ រឿងលក្ខខណ្ឌការងារចេញកម្មករនិងកម្មការិនី រោងចក្រក៏មានធានារ៉ាប់រងសុខភាព ហើយនិងអត្ថប្រយោជន៍ផ្សេងៗទៀត ។

កញ្ញាបានបញ្ជាក់ថា៖ « ដូចលើកមុនអ្នកដែលមានកូន គឺបានប្រាក់ខែ តែពាក់កណ្ដាលទេ ប៉ុន្តែពេលនេះ ខ្ញុំឮគេថា នៅពេលយើងកើតកូន គឺមិនត្រឹមតែបានលុយ ទេ គឺដេកពេទ្យមិនអស់ប្រាក់ហើយបានប្រាក់ខែរ ច្រើនជាង ប្រាក់ខែយើងទៀតនៅក្នុងពេលសម្រាលកូន» ។

កញ្ញាបាននិយាយលេងសើចបន្ដិចថា៖ «រឿងសន្លប់ខ្ញុំធ្លាប់ហើយ តែមិនទាន់បានសាកអាកើតកូនបានលុយ និង បានប្រាក់ខែច្រើនជាងមុន»។

ទាំងនេះគឺជាគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការកែលំអរបរិយាកាសនិងលើកកំពស់អត្ថប្រ យោជន៍ចំពោះបងប្អូនកម្មករនិងកម្មការិនី ហើយថ្មីៗនេះ នៅក្នុងគម្រោងជម្រុញឲ្យវិស័យឧស្សាហកម្មមានបរិយាកាសកាន់តែប្រសើរទៀតនោះ គឺថា ក្រសួងពីរដែលមានក្រសួងពាណិជ្ជកម្ម និងក្រសួងការងារ បានរួមគ្នាជាមួយនឹងសមាគមរោងចក្រកាត់ដេរនៅកម្ពុជានិងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នៃអង្គការអន្តរជាតិខាងការងារបានចុះអនុស្សរណៈយោគយល់គ្នាសម្រាប់រយៈពេល៣ឆ្នាំខាងមុខ ដើម្បីបន្តកែលម្អលក្ខខណ្ឌការងារ នៅក្នុងវិស័យវាយនភ័ណ្ឌ និងកាត់ដេរសម្លៀកបំពាក់ ព្រមទាំងពង្រីកវិសាលភាព នៃការអនុវត្តអនុស្សរណៈយោគយល់គ្នានេះ ដោយដាក់បញ្ចូលវិស័យផលិតផលធ្វើដំណើរ និងកាបូបនៅប្រទេសកម្ពុជាផងដែរ គិតចាប់ពីខែ មករា ឆ្នាំ២០២០ ដល់ខែធ្នូ ២០២២។

គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នឹងបន្តធ្វើការវាយតម្លៃស្ដីពីលក្ខខណ្ឌការងារ នៅក្នុងរោងចក្រកាត់ដេរ ដោយផ្អែកទៅតាមច្បាប់ស្ដីពីការងារ របស់ប្រទេសកម្ពុជា និងបទដ្ឋានស្នូលការងារ ដែលទទួលស្គាល់ជា អន្តរជាតិ។ សេវាកម្មប្រឹក្សាយោបល់ និងវគ្គបណ្ដុះបណ្ដាលនានា ស្ដីពីការធ្វើឲ្យកន្លែងការងារ មានប្រសើរឡើង ព្រមទាំងបង្កើនផលិតភាព នឹងបន្តប្រតិបត្តិការជាទៀងទាត់ ជាមួយនឹងការយកកម្រៃសេវាទាំងនេះ។ គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ក៏នឹងបន្តធ្វើការជាមួយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ស្ដីពីការអនុវត្តផែនការយុទ្ធសាស្ត្រ និងសកម្មភាពរួមគ្នា ដោយគោលបំណងជួយបង្កើនសមត្ថភាពក្រសួង សម្រាប់ការធ្វើអធិការកិច្ច និងភាពជាម្ចាស់ការ ដើម្បីលើកកម្ពស់ការអនុលោមច្បាប់ស្ដីការងារ និងគាំទ្រ ក្នុងការដោះស្រាយនៅក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង វិស័យផលិតផលធ្វើដំណើរ និងកាបូបនៅ ប្រទេសកម្ពុជា។ លើសពីនេះ គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នឹងបន្តធ្វើការជាមួយសមាគម រោងចក្រកាត់ដេរ និងអ្នកផលិតវិស័យផលិតផលធ្វើដំណើរ និងកាបូប ដើម្បីធ្វើការរួមគ្នា ក្នុងការបង្កើន សមត្ថភាពរបស់រោងចក្រសម្រាប់ការអនុលោមច្បាប់ប្រកបដោយចីរភាព និងគាំទ្រដល់ពួកគេ ក្នុងការ ពង្រឹងប្រព័ន្ធគ្រប់គ្រង។

លោក ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានមានប្រសាសន៍ថា៖ «តាមរយៈការអនុវត្តគោល នយោបាយនៃការផ្សារភ្ជាប់ពាណិជ្ជកម្ម ជាមួយនឹងបទដ្ឋានការងារ បានប្រែក្លាយកេរ្តិ៍ឈ្មោះរបស់កម្ពុជា ទៅជាប្រទេសឈានមុខគេក្នុងគោលនយោបាយពាណិជ្ជកម្មអន្តរជាតិ និងបានធ្វើអោយកម្ពុជា ក្លាយជា ប្រទេសគំរូសម្រាប់ប្រទេសមួយចំនួន យកទៅធ្វើជាបទពិសោធន៍ សម្រាប់យកទៅអនុវត្ត និងរៀនសូត្រ តាម។ ការអនុវត្តគោលនយោបាយនៃការផ្សារភ្ជាប់ពាណិជ្ជកម្ម ជាមួយនឹងបទដ្ឋានការងារ ក៏បានបង្កើន ទំនុកចិត្តដល់អ្នកបញ្ជាទិញម៉ាកយីហោល្បីៗក្នុងការដាក់បន្ថែមការបញ្ជាទិញផលិតផល សម្លៀកបំពាក់ និងវាយនភ័ណ្ឌនៅកម្ពុជា»។

ជាមួយគ្នានេះដែរ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានមានប្រសាសន៍ថា៖ «ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈតែងតែចាត់ទុកគម្រោងរោងចក្រកាន់ តែប្រសើរនៅកម្ពុជា និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា គឺជាដៃគូដ៏សំខាន់ក្នុងការចូលរួមចំណែក លើកកម្ពស់សិទ្ធិនិងលក្ខខណ្ឌការងារ និងការជំរុញភាពប្រកួតប្រជែង និងផលិតភាពការងារនៅក្នុង វិស័យវាយនភណ្ឌ និង សម្លៀកបំពាក់នៅកម្ពុជា។ នៅក្នុងអនុស្សរណៈនៃការយោគយល់គ្នាថ្មីនេះ យើងបាន ឯកភាពគ្នាដាក់បញ្ចូលផងដែរនូវវិស័យផលិតផលធ្វើដំណើរ និងកាបូប នៅក្រោមគម្រោងរោងចក្រកាន់ តែប្រសើរនៅកម្ពុជា ដែលជាការបោះជំហានកាន់តែទូលំទូលាយមួយកម្រិតថែមទៀតក្នុងការពង្រីក វិសាលភាពរបស់ខ្លួន និងជាការឆ្លុះបញ្ចាំងពីការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់ លក្ខខណ្ឌការងារក្នុងវិស័យវាយនភ័ណ្ឌសម្លៀកបំពាក់និងផលិតផលធ្វើដំណើរ និងកាបូប អនុលោមតាមបទដ្ឋានការងារស្នូលដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងអនុលោមតាមច្បាប់ស្ដីពីការងារកម្ពុជា»៕



*លោក ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ រូបភាព៖ ក្រសួងពាណិជ្ជកម្ម*









*ក្រុមហ៊ុនក្នុងស្រុកជួលកម្មករជាមធ្យម៨នាក់ក្នុងមួយក្រុមហ៊ុន បើប្រៀបធៀបទៅនឹង១២៨នាក់ក្នុងក្រុមហ៊ុនដែលគ្រប់គ្រងដោយជនបរទេស។ រូបភាព៖ ស៊ីអេសស៊ី*

# ស្ថាប័នអន្តរជាតិមួយអះអាងថា គុណភាព ការងារនៅកម្ពុជាកំពុងមានការកែលម្អ

**របាយការណ៍នៃការសិក្សាថ្មីមួយអំពីគុណភាពការងារនៅកម្ពុជាបានអះអាងថា ភាពចម្រុះនិងគុណភាពនៃការងារដែលមាននៅក្នុងប្រទេសកំពុងតែមានការកែលម្អឱ្យប្រសើរឡើង ប៉ុន្តែកម្ពុជាចាំបាច់ត្រូវមានគោលនយោបាយថ្មីៗដើម្បីទាញយកអត្ថប្រយោជន៍ពីឱកាសនានាដែលអាចរកបាននៅលើទីផ្សារពិភពលោកនាពេលអនាគត។**

*ដោយ៖ អរិយបុត្រ*



*ជនមានពិការភាពត្រូវបានយកចិត្តទុកដាក់ក្នុងពេលបំពេញការងារ។ រូបភាព៖ ស៊ីអេសស៊ី*

របាយការណ៍របស់ធនាគាពិភពលោកក្រោមចំណងជើងថា អនាគតការងារនៅប្រទេសកម្ពុជា៖ តំណភ្ជាប់ជាមួយសេដ្ឋកិច្ចនាពេលខាងមុខ ដែលចេញផ្សាយនៅកាលពីពេលថ្មីៗនេះបាន និយាយថា ក្នុងចំណោមការងារចំនួន៨លាននៅក្នុងប្រទេសកម្ពុជាមាន៣៧ភាគរយជាការងារមានប្រាក់ឈ្នួលដែលភាគច្រើនផ្ដល់ប្រាក់ចំណូលខ្ពស់គ្រាន់បើ និងអត្ថប្រយោជន៍ការពារបន្ថែមដល់កម្មករ ប៉ុន្តែ៦៣ភាគរយទៀតនៅតែជាការងារបែបប្រពៃណីនៅឡើយ ក្នុងនោះមានការងារដាំដុះ ឬអាជីវកម្មជាលក្ខណៈគ្រួសារដែលមិនសូវបានធ្វើសមាហរណកម្មចូលទៅក្នុងសេដ្ឋកិច្ចទំនើបប៉ុន្មានទេ ហើយផ្ដល់ឱ្យកម្មករនូវប្រាក់ចំណូលទាបជាង។



*លោកស្រី អ៊ិនហ្គូណា ដូប្រាចា ប្រធានគ្រប់គ្រងធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា។ រូបភាព៖ ធនាគារពិភពលោក*

លោកស្រី អ៊ិនហ្គូណា ដូប្រាចា ប្រធានគ្រប់គ្រងធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា មាន ប្រសាសន៍ថា៖ «ភាពចម្រុះនិងគុណភាពនៃការងារនៅក្នុងប្រទេសកម្ពុជាត្រូវបានកែលម្អឱ្យប្រសើរ ឡើងជាបណ្ដើរៗហើយ ប៉ុន្តែនិន្នាការសកលមានដូចជាការកើនឡើងនូវចំនួនរបស់វណ្ណៈកណ្ដាល ក្នុងតំបន់អាស៊ី បម្រែបម្រួលលំនាំក្នុងការធ្វើពាណិជ្ជកម្ម និងស្វ័យប្រវត្តិកម្ម តម្រូវឱ្យកម្ពុជាគិតគូរ ឡើង វិញអំពីយុទ្ធសាស្ត្រការងាររបស់ខ្លួន ខណៈដែលប្រទេសនេះកំពុងឈានឆ្ពោះទៅកាន់ដំណាក់ កាល មួយទៀតនៃការអភិវឌ្ឍផ្អែកលើការនាំចេញ»។

ការសិក្សានោះបានអះអាងថា ក្រុមហ៊ុនដែលគ្រប់គ្រងដោយជនបរទេសបានដើរតួយ៉ាងសំខាន់ក្នុងការងាររួមចំណែកបង្កើតការងារមានគុណភាពខ្ពស់នៅក្នុងប្រទេសកម្ពុជា។ មកដល់ឆ្នាំ២០១៥ មួយភាគបីនៃការងារមានប្រាក់ឈ្នួលនៅកម្ពុជា គឺស្ថិតនៅក្នុងក្រុមហ៊ុនដែលគ្រប់គ្រងដោយជនបរទេស។ ក្នុងអំឡុងឆ្នាំ២០១០-២០១៥ ឧស្សាហកម្មកាត់ដេរគឺជាវិស័យមុខរបរដែលមានការរីកលូតលាស់យ៉ាងលឿនបំផុតដោយបង្កើនចំណែករបស់ខ្លួននៅក្នុងការបង្កើតការងារបាន ១,១ភាគរយក្នុងមួយឆ្នាំ។

ប្រភពដដែលបានបន្តថា ក្រុមហ៊ុនក្នុងស្រុកមានចំនួនច្រើនជាងក្រុមហ៊ុនដែលគ្រប់គ្រងដោយជនបរទេសប៉ុន្តែពួកគេមិនបានចូលរួមចំណែកបង្កើតការងារបានច្រើនទេ។ ក្រុមហ៊ុនក្នុងស្រុកជួលកម្មករជាមធ្យម៨នាក់ក្នុងមួយក្រុមហ៊ុន បើប្រៀបធៀបទៅនឹង១២៨នាក់ក្នុងក្រុមហ៊ុនដែលគ្រប់គ្រងដោយជនបរទេស។ កង្វល់ធំមួយគឺនៅត្រង់ការធ្វើយ៉ាងណាឱ្យពលករកម្ពុជាមានជំនាញចាំបាច់ដើម្បីពួកគាត់អាចទៅប្រកួតប្រជែងជាមួយកម្មករមកពីប្រទេសផ្សេងទៀត ក្នុងការស្វែងរកការងារធ្វើក្នុងក្រុមហ៊ុនដែលគ្រប់គ្រងដោយបរទេស។ នៅឆ្នាំ២០១៦ ៣៧,៦ភាគរយនៃក្រុមហ៊ុននាំចេញបានប្រាប់ឱ្យដឹងថា កម្លាំងពលកម្មដែលមានការអប់រំជំនាញមិនគ្រប់គ្រាន់ជាឧបសគ្គចម្បងដល់ការធ្វើអាជីវកម្ម។

របាយការណ៍នេះស្នើជូនអនុសាសន៍បែបយុទ្ធសាស្ត្រ៩ដើម្បីធានាសម្រាប់ឲ្យមានការងារច្រើននិងប្រសើរនាពេលអនាគត៖ ធ្វើពិពិធកម្មវិស័យនាំចេញឲ្យចូលក្នុងខ្សែចង្វាក់តម្លៃនៃតម្លៃបន្ថែម បង្កើតបរិយាកាសធុរកិច្ចក្នុងស្រុកដែលគាំទ្រដល់ការរីកលូតលាស់នៃក្រុមហ៊ុនក្នុងស្រុក ពង្រឹងការតភ្ជាប់រវាងវិស័យការងារក្នុងស្រុក និងការនាំចេញនៃសេដ្ឋកិច្ច និងការវិនិយោគលើជំនាញនិងការអប់រំនៃកម្មករ។ របាយការណ៍បានលើកឡើងជាគោលនយោបាយជាក់លាក់ពាក់ព័ន្ធការងារចំនួន ៧ ដែលអាចជួយសម្រេចបានយុទ្ធសាស្ត្រនេះ៖ ១.ធ្វើពិពិធកម្មវិស័យនាំចេញនិងការវិនិយោគផ្ទាល់ពីបរទេស ឱ្យចូលទៅក្នុងខ្សែចង្វាក់តម្លៃនៃតម្លៃបន្ថែមកាន់តែខ្ពស់។ ២.សម្រួលដំណើរការនីតិវិធីឱ្យរលូន និងកាត់បន្ថយចំណាយថ្លៃដើមលើការបង្កើតនិងការពង្រីកសហគ្រាសខ្នាតតូចនិងមធ្យម ដែលមានសក្ដានុពលច្រើនគួរសមនៅក្នុងការបង្កើតការងារ។ ៣.ជួយដល់អាជីវកម្មតាមគ្រួសារឱ្យពង្រីកផលិតភាពរបស់ខ្លួន និងបង្កើតការងារកាន់តែល្អឡើង។ ៤.គាំទ្រការអភិវឌ្ឍបណ្ដាញតភ្ជាប់រវាងក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេសសម្រាប់ការនាំចេញនិងក្រុមហ៊ុនផ្គត់ផ្គង់ធាតុចូលក្នុងស្រុក។៥.កសាងប្រព័ន្ធអភិវឌ្ឍន៍ជំនាញមួយដែលនឹងអាចទាក់ទាញបានការវិនិយោគផ្ទាល់ពីបរទេសដែលមានតម្លៃកាន់តែខ្ពស់ និងបង្កើនផលិតភាពនៅតាមគ្រប់ផ្នែកនៃសេដ្ឋកិច្ច។ ៦.លើកកម្ពស់ចល័តភាពនៃកម្លាំងពលកម្មនិងការផ្គូផ្គងជំនាញជាមួយការងារ ឱ្យមានប្រសិទ្ធផលខ្ពស់។ ៧. យកមកវិញឱ្យបាននូវឯករាជ្យភាពផ្នែកម៉ាក្រូសេដ្ឋកិច្ច និងអត្រាប្តូរប្រាក់មួយដែលមានភាពបត់បែន។ដំណើរឡើងចុះតម្លៃប្រាក់ដុល្លារអាមេរិកជះឥទ្ធិពលយ៉ាងខ្លាំងដល់វិស័យពាណិជ្ជកម្មនិងទំនិញរបស់កម្ពុជាដែលទទួលខុសត្រូវលើការបង្កើតការងារភាគច្រើនរបស់ប្រទេស៕



# ពិណខ្មែរ

**យុវជនខ្មែរសម័យនេះ ប្រហែលជាមិនធ្លាប់ស្គាល់ទេ នូវពិណខ្មែរ និងបានស្តាប់នូវសូរសៀង យ៉ាងពីរោះរណ្តំ ប៉ុន្តែបើនិយាយពីឧបករណ៍ ភ្លេងសម័យដែលកំពុងតែហូរចូលមកពីក្រៅប្រទេសនោះ ដូចជាហ្គីតាអ័រហ្គាន នោះប្រហែលជាមានអ្នកស្គាល់ច្រើន។ ទោះបីជាសម័យបច្ចុប្បន្ននេះ សម្បូរបែបទៅដោយឧបករណ៍តន្ត្រី ដែលកំពុងហូរចូលយ៉ាងគំហុកពីបរទេសនោះ កម្ពុជាក៏មាននូវឧបករណ៍តន្ត្រីមួយដែលបានបាត់បង់ជិតមួយសហសវត្សមកហើយនោះ គឺពិណបុរាណខ្មែរ។**

*ដោយៈ ផល សុផានិត*

ពិណខ្មែរជាឧបករណ៍តន្ត្រីខ្មែរមួយប្រភេទ ដែលមានឆ្លាក់នៅលើជញ្ជាំងប្រាសាទនានា ហើយខ្មែរយើងទើបតែរកឃើញនិងបង្កើតចេញមកដើម្បីប្រគំជាមួយភ្លេងប្រពៃណីដទៃទៀត។

នៅក្នុងវង់ភ្លេងខ្មែរ ដែលយើងតែងឮថា ពិណពាទ្យ ប្រគំក្នុងកម្មវិធីបុណ្យផ្សេងៗ មនុស្សជាច្រើនតែងដណ្តឹងសួរគ្នាថា ហេតុអ្វីយើងមានឈ្មោះវង់ភ្លេងនេះ តែពិណនោះមានរូបរាងយ៉ាងណាទៅ?

សម្លេងណៃណង ពីរោះស្រទន់ ដែលចេញពីឧបករណ៍តន្ត្រីមួយប្រភេទមានដងវែងកោងទៅលើ ក្បាលរូបនាគ ឬគ្រុឌ មានខ្សែដេញជាច្រើន ដែលធ្វើឲ្យសំលេងរបស់វាអាចទាក់ចិត្តអ្នកស្តាប់និងទស្សនាបង្កើតមនោសញ្ចេតនាទៅតាមបទភ្លេង។ នៅក្នុងសណ្ឋាគារផ្កាយ៥មួយកន្លែងក្នុងប្រទេសកម្ពុជា សិល្បការិនីវ័យក្មេង២រូបបានអង្គុយប្រគំ កំដរអារម្មណ៍ចិត្តទេសចរណ៍។



*ឧបករណ៍តន្ត្រីពិណត្រូវបានប្រគំ នៅតាមការប្រគំតន្ត្រីបែបសហសម័យ ព្រមទាំងការរៀបចំរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក៏មាននៅតាមសណ្ឋាគារធំៗមួយចំនួនសម្រាប់ស្វាគមន៍ភ្ញៀវទេសចរ។* *រូបភាពៈ សហការី*

ពិណខ្មែរ មានតាំងពីយូរលុងណាស់មកហើយ ពីមួយជំនាន់ទៅមួយជំនាន់តន្ត្រីករ ត្រូវបានបង្រៀន និងរៀនដើម្បីប្រគំក្នុងវង្សភ្លេងព្រះរាជទ្រព្យ ហើយក៏ត្រូវបានវិចិត្រករខ្មែរសម័យបុរាណឆ្លាក់នៅតាមជញ្ជាំងប្រាសាទនានា ជាពិសេសគឺប្រាសាទបន្ទាយឆ្មារ ដើម្បីជាតង្វាយសម្រាប់ព្រះអាទិទេពរបស់ព្រហ្មណ៍សាសនា។ ខ្មែរយើងបានបាត់ឧបករណ៍បុរាណនេះ ប្រហែលជាង៨០០ឆ្នាំមុន នេះបើផ្អែកទៅលើចម្លាក់ដែលគេប្រទះឃើញនៅលើជញ្ជាំងប្រាសាទបាយ័ន។

ចាប់តាំងពីស.វទី៧ ដល់ទី១២ តាមប្រវត្តិសាស្ត្រខ្មែរឧបករណ៍ពិណ ត្រូវបានសាបនៅតួនាទីរបស់ខ្លួន តាំងពីពេលដែលអរិយធម៌អង្គរត្រូវបានធ្លាក់ចុះមក ចំណែកព្រហ្មណ៍សាសនាត្រូវបានប្រែប្រួល និងជំនឿរបស់ប្រជាជន បែរទៅរកព្រះពុទ្ធសាសនា ជាហេតុធ្វើឲ្យតន្ត្រីករ និងនាតករ នាតការិនីបាត់បង់ឱកាសសម្តែងខ្លះៗ ចន្លោះឆ្នាំ ១៤៣១ ជាឆ្នាំប្រវត្តិសាស្ត្រកម្ពុជា បាត់បង់ស្ទើរទាំងអស់នូវអ្នកប្រាជ្ញ បណ្ឌិត កវី និងតន្ត្រីករ។

លោក កែវ សុភី សាស្ត្រាចារ្យមហាវិទ្យាល័យតូរ្យតន្ត្រីនៃសកលវិទ្យាល័យវិចិត្រសិល្បៈមានប្រសាសន៍ថា៖ «បើតាមខ្ញុំឧបករណ៍ពិណនេះ យើងបាត់បង់ជិត១ពាន់ឆ្នាំមកហើយ ព្រោះឧបករណ៍ពិណនេះកើតនៅសម័យមហានគរ ដែលដូនតាយើងបានសាងប្រាសាទអង្គរវត្តនោះ ហើយក៏មានការឆ្លាក់រូបពិណនៅលើជញ្ជាំងប្រាសាទនោះ។រយៈពេលដ៏យូរនេះ ជនជាតិខ្មែរយើងបានភ្លេចនៅពិណនេះ ដល់ពេលដែលប្អូនសួរថា យុវជនយើងស្រឡាញ់ពេញចិត្ត ឧបករណ៍នេះកម្រិតណានោះ ខ្ញុំមិនទាន់ហ៊ានឆ្លើយសំណួរនេះទេ។ ឥឡូវនេះយើងទើបតែបង្កើត ដែលមិនមែនធ្វើថ្មីទេ តែយើងចម្លងនៅជញ្ជាំងប្រាសាទ។ ចឹងមហាជនទូទៅ គាត់មិនបានស្គាល់ច្រើននោះទេ តែការគាំទ្រ ការស្រលាញ់នោះនៅមានកម្រិតទាបនៅឡើយ»។

យុវនារីខ្មែរ ២រូប ដែលមានម្រាមដៃតូចស្រលូន ស្ទាជាប់ជាមួយពិណខ្មែរ ដែលមានខ្សែពិណសរុប១៦ ដៃកេះយ៉ាងពីរោះរណ្តំ នៅលើភ្លៅ ក្នុងសណ្ឋាគារលំដាប់ខ្ពស់ សម្រាប់ចែកជូនភ្ញៀវសណ្តាប់កម្សាន្ត ដែលអង្គុយពន់ពេនទៅតាមរៀងនៃពិណខ្មែរ។



*រូបចម្លាក់ជញ្ជាំងប្រាសាទអំពីនារីក្រមុំព្រហ្មចារីកំពុងលេងពិណ។* *រូបភាពៈ សហការី*

កញ្ញា សួន កវីសរីរ័ត្ន ជាតន្ត្រីការិនី ដំបូងបង្អស់ដែលចាប់ផ្តើមរៀនឧបករណ៍នេះ នៅពេលបង្កើតវាបាន។

តន្ត្រីការិនី សួន កវីសរីរ័ត្ន៖ «ខ្ញុំគិតថា ឧបករណ៍ពិណ មិនមែនជាឧបករណ៍បង្កើតថ្មី តែវាជាឧបករណ៍ដែលមានវ័យចំណាស់ដែលបាត់បង់ ហើយទើបរកឃើញ ដែលធ្វើឲ្យខ្ញុំចង់រក្សា ឲ្យកូនខ្មែរជំនាន់ក្រោយ និងណាមួយចិត្តខ្ញុំស្រលាញ់ឧបករណ៍នេះផង»។

កញ្ញា ពៅ រស្មីមុន្នី ជាតន្ត្រីការនីពិណខ្មែរម្នាក់ទៀតនិយាយថា៖ «ខ្ញុំចង់រក្សានូវឧបករណ៍ពិណខ្មែរនេះ ឲ្យកាន់តែរីកចម្រើន ជាពិសេសទៀតនោះគឺនាងខ្ញុំមានឈាមជ័រជាអ្នកសិល្បៈគឺខ្ញុំចង់ថែរក្សាបន្ត»។

កញ្ញា ពៅ រស្មីមុន្នី បន្តថា ឧបករណ៍នេះមិនពិបាករៀនទេ តែដំបូងគឺត្រូវហ្វឹកហ្វាត់ជាមួយដៃឲ្យស្ទាត់។ នាងបានប្រាប់ថា៖ «ឧបករណ៍នេះមានការលំបាកខ្លះ ស្រួលខ្លះ ដំបូងឡើយពេលដែលខ្ញុំរៀនធ្វើឲ្យខ្ញុំពងដៃ»។

ពិណខ្មែរមានរូបរាងដូចជាទូក តែតូចល្មមងាយស្រួលដាក់នៅលើភ្លៅ និងមានកវែងដែលរចនាឡើងតាមសណ្ឋានដែលគេចង់បាន។ ខ្សែពិណធ្វើពីសរសៃរសូត្រស្វិត និងមានជំល្អេញ សម្រាប់រឹតបន្តឹងខ្សែពិណតាមចិត្តចង់បាន ហើយទំងន់របស់វាមានប្រហែលពី២ទៅ៣គីឡូក្រាម។

តាមឯកសារបង្ហាញនៅលើជញ្ជាំងប្រាសាទនានា អ្នកលេងពិណភាគច្រើន ជានារីក្រមុំព្រហ្មចារី ដូចជានារីសួគ៌។

ទោះបីជាពិណទើបតែបង្កើត តែវាត្រូវបានមនុស្សមួយចំនួនសាទរជាមួយការរកឃើញឧបករណ៍បុរាណមួយនេះ។ កញ្ញា សួន កវីសរីរ័ត្នសំណូមពរថា៖ «ខ្ញុំសូមឲ្យយុវជនខ្មែរគ្រប់រូប ស្វែងយល់ពីឧបករណ៍ភ្លេងបុរាណឲ្យបានច្រើន»។

រីឯកញ្ញា ពៅ រស្មីមុន្នីក៏បានសំណូមពរដែរថា៖ «ខ្ញុំសូមឲ្យយុវជនខ្មែរជំនាន់ក្រោយ ស្វែងយល់ពីសិល្បៈខ្មែរទម្រង់បុរាណ និងជួយលើកស្ទួយបន្ថែម»។

អ្នកនាង នៅ ចន្ធូរ មានវ័យជាង ២០ឆ្នាំ បានឲ្យដឹងតាមរយៈសារអេឡិចត្រូនិច ថាអ្នកនាងមិនសូវស្គាល់ច្បាស់អំពីឧបករណ៍ពិណនេះទេ ដោយសារតែវាមិនសូវមានតន្ត្រីករណាម្នាក់ប្រគំនៅតាមទីសាធារណៈនោះទេ ភាគច្រើនសម្តែងតែនៅតាមការប្រគំតន្ត្រីធំៗ ឬការរៀបចំពិពណ៌សិល្បៈរបស់ជាតិ ជាហេតុធ្វើឲ្យនាងមិនសូវច្បាស់ពីឧបករណ៍តន្ត្រីបុរាណមួយនេះទេ។

ចំណែកយុវវ័យមួយរូបទៀត លោក បញ្ញា បានឲ្យដឹងថា «ខ្ញុំបានស្គាល់តែមិនសូវច្បាស់ទេ ចំពោះរូបរាង និងសំឡេងរបស់ឧបករណ៍តន្ត្រីបុរាណនេះ ព្រោះតែការផ្សព្វផ្សាយនៅមានកម្រិតនៅឡើយ និងម្យ៉ាងទៀត មិនសូវមានការប្រគំឧបករណ៍មួយនេះច្រើននៅឡើយនោះទេ»។

បច្ចុប្បន្ននេះឧបករណ៍តន្ត្រីពិណត្រូវបានប្រគំ នៅតាមសណ្ឋាគារធំៗមួយចំនួនសម្រាប់ស្វាគមន៍ភ្ញៀវទេសចរណ៍ចូលទៅស្នាក់នៅ និងនៅតាមការប្រគំតន្ត្រីបែបសហសម័យ ព្រមទាំងការរៀបចំរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីឲ្យយុវជនខ្មែរជំនាន់ក្រោយបានស្គាល់ និងស្តាប់សំឡេងរបស់វា៕





# កម្ពុជានាំចេញផលិតផលកសិកម្ម លើសពី១០ប្រភេទទៅក្រៅប្រទេស

*ដោយៈ អរិយបុត្រ*

នៅក្នុងរយៈពេលប្រមាណជាជិត១១ខែនៃឆ្នាំ២០១៩ នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទបានបញ្ជាក់ថា កម្ពុជាបាននាំចេញផលិតផលកសិកម្មលើសពី១០ប្រភេទទៅកាន់ទីផ្សារអន្តរជាតិ។

នៅក្នុងរបាយការណ៍ដែលបានផ្សព្វផ្សាយដោយលោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និង នេសាទ បានឲ្យដឹងថា នៅក្នុងរយៈពេល១០ខែ ២៥ថ្ងៃសម្រាប់ឆ្នាំ២០១៩ នេះ ទំនិញដែលកម្ពុជានាំចេញទៅកាន់ទីផ្សារអន្តរជាតិមានដូចជា អង្ករ ផលិតផលធ្វើអំពីតំឡូងមី គ្រាប់ស្វាយចន្ទី ពោត សណ្តែកសៀង ចេក ស្វាយម្រេចនិង បន្លែមួយចំនួន។

ប្រភពដដែលបានបន្តថា នៅក្នុងអំឡុងពេលនេះ ផលិតផលកសិកម្មកម្ពុជាទាំងអស់នោះ ត្រូវបាននាំចេញនៅក្នុងបរិមាណប្រមាណជា ៣,៧៤ លានតោន ហើយទីផ្សារមានប្រទេសជិតខាង សហភាពអឺរ៉ុប មជ្ឈឹមបូពារ អឺរ៉ុបខាងកើត មួយចំនួន ចិន កូរ៉េ ជាដើម។

ប្រភពដដែលបានឲ្យដឹងថា រហូតមកដល់រយៈពេលដដែល កម្ពុជាបាននាំចេញអង្ករនៅក្នុងបរិមាណសរុប ៤៩៩.៦៣៣ តោនដោយទីផ្សារគឺមានចិន ច្រើនជាងគេ ពោលគឺប្រមាណជា ៣៩,៧១ភាគរយនៃចំណែកទីផ្សារនាំចេញអង្ករ បន្ទាប់មកគឺអឺរ៉ុប ដែលមានប្រមាណជា ៣៤,២១ភាគរយដែរ ហើយក៏នៅមានអាស៊ាន និង ប្រទេសផ្សេងៗទៀត។

សម្រាប់ផលិតផលម្រេចបរិមាណនៃការនាំចេញគឺមានប្រមាណតែ ៣.៥៧៤ តោន ប៉ុន្តែទីផ្សារគឺធំទូលាយ ដែលមានរហូតដល់ទៅ ២១ ប្រទេស ដោយរាប់ទាំង វៀតណាម បារាំង អាល្លឺម៉ង់ ឆេក អង់គ្លេស ជប៉ុន សិង្ហបុរី កូរ៉េ អារ៉ាប៊ីសាអូឌិត ឥណ្ឌា តៃវ៉ាន់ ប៊ែលហ្ស៊ិក ថៃ អូស្ត្រាលី ស្វីស កាណាដា កាហ្សាក់ស្ថាន រុស្ស៊ី ហុងកុង អាមេរិក និង ប៊ុលហ្គារី។

ផលិតផលកសិកម្មកម្ពុជាដែលបាននាំចេញទៅច្រើនប្រទេសបន្ទាប់តែបរិមាណនៃការនាំចេញនៅតូចដែរនោះគឺមាន គ្រាប់ស្វាយចន្ទី។ បរិមាណនៃការនាំចេញគ្រាប់ស្វាយចន្ទីគឺមានចំនួនប្រមាណជា ១៦៩.៥៩១តោន ហើយទីផ្សារគឺមាន ១២ ប្រទេស ដែលរួមមាន ដូចជា វៀតណាម រុស្ស៊ី កូរ៉េ ចិន ប៉េរូ អារ៉ាប៊ីសាអូឌីត មីយ៉ាន់ម៉ា ឥណ្ឌា អូស្ត្រាលី តៃវ៉ាន់ សិង្ហបុរីនិង ម៉ាឡេស៊ី។

នៅក្នុងចំណោមផលិតផលកសិកម្មដែលនាំចេញទាំងអស់ផលិតផលដំឡូងមីគឺកម្ពុជាបាននាំចេញ គឺច្រើនប្រភេទ ដោយមានទាំងចំណិតដំឡូងមីក្រៀម ដែលមានបរិមាណនាំចេញប្រមាណជា ១.១៥៤.៤១៤ តោន ដំឡូងមីស្រស់ប្រមាណជា ១.២៩៦.៧០០ តោន និង ម្សៅដំឡូងមី គឺប្រមាណជា ៥០.៤២៦តោន ដោយទីផ្សារគឺមានទូលំទូលាយដែរ គឺប្រមាណជា ៧ ប្រទេស ដែលមានដូចជា វៀតណាម ចិន ហូឡង់ ឆេក កាណាដា អ៊ីតាលី និង ឥណ្ឌា។



*គ្រាប់ស្វាយចន្ទី ជាផលិតផលដែលមានសក្តានុពលនៅលើទីផ្សារនាំចេញនាពេលបច្ចុប្បន្ន។* *រូបភាពៈ សហការី*

ដោយឡែកសម្រាប់ផលិតផលកសិកម្មផ្សេងទៀតដូចជា ចេក ផ្លែស្វាយ និង បន្លែ គឺមានបរិមាណនាំចេញសរុបនៅក្នុងរយៈពេលនេះប្រមាណជា ១៤៣.៩១៧តោន ហើយទីផ្សារ គឺមានដូចជា វៀតណាម ថៃ សិង្ហបុរី បារាំង រុស្ស៊ី ចិន ជប៉ុន ជាដើម។

ការនាំចេញពោតក៏គ្រាន់បើដែរ ដោយនៅក្នុងរយៈពេលនេះការនាំចេញគឺនៅក្នុងបរិមាណសរុបប្រមាណជា ១១៤.៧០២ តោន ហើយទីផ្សារនាំចេញគឺមាន វៀតណាម ថៃ និង កោះតៃវ៉ាន់។ ដោយឡែកសណ្តែកសៀង គឺមានបរិមាណនៃការនាំចេញតិចតួចគឺនៅក្នុងបរិមាណប្រមាណជា ត្រឹមតែ ៥៦.២៥០ តោន ហើយទីផ្សារគឺមានតិចបំផុតគឺតែប្រទេសវៀតណាម និងថៃ។



*រូបចម្លាក់ជញ្ជាំងប្រាសាទអំពីនារីក្រមុំព្រហ្មចារីកំពុងលេងពិណ។* *រូបភាពៈ សហការី*

លោក សាញ់ សម្បត្តិ កសិករដាំដំណាំនៅចំការលើ ខេត្តកំពង់ចាមមួយរូប បានឲ្យដឹងថា ចាប់តាំងពីលោកធំដឹងក្តីមក ដំណាំដែលមានសក្តានុពលនៅលើទីផ្សារនាំចេញខាងលើ គឺលោកបានធ្លាប់ដាំសឹងតែទាំងអស់ រាប់តាំងពីកៅស៊ូ ប៉ុន្តែនៅពេលនេះ លោកដាំតែតំឡូងមីដើមចន្ទី តែប៉ុណ្ណោះ។

លោក បានអះអាងថា ជារួមដំណាំនេះ គឺមិនសូវរើសដី ហើយមានទីផ្សារ គ្រាន់តែពេលខ្លះវាថោកបន្តិចតែនៅតែមានអ្នកទិញដោយឡែកដំណាំផ្សេងទៀត ជាពិសេស គឺសណ្តែកសៀង ល្ង អី ពេលខ្លះពិបាករកអ្នកទិញ។

លោកបានឲ្យដឹងថា អ្នកមកទិញភាគច្រើនទិញតែបន្តិចបន្តួច គ្រាន់តែយកទៅផ្សារនៅក្នុងស្រុកប៉ុណ្ណោះ ដូច្នេះហើយបានជាលោក និងអ្នកភូមិមួយចំនួនខ្ជិលដាំ។

លោកស្រី ច័ន្ទ ចំរើន ជាកសិករ និងជាឈ្មួញជួញកសិផលមួយរូប បានអះអាងថា រហូតមកដល់ពេលនេះ ផលិតផលកសិកម្មដែលស្រួលរកទីផ្សារ គឺមានតែគ្រាប់ស្វាយចន្ទី និង ដំឡូងមី ឯផលិតផលផ្សេងទៀត ដូចពិបាក។

លោកស្រីបានបញ្ជាក់ថា៖ «សម្រាប់ខ្ញុំម៉ូយ ភាគច្រើនគឺមានតែនៅវៀតណាម និងថៃ ហើយក្រៅពីស្រូវ ពោត អី គឺគេត្រូវការតែ គ្រាប់ស្វាយចន្ទី និង ដំឡូងមី នេះឯង»៕



*ឯកឧត្តម វេង សាខុន ពិនិត្យមើលទិន្នផលពោតដែលប្រជាជនផលិតបាន។* *រូបភាពៈ ក្រសួងកសិកម្ម*



*អង្ករស្អិតក្នុងឃ្លាំងរង់ចាំការនាំចេញ ខណៈតម្លៃស្រូវនាពេលបច្ចុប្បន្នកំពុងជួបបញ្ហា។* *រូបភាពៈ សហការី*

# អំពើជួញដូរមនុស្សនៅតែក្តៅសម្រាប់កម្ពុជា

*ដោយ៖ ដាលីស*



*សម្តេចក្រឡាហោម ស ខេង ជាអធិបតីក្នុងទិវាជាតិប្រឆាំងការជួញដូរមនុស្ស១២ធ្នូ។ ស៊ីអេសស៊ី*

ប្រជាពលរដ្ឋ តំណាងសាសនា មន្ត្រីរាជការ និងស្ថាប័នអង្គការ ប្រមាណជាង៣៥០០នាក់បានចូលរួមក្នុង «ទិវាជាតិប្រឆាំងការជួញដូរមនុស្ស១២ធ្នូ» លើកទី១៣ ដើម្បីផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីអំពើជួញដូរមនុស្ស នៅសាលពិព័រណ៍និងមហោស្រពកោះពេជ្រ នារសៀលថ្ងៃទី១២ ធ្នូ ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ទិវានេះបានធ្វើឡើងនៅក្រោមប្រធានបទ «រួមសហការគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស»។

សម្តេចក្រឡាហោម ស ខេង បានលើកឡើងថា បញ្ហាការជួញដូរមនុស្សនេះនៅតែជាបញ្ហា ស្មុគស្មាញ និងក្តៅគុកសម្រាប់រដ្ឋាភិបាល និងបណ្តាប្រទេសនៅក្នុងពិភពលោកដែលត្រូវរួមគ្នាបង្ការនិងដោះស្រាយ។

សម្តេចបានបន្តបន្ថែមទៀតថា៖ «រាជរដ្ឋាភិបាល បញ្ជាក់សារជាថ្មីនូវការប្តេជ្ញាចិត្តបន្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងគោលដៅការពារ និងលើកកម្ពស់ សុវត្ថិភាពរបស់មនុស្សគ្រប់រូប និង សន្តិសុខសង្គម ក៏ដូចជាលើកកម្ពស់ការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរនិងផលប្រយោជន៍របស់មនុស្សគ្រប់ភេទគ្រប់វ័យ ដែលត្រូវបានបំផ្លាញដោយជនល្មើសនៃអំពើជួញដូរមនុស្សដោយ ការកេងប្រវ័ញ្ច និងការរំលោភបំពានគ្រប់រូបភាពឲ្យលទ្ធផលល្អប្រសើរជាអតិបរមា»។



*លោកបូជាចារ្យ សួន ហង់ លី (ជួរក្រោយ កណ្តាល) និងសមាជិកព្រះសហគមន៍មណ្ឌលសកម្មភាពភ្នំពេញថ្មី។ ស៊ីអេសស៊ី*

យ៉ាងណាក៏ដោយសម្តេចក្រឡាហោមក៏បានអំពាវនាវឲ្យមានការចូលរួមពីសំណាក់ស្ថាប័នពាក់ព័ន្ធនានា ទាំងស៊ីវិល និងរដ្ឋាភិបាលទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សហការគ្នា និងរួមគ្នាជាមួយប្រទេសពាក់ព័ន្ធនៅក្នុងតំបន់ និងពិភព ដើម្បីទប់ស្កាត់ បង្ការ និងដោះស្រាយ។ ក្នុងនោះដែរ ពលរដ្ឋទាំងអស់ត្រូវមានការប្រុងប្រយ័ត្នខ្ពស់អំពីអំពើជួញដូរតាមរូបភាពផ្សេងៗដូចជាតាមប្រព័ន្ធបច្ចេកវិទ្យាទំនើប និងតាមប្រព័ន្ធអនឡាញផងដែរ។

ជាមួយគ្នានោះសម្តេចក្រឡាហោម ស ខេង ក៏បានបញ្ជាក់បន្ថែមទៀតផងដែរថា កម្ពុជា បាននឹងកំពុងខិតខំជម្រុញអនុវត្តគោលការណ៍ទាំងឡាយ ដែលមានចែងក្នុងកតិកាសញ្ញាពិភពលោក «ស្តីពីទេសន្តប្រវេសន៍ដោយសុវត្ថិភាព រៀបរយនិងស្របច្បាប់» ដែលហៅកាត់ថា GCM និងជំរុញបន្ថែមទៀតនូវការអនុវត្តអនុសញ្ញាអន្តរជាតិ «ស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លង ដែនដែលមានអង្គការចាត់តាំង» និងកិច្ចព្រមព្រៀងទាំងទ្វេភាគីពហុភាគីឲ្យបានម៉ឺងម៉ាត់ផង ដែរ។

លោកបូជាចារ្យ សួន ហង់លី ទទួលខុសត្រូវលើព្រះសហគមន៍មណ្ឌលសកម្មភាពភ្នំពេញថ្មី មានប្រសាសន៍ថា អំពើជួញដូរមនុស្សប្រាសចាកពីជំនឿរបស់ព្រះសហគមន៍ដែលផ្តល់តម្លៃ និងគោរពដល់ជីវិត។

លោកបូជាចារ្យបញ្ជាក់ថា៖ «គ្រីស្តបរិស័ទ គឺយកចិត្តទុកដាក់គោរពតម្លៃរបស់មនុស្ស ហើយការជួញដូរមនុស្សតាមរូបភាពណាក៏ដោយមិនថាការកេងប្រវ័ញ្ចខាងសេដ្ឋកិច្ចខាងកម្លាំងកាយ ឬកម្លាំងចិត្តក្តី គឺជារឿងមិនត្រឹមត្រូវតាមជំនឿរបស់យើង និងមិនគាប់ព្រះហឫទ័យព្រះជាម្ចាស់»។

លោកបូជាចារ្យបន្ថែមថា លោកនឹងយកសេចក្តីដែលរដ្ឋាភិបាលបានរៀបរាប់នៅក្នុងទិវានេះទៅផ្សព្វផ្សាយដល់គ្រីស្តបរិស័ទយើង ដើម្បីការពារជនចំណាកស្រុក និងយកចិត្តទុកដាក់អធិដ្ឋានសូមព្រះជាម្ចាស់ជួយបំភ្លឺណែនាំដល់ជនល្មើសឲ្យកែប្រែចិត្តគំនិត ព្រមទាំងជួយរាយការណ៍ទៅសមត្ថកិច្ចនៅពេលឃើញមានអំពើជួញដូរមនុស្ស។ លោកថា គោលនយោបាយនេះពិតជាស៊ីជាមួយគ្រីស្តបរិស័ទក្នុងការជួយដល់អ្នកទន់ខ្សោយ៕

# លោកអភិបាលប្រកាសឆ្នាំនៃការប្រកាសដំណឹងល្អ២០២០-២០២២

*ដោយ៖ ដាលីស*

លោកអភិបាលអូលីវីយេ ឝ្មិតអីស្ល័រ បានមានប្រសាសន៍ថា ក្នុងឆ្នាំ២០២០-២០២២ ព្រះសហគមន៍ភូមិភាគភ្នំពេញរួមនឹងព្រះសហគមន៍នៅតំបន់អាស៊ីនឹងធ្វើដំណើររួមគ្នាដោយផ្តោតសំខាន់លើគោលដៅរួមគឺប្រកាសដំណឹងល្អ។ ក្នុងរយៈពេល៣ឆ្នាំខាងមុខនេះ ព្រះសហគមន៍កម្ពុជាត្រូវយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការប្រកាសដំណឹងល្អ ដោយបម្រើអ្នកក្រីក្រ សន្ទនាជាមួយសាសនានានា និងរស់នៅក្នុងវប្បធម៌នៃជាតិសាសន៍របស់ប្រទេសកម្ពុជា។

លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មានប្រសាសន៍នេះ នៅក្នុងជំនួបប្រចាំឆ្នាំជាមួយក្រុមបុគ្គលិកការិយាល័យព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញទាំងអស់ នាថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៩ នៅព្រះវិហារសន្តសិលានិងសន្តប៉ូល ស្ថិតក្នុងសង្កាត់ភ្នំពេញថ្មី ក្នុងរាជធានីភ្នំពេញដែលមានអ្នកចូលរួមប្រមាណជាង៥០នាក់។

លោកអភិបាលបានរំលឹកថា សម្រាប់ ៣ ឆ្នាំខាងមុខ ការិយាល័យនីមួយៗត្រូវចូលយ៉ាងសកម្មនៅក្នុងសកម្មភាពរួម ដែលនឹងមានគឺ "រួមដំណើររួមគ្នាជាមួយប្រជាជាតិអាស៊ី" ដែលមាន ៣០ប្រទេសនៅក្នុងទ្វីបអាស៊ី ស្ថិតក្រោមអភិបាលកិច្ចរបស់ក្រុមលោកអភិបាលចំនួន១៧ប្រទេស ដើម្បីប្រកាសដំណឹងល្អ ដល់ប្រជាជនក្នុងតំបន់ ដោយយកខ្លឹមសារឯកសាររបស់សន្តសម្តេចប៉ាបយ៉ូហានប៉ូលទី២ ដែលបានណែនាំព្រះសហគមន៍នៅទ្វីបអាស៊ី ជាមូលដ្ឋានក្នុងការអនុវត្ត។ លោកមានប្រសាសន៍ក្នុងធម្មទេសនាថា អ្វីៗទាំងអស់ដែលយើងធ្វើបាន លុះត្រាតែយើងយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាប្រភពនៃកម្លាំងដួងចិត្ត ហើយអត្តទស្សនៈគឺជាអ្វីដែលចេញពីដំណឹងល្អរបស់ព្រះជាម្ចាស់។ ដូចនេះ ព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនទៅណាឆ្ងាយពីជីវិតប្រចាំថ្ងៃរបស់យើងឡើយ។

ក្នុងជំនួបនេះដែរ លោកអភិបាលបានជំរុញឲ្យការិយាល័យទាំងអស់យកចិត្តទុកដាក់ផងដែរ អំពីប្រព័ន្ធគ្រប់គ្រង និងរបៀបនៃការទំនាក់ទំនងគ្នានៅក្នុងការិយាល័យផ្ទាល់ និងជាមួយស្ថាប័នកាតូលិកនានាផងដែរ។




*សមាជិកការិយាល័យនៃព្រះហសហគមន៍នៅក្នុងភូមិភាគភ្នំពេញ។ ស៊ីអេសស៊ី*

លោកបានសង្កត់ធ្ងន់ចំនួន១០ចំណុចគឺ ១.មួយសន្ទនាជាមួយបូជាចារ្យគ្រប់មណ្ឌលសកម្មភាព។ ២. វាយតម្លៃផលប៉ះពាល់ចំពោះកិច្ចការដែលបានធ្វើ។ ៣. ធ្វើរបាយការណ៍ប្រចាំខែ។ ៤. ប្រជុំប្រចាំខែដើម្បីលើកទឹកចិត្តគ្នាទៅវិញទៅមកនិងរកដំណោះស្រាយ។ ៥. ធ្វើរបាយការណ៍ហិរញ្ញវត្ថុច្បាស់លាស់និងមានតម្លាភាព។ ៦. ចូលរួមជាមួយនឹងព្រឹត្តិការណ៍នានាដែលមាននៅក្នុងភូមិភាគភ្នំពេញ។ ៧. មានពេលវេលាដើម្បីសំណាក់ធម៌រិះគិតអំពីជំនឿ និងកិច្ចការប្រកាសដំណឹងល្អ។ ៨. បន្តធ្វើការងារដោយមានកំលាំង។ ៩. ជ្រើសរើសព័ត៌មានដែលត្រូវផ្សព្វផ្សាយនិង ១០. ថែរក្សាអត្តទស្សនៈរបស់យើង។

កិច្ចជួបជុំនេះបានធ្វើជារៀងរាល់មួយឆ្នាំក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត ដើម្បីលើកទឹកចិត្តនិងស្គាល់គ្នារវាងការិយាល័យក្នុងព្រះសហគមន៍ ដោយមានការណែនាំពីលោកអភិបាល អភិបូជា និងទទួលអាហារសាមគ្គី។

ការិយាល័យដែលបម្រើការងារឲ្យព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញដែលបានចូលរួមនៅក្នុងកម្មវិធីនេះមានដូចជា ការិយាល័យយុវជនកុមារនិងគ្រួសារ ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ការិយាល័យសុខភាព ការិយាល័យអប់រំជំនឿនិងព្រះគម្ពីរ ការិយាល័យអប់រំសិក្សា ការិយាល័យពលករ ការិយាល័យលោកអភិបាល ក្រុមស្វាគមន៍នៅភ្នំពេញថ្មី ការិយាល័យសហគ្រិនសង្គម និងការិយាល័យសិល្បៈ៕





# អគារសិក្សាថ្មីជាកូនសោរជួយអភិវឌ្ឍប្រទេស

*ដោយ៖ កែវ កញ្ញា*



*អគារសិក្សាសាលាសន្តសិលានេះនឹងមានប្រយោជន៍ច្រើនដល់កុមារក្រោមការឧបត្ថម្ភពីសំណាក់សប្បុរសជនក្រៅប្រទេស។ រូបភាព៖ សហការី*

អគារសិក្សាសាលាសន្តសិលាត្រូវបានបើកសម្ពោធឲ្យប្រើប្រាស់ជាផ្លូវការ ក្រោមអធិបតីភាពរបស់លោកគីគេ ហ្វីការេដូ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង សម្រាប់មត្តេយ្យសិក្សានិងថ្នាក់អប់រំបន្ថែមសម្រាប់សិស្សបឋមសិក្សា និងមានការចូលរួមពីសំណាក់តំណាងមន្ទីរអប់រំ មន្ទីរធម្មការនិងសាសនា អាជ្ញាធរក្នុងតំបន់ លោកគ្រូអ្នកគ្រូ និងភ្ញៀវជាតិនិងអន្តរជាតិជាច្រើនរូប ស្ថិតនៅក្នុងបរិវេណព្រះវិហារសន្តសិលានៃព្រះសហគមន៍កំពង់ឆ្នាំង ក្នុងទីរួមខេត្តកំពង់ឆ្នាំងកាលពីថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៩។

ក្នុងកម្មវិធីនេះ លោកអភិបាលគីគេ បានមានប្រសាសន៍ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់ជំនួយ វត្តមានរបស់បងស្រីនិងលោកបូជាចារ្យ និងការគាំទ្រពីរដ្ឋាភិបាលដើម្បីឲ្យព្រះសហគមន៍អាចមានសកម្មភាពនៅក្នុងខេត្តកំពង់ឆ្នាំងនេះ។ លោកអភិបាលមានប្រសាសន៍ទៀតថា សាលានេះមានសកម្មភាពជាយូរហើយ ហើយអគារសិក្សាថ្មីនេះ នឹងមានប្រយោជន៍ច្រើនដល់កុមារដែលរស់នៅក្នុងតំបន់ ហើយក៏ជួយដល់ឪពុកម្តាយដើម្បីឲ្យកូនៗរបស់ពួកគាត់ទទួលការអប់រំដែលមានករុកោសល្យល្អ។

លោកអភិបាលបានមានប្រសាសន៍ទៀតថា អគារនេះ ក៏នឹងបញ្ជាក់អំពីវត្តមានរបស់ព្រះសហគមន៍ គឺធ្វើដើម្បីប្រយោជន៍រួម មិនមែនត្រឹមតែគ្រីស្តបរិស័ទប៉ុណ្ណោះទេ គឺជួយអ្នកក្រីក្រអ្នកខ្វះខាតឲ្យមានការអប់រំនិងការីកចម្រើន ដើម្បីអនាគតនៃប្រទេសជាតិ។

លោកបញ្ជាក់ទៀតថា «បើសិនជាយើងចេះចូលរួម យើងអប់រំសម្រាប់កូនក្មេង យើងកំពុងចូលរួមកសាងសង្គមមួយ ប្រទេសជាតិដែលមានអនាគត។ យើងចង់មានអនាគត យើងត្រូវមានចំណេះដឹង។ អប់រំជាកូនសោរឲ្យយើងទៅខាងមុខ ឲ្យអភិវឌ្ឍប្រទេស»។

កម្មវិធីសិក្សារបស់សាលាសន្តសិលានេះ បានបើកជាច្រើនឆ្នាំមកហើយ ដោយមានសាលាមត្តេយ្យសម្រាប់កុមារតូចៗ។

នៅក្នុងឆ្នាំ២០១៩នេះ ដោយសារមើលឃើញនូវតម្រូវការបន្ថែមរបស់ឪពុកម្តាយកុមារ ទើបព្រះសហគមន៍សាងសង់អគារបន្ថែម និងមានកម្មវិធីសិក្សារហូតដល់ពេលរសៀល គឺរៀនចាប់ពីម៉ោង៧:៣០នាទីព្រឹក ដល់រសៀលម៉ោង៣។ ក្នុងនោះដែរក៏មានបន្ថែមនូវអាហារថ្ងៃត្រង់មួយពេលទៀតសម្រាប់កុមារ។

បងស្រីរ៉ូហ្សា ដែលជាអ្នកគ្រប់គ្រងសាលាសន្តសិលា មានប្រសាសន៍ថា សាលានេះគឺមានទិសដៅជួយសម្រួលដល់ឪពុកម្តាយកុមារ ដែលមានកិច្ចការរវល់នឹងរបរទទួលទាន។ បងស្រីរ៉ូហ្សា «កូនសិស្សក្រីក្រ ឪពុកម្តាយទុកនៅផ្ទះ អត់មានអ្នកណាជួយមើល អត់មានអ្នកណាបង្រៀន។ បំណងរបស់លោកពុក បងស្រី គឺជួយមើលថែកូនសិស្ស និងអប់រំ។ ឪពុកម្តាយគេទុកចិត្តថា គេ( កូនៗ ) រៀនចេះច្រើន»។



*ការសម្ពោធអគារសិក្សាសាលាសន្តសិលាជាផ្លូវការក្រោមអធិបតីភាពរបស់លោកគីគេ ហ្វីការេដូ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង។ រូបភាព៖ សហការី*

សាលាមត្តេយ្យនេះ បានបើកបវេសនកាលរបស់ខ្លួនកាលពីដើមខែវិច្ឆិកា ហើយដែលក្នុងនោះមានសិស្សចូលរៀនចំនួន៤៥នាក់ដែលមកពីតំបន់នានាក្នុងក្រុងកំពង់ឆ្នាំង។ អគារសិក្សានេះ បានទទួលការឧបត្ថម្ភពីសំណាក់សប្បុរសជនក្រៅប្រទេសរួមមាន សិង្ហបុរី ហុងកុង និងអ៊ីតាលី៕



*តំណាងមន្ទីរអប់រំ មន្ទីរធម្មការ និងសាសនា អាជ្ញាធរក្នុងតំបន់ លោកគ្រូអ្នកគ្រូ ក្នុងពិធីសម្ពោធអគារសិក្សាសាលាសន្តសិលា។ រូបភាព៖ សហការី*



*កូនសិស្សសាលាមត្តេយ្យដែលមកពីតំបន់នានាក្នុងក្រុងកំពង់ឆ្នាំង។ រូបភាព៖ សហការី*

# ក្រុមយុវជនស្ម័គ្រចិត្ត មួយក្រុម ចូលរួមថតសត្វស្លាបកម្រ



ចាបស៊ីរុយចិញ្ចើមស។ ក្រុមថតសត្វស្លាបកម្ពុជា

*ដោយ៖ ផល សុផានិត*

នៅក្នុងបណ្តាញសង្គមបច្ចុប្បន្ននេះវិស័យបរិស្ថានត្រូវបានចាត់ទុកថា កំពុងតែមានការយកចិត្តទុកដាក់ខ្លាំងពីសំណាក់ប្រជាពលរដ្ឋ និងសង្គម ដែលធ្វើឲ្យមានការផុសផុលឡើងនូវចលនាជាច្រើន ទាំងវិស័យ សាធារណៈ និងឯកជន ក្នុងការចូលរួមការពារនិងថែរក្សានូវប្រព័ន្ធធម្មជាតិ។

សត្វស្លាបមួយចំនួនក្នុងពេលបច្ចុប្បន្ននេះត្រូវបានក្រុមអ្នកជំនាញនៃអង្គការសង្គ្រោះសត្វព្រៃនៅកម្ពុជា ហៅកាត់ថា WCF បានចាត់ទុកថារងផលប៉ះពាល់និងជិតផុតពូជ ជាហេតុធ្វើឲ្យមានការអំពាវនាវឲ្យមានការជួយសង្គ្រោះនិងអភិរក្សជាបន្ទាន់។

ក្រុមយុវជនដែលមានគ្នា៨នាក់ ដើរថតរូបស្ទើរតែពេញ២៥រាជធានីខេត្ត ហើយបានថតរូបសត្វស្លាបបានជាង២០០ប្រភេទ សកម្មភាពនេះត្រូវបានមហាជន ជាពិសេសក្រសួងបរិស្ថានគាំទ្រនូវសកម្មភាពរបស់ពួកគេ ក្នុងការចូលរួមផ្ដិតយកទស្សនីយភាពធម្មជាតិក្នុងព្រៃជ្រៅៗ ក្នុងន័យការពារ និងចងក្រងឯកសារពីសត្វស្លាបនៅក្នុងប្រទេសកម្ពុជា ។

លោក សោម ពិសិដ្ឋ សមាជិកថតសត្វស្លាបកម្ពុជាបានថ្លែងថា «ក្រុមពួកខ្ញុំបានថតរូបសត្វស្លាបកម្ពុជា ហើយបង្កើតឡើងដោយមិត្តភក្តិដែលចូលចិត្ត ស្រលាញ់ការថតរូប ជាពិសេសគឺការថតរូបសត្វស្លាប។ ពួកខ្ញុំថតរូបប្រហែលជា៤ទៅ៥ឆ្នាំហើយមុននឹងបង្កើតក្រុម ហើយក្រុមរបស់នេះ ទើបតែបង្កើតហើយមានឈ្មោះបានជិតតែមួយឆ្នាំតែប៉ុណ្ណោះ»។

គោលដៅចម្បងនៃក្រុមថតរូបសត្វស្លាបកម្ពុជា គឺធ្វើយ៉ាងណាប្រមូលរូបភាព និងព័ត៌មានអំពីសត្វស្លាបដើម្បីចែករំលែកទៅសាធារណជន ដើម្បីឲ្យដឹងពីប្រភេទសត្វស្លាបនីមួយៗ។

លោក សោម ពិសិដ្ឋ បានបន្តថា «ពួកយើងថតរូបដើម្បីចងក្រងរូបភាព ដែលពួកយើងប្រមូលបាននឹង ទុកជាឯកសារ និងផ្សព្វផ្សាយតាមបណ្តាញសង្គមហ្វេកប៊ុកទៅឲ្យប្រជាពលរដ្ឋខ្មែរបានស្គាល់ពីសត្វស្លាបទាំងនេះដែលបាននៅក្នុងស្រុកខ្មែរ»។

សមាជិកទាំងអស់នៃក្រុមថតសត្វស្លាបនេះបានចាត់ទុកការថតរូបសត្វស្លាបគឺជាពេលវេលាលំហែកាយដ៏ល្អបំផុត នៅតាមតំបន់ធម្មជាតិនៅពេលចុងសប្តាហ៍បន្ទាប់ពីសម្រាកពីការងារ។

លោក សោម ពិសិដ្ឋ បានបន្តថា «វាហត់ពេលដែលយើងទៅ តែសំខាន់ពេលដែលយើងទៅវាបានលទ្ធផល យើងថតរូបបាន យើងចែករំលែកទៅមិត្តរួមក្រុម ព្រោះពេលដែលគាត់ចុះទៅ យើងទៅកន្លែងផ្សេងៗគ្នា យើងប្រមូលផ្តុំបានសត្វស្លាបច្រើនប្រភេទដែលយើងថតបាន»។

ចំណែកលោក ចាន់ សុផារ៉ា សមាជិកក្រុមម្នាក់ទៀតបានបន្តថា សមាជិកក្រុមរបស់ពួកគាត់គឺជាអ្នកស្គាល់គ្នា ហើយមានចំណូលចិត្តថតរូបសត្វស្លាបដូចគ្នាទាំងអស់។ លោកបានបញ្ជាក់ថា អ្វីដែលពួកគាត់ចំណាយពេលថតនោះ គឺសត្វស្លាប គឺដើម្បីបញ្ចេញនូវភាពហត់នឿយពីកន្លែងការងារប៉ុណ្ណោះ។

លោក ចាន់ សុផារ៉ា និយាយថា «ចំទៅពេលដែលថតរូបសត្វស្លាបពីមុនៗ អត់ដឹងថាសត្វនោះមានឈ្មោះអ្វីទេ ពេលដែលថតបានទៅ ឃើញសត្វនេះស្អាតចេះតែសួរគ្នា ធ្វើឲ្យយើងកាន់តែសប្បាយកាន់តែចូលចិត្តថតថែមទៀតទៅ»។

អ្នកថតរូបសត្វស្លាបមិនមែនជាអ្នកជំនាញផ្នែកសត្វស្លាបនោះទេ គ្រប់ព័ត៌មានទាំងអស់ និងប្រភេទសត្វស្លាប និងទីតាំងភូមិសាស្ត្រសត្វស្លាបនីមួយៗ ត្រូវពឹងផ្អែកទៅលើឯកសារជំនួយ និងត្រូវការមគ្គុទេសសត្វស្លាបដើម្បីផ្តល់ព័ត៌មានបន្ថែម។

លោក សោម ពិសិដ្ឋ បានថ្លែងបន្តថឲ្យដឹងទៀតថា៖ «អត្តសញ្ញាណសត្វស្លាបទាំងនោះគឺយើងពឹងផ្អែកលើឯកសារមួយចំនួនដែរ គឺមានឯកសារទាក់ទងនឹងសត្វស្លាបនៅតំបន់អាស៊ុី សត្វស្លាបនៅកម្ពុជា ឯកសារដែលគេចងក្រងមក ពីមុនៗ។ នៅពេលដែលយើងថតបាន យើងយកទៅប្រៀបធៀបជាមួយពណ៌សម្បុររបស់សត្វស្លាបនោះដើម្បីកំណត់អត្តសញ្ញាណរបស់វា»។

នៅកម្ពុជា ដែលជាជម្រកសត្វជិតផុតពូជក្នុងពិភពលោក ក្នុងបញ្ជីក្រហមរបស់អង្គការIUCN។ ក្នុងនោះសត្វកម្រ ដែលយកមកបង្ហាញរួមមានដូចជា៖ ត្រដក់ធំ ត្រយ៉ងយក្ស ត្រយ៉ងចង្កំ ក ស ត្មាត ក្ងោកទេព ដំរីអាស៊ី ទោចថ្គាល់លឿង ស្វាកន្ទុយស កន្ធាយក្បាលកង្កែប និងអណ្ដើកហ្លួង៕



**ចកវ៉ែកកំប៉ោយស។** រូបថត៖ ក្រុមថតសត្វស្លាបកម្ពុជា



**ពពិចថ្មបំពង់កស។** ក្រុមថតសត្វស្លាបកម្ពុជា



**ទទាវជើងបៃតង។** ក្រុមថតសត្វស្លាបកម្ពុជា



**សត្វក្រៀលដែលកំពុងរកស៊ីក្នុងតំបន់ការពារទេសភាពអន្លង់ព្រីង ខេត្តកំពត។** ក្រុមថតសត្វស្លាបកម្ពុជា



**សត្វទុងប្រផេះ។** ក្រុមថតសត្វស្លាបកម្ពុជា



**សត្វល្វាចេកព្រៃ។** រូបថត៖ ក្រុមថតសត្វស្លាបកម្ពុជា





# ដើម្បីបានរៀបការជាមួយមនុស្សដែលខ្លួនស្រឡាញ់ តើយុវវ័យនៅពេលបច្ចុប្បន្ន រកប្រាក់តាមរបៀបណា?

*ដោយ៖ ផល សុផានិត*

ប្រទេសជាតិនីមួយៗមានបែបផែនរៀងៗខ្លួន ក្នុងការរៀបចំអាពាហ៍ពិពាហ៍ តាមប្រពៃណីនឹងជាតិសាសន៍របស់ខ្លួន។ ការរៀបអាពាហ៍ពិពាហ៍មិនមែនជារឿងរបស់មនុស្សពីរនាក់តែវាជារឿងមួយរួមក្នុង គ្រួសារទាំងសងខាង។

យុវវ័យត្រូវបានច្បាប់អង្គការសហប្រជាជាតិចាត់ទុកក្នុងកម្រិតអាយុ ចាប់ពី១៨ឆ្នាំ ដល់៣៥ឆ្នាំ។ ក្នុងជីវិតជាយុវវ័យ ត្រូវឆ្លងកាត់រឿងរ៉ាវមួយចំនួនធំ ប្លែកៗទៅតាមតួអង្គនីមួយ។ ដោយឡែកការរៀបការ ទៅតាមប្រពៃណីរបស់ព្រះរាជាណាចក្រកម្ពុជា ពិតជាចាំបាច់ក្នុងការចំណាយច្រើន។

ដើម្បីបានរៀបការជាមួយមនុស្សដែលខ្លួនស្រឡាញ់ តើយុវវ័យនៅពេលបច្ចុប្បន្ននេះ រកប្រាក់តាមរបៀបណា ក្នុងការចាត់ចែងទាំងផ្លូវច្បាប់ និងតាមប្រពៃណី?

ជាគ្រូគណិតវិទ្យាថ្នាក់ទី១២ នៃវិទ្យាល័យជាស៊ីម សន្ធរម៉ុក លោក ប៉ូ វិចិត្រ បានអោយយើងដឹងថា នៅពេលដែលបញ្ចប់នៅរដូវកាលបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែររួច សឹងតែនៅទូទាំងប្រទេសកម្ពុជា តែងតែចំណាំថារដូវរៀបអាពាហ៍ពិពាហ៍ របស់កូនចៅប្រុសស្រីនឹងចូលមកដល់ ច្បាស់ណាស់នឹងនៅតាមគ្រប់ភូមិស្រុក តាមដងផ្លូវ ច្បាស់ជាមានការសាងសង់រោងការជាមិនខាន។

លោក ប៉ូ វិចិត្រ បានអោយដឹងថា ចំពោះរូបគាត់ផ្ទាល់ គាត់បានសន្សំប្រាក់ខែពាក់កណ្តាលរបស់គាត់ជាមួយអនាគតភរិយាជាមួយគ្នាដើម្បីរៀបចំពិធីមង្គលការ។ វិចិត្របានប្រាប់ទៀតថា ពួកគាត់ទាំងពីរនាក់សន្សំរយៈពេល៥ឆ្នាំទើបមានប្រាក់គ្រប់គ្រាន់។

លោក វិចិត្រ បានរៀបមង្គលការ ក្នុងឆ្នាំ២០០៥ និយាយថា៖ «ការរៀបមង្គលការរបស់ខ្ញុំតាមបែបសាមញ្ញ ខ្ញុំគ្រាន់តែដឹងថា ខ្ញុំបានឲ្យលុយ៨០០០ដុល្លា ទៅម្តាយក្មេកខ្ញុំដើម្បីចាត់ចែងក្នុងមង្គលការតែប៉ុណ្ណោះ»។

បើតាមការរៀបអាពាហ៍ពិពាហ៍ក្នុងប្រទេសកម្ពុជា បច្ចុប្បន្ននេះ គេតែងតែប្រារព្ធក្នុងរយៈពេល ត្រឹមតែ២ថ្ងៃ ដោយធ្វើការកាត់បង្រួម។ ការរៀបការនេះត្រូវស្ថិតនៅក្នុងការរៀបចំឡើង នៅផ្ទះរបស់កូនក្រមុំ។ ការចំណាយទៅលើពិធីមង្គលការគឺមានចំនួនច្រើនសន្ធឹកសន្ធាប់ទៅតាមលទ្ធភាពនិងការចង់បានរបស់គ្រួសារទាំងសងខាង។

លោក ប៉ូ វិចិត្រ បានបន្តថា ការរៀបការក្នុងពេលបច្ចុប្បន្ននេះគេហាក់ឃើញថាមានការប្រារព្ធឡើង ដោយធ្វើការចំណាយយ៉ាងច្រើនទៅលើ ផ្ទូង ចុងភៅ ភ្លេងការស្ទុតែរបស់ថ្លៃៗ និមន្តលោកក្នុងការសូត្រមន្ត សុទ្ធតែលំដាប់ខ្ពស់ហាក់បង្អួតគ្នា ដោយមិនគិតទៅលើ លទ្ធភាពដែលខ្លួនមាននោះទេ។

លោក ប៉ូ វិចិត្រ បានបន្តថា៖ «ការរៀបការដោយគ្មានផែនការហិរញ្ញវត្ថុច្បាស់លាស់នោះ នៅទីចុងបញ្ចប់ ក្រខ្លួនឯងមួយកំណាត់ជីវិត ប្រសិនបើអ្នកដែលមានលុយ មន្ត្រី ឧញ៉ា ធ្វើបែបនេះគេអាចធ្វើបាន ដោយគេមានលទ្ធភាព តែបើអ្នកមធ្យម អ្នកក្រ ការកូនបានរួចខ្លួន អរទៅ តែបើអ្នកក្រការកូននោះសង្ឃឹមថា នឹងខាត១០០ភាគរយ»។

ចំណែក អ្នកនាង គន សុធីតា ដែលបានរៀបអាពាហ៍ពិពាហ៍កាលពីឆ្នាំ២០១៦កន្លងទៅ បានអោយដឹងថា ការរៀបការរបស់អ្នកនាង បានធ្វើឡើងដោយសារតែប្រាក់ថ្លៃបណ្តាការ ដែរបានមកពី ខាងកូនកម្លោះតែប៉ុណ្ណោះ។

អ្នកនាង គន សុធីតា បានបន្តថា ប្រាក់បណ្តាការនោះ បានមកពីការផ្តល់អោយដោយឪពុកម្តាយក្មេក របស់អ្នកនាង ទៅកាន់ស្វាមី និងបន្ថែមពីប្រាក់ខែដែលស្វាមីរបស់អ្នកនាងសន្សំ។

រីឯ លោក អៀ វិទូ ជាបុគ្គលិកក្រុមហ៊ុន ផ្គត់ផ្គង់អ៊ីនធឺណែត ក្នុងរាជធានីភ្នំពេញ បានអោយដឹងថា នៅពេលដែលលោករៀបការជាមួយភរិយារបស់លោកកាលពីឆ្នាំ ២០១៥ ប្រាក់ដែលយកទៅចំណាយក្នុងពេលរៀបមង្គលការបានមកពីប្រាក់សន្សំនៃប្រាក់ខែប្រចាំខែរបស់លោក។

បុគ្គលិកក្រុមហ៊ុនផ្គត់ផ្គង់អ៊ីនធឺណែត រូបនេះបានអោយដឹងថា៖ «ខ្ញុំបានសន្សំលុយ ៥០ភាគរយនៃប្រាក់ខែ ដើម្បីយកទៅរៀបការជាមួយ ប្រពន្ធខ្ញុំ និងបន្ថែមបន្តិចបន្តួចពីឪពុកម្តាយតែប៉ុណ្ណោះ»។

លោក សំ សុខណា ជាបុគ្គលិកផ្នែកឥណទាន នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មួយក្នុងក្រុងភ្នំពេញ បានអោយយើងដឹងថា៖ «មិនថាធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បើកកម្ចី អោយគូស្វាមីភរិយា កូនកម្លោះកូនក្រមុំ ទៅខ្ចីលុយការ ក្នុងកម្រិតការប្រាក់ក្នុង១ខែ ១,៦ភាគរយ ហើយបច្ចុប្បន្នទាំងម្តាយនឹងឪពុក កូនកម្លោះ កូនក្រមុំកំពុងតែពេញនិយម អត់មានលុយការកូនទេ តែទៅខ្ចីលុយគេមករៀបការ»។

បុគ្គលិកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរូបនេះ បានបន្តថា នៅសព្វថ្ងៃនេះ សេវាកម្មអាពាហ៍ពិពាហ៍របស់ធនាគារគឺផ្តល់អោយគូរស្វាមីភរិយា ដូចៗគ្នា ដោយគ្រាន់តែគូរស្វាមីភរិយា មានប្រាក់ខែ និងប្រាក់ចំណូលច្បាស់លាស់ តែប៉ុណ្ណោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នឹងផ្តល់កម្ចីសម្រាប់អាពាហ៍ពិពាហ៍ជូន។

ថ្វីដ្បិតតែយុវជនភាគច្រើនសុទ្ធតែអះអាងថាពួកគេត្រូវមានការងារធ្វើ អាចរកសន្សំប្រាក់ដោយខ្លួនឯងបាន ដើម្បីចំណាយលើការរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែពួកគេក៏ទទួលស្គាល់ថា នេះជាបន្ទុកដ៏ធ្ងន់ធ្ងរមួយដែរ។ យ៉ាងហោចណាស់ ពួកគេត្រូវការចំណាយពេលវេលាសាកសមដើម្បីអាចធ្វើការសន្សំថវិកាបាន៕



# ផ្ទេរមុខងារបូជាចារ្យ ទទួលខុសត្រូវ ព្រះសហគមន៍ លើទឹកដីត្បូងពេជ្រ

ដោយ៖ លី សុវណ្ណា



(ឆ្វេង) លោកបូជាចារ្យ យ៉ូសែប មួង រស់ លោកអភិបាល គីគេ ហ្វីការេដូ និង លោកបូជាចារ្យ កាឡូស។ រូបភាព៖ លី សុវណ្ណា



ព្រះវិហារ ព្រះបេះដូងព្រះយេស៊ូនៃក្រុងប៉ៃលិន។ រូបភាព៖ លី សុវណ្ណា

ព្រះសហគមន៍កាតូលិកប៉ៃលិន ព្រះវិហារព្រះបេះដូងព្រះយេស៊ូ ប្រារព្ធពិធីផ្លាស់ប្តូរមុខងារលោកបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍កាតូលិក នៅជាប់ព្រំដែនខ្មែរថៃមួយនេះ កាលពីថ្ងៃទី១ វិច្ឆិកា ២០១៩។

លោកបូជាចារ្យ យ៉ូសែប មួង រស់ យុវជនជាតិកម្ពុជា ដែលបានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យកាតូលិក ក្នុងឆ្នាំ២០១៤ ក្នុងភូមិភាគបាត់ដំបង ហើយលោកអភិបាលព្រះសហគមន៍ភូមិភាគនេះបានចាត់លោកឲ្យទទួលខុសត្រូវព្រះសហគមន៍ចំនួន២ គឺព្រះវិហារសន្តប៉ូល ( ស្ទឹង) ក្នុងខេត្តបាត់ដំបង និងព្រះវិហារ ព្រះបេះដូងព្រះយេស៊ូនៃក្រុងប៉ៃលិន។

តាមប្រសាសន៍របស់លោក គីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ឲ្យបញ្ជាក់ចំពោះមុខបងប្អូនគ្រីស្តបរិស័ទក្នុងពិធីអភិបូជាថា ក្នុងរយៈប៉ុន្មានឆ្នាំមកនេះ លោកបូជាចារ្យយ៉ូសែប មួង រស់ បានខិតខំអស់ពីសមត្ថភាពក្នុងការណែនាំ ព្រមទាំងបម្រើព្រះសហគមន៍នៅប៉ៃលិន និងស្ទឹង សម្រាប់ភូមិភាគបាត់ដំបង ក៏ដូចជាការបម្រើព្រះសហគមន៍អន្តរភូមិភាគផងដែរ គឺកម្មវិធីយុវជន ព្រះសហគមន៍កាតូលិក។ លោកអភិបាលបន្តថា លោកឪពុករស់មានគំរូល្អ និងមានចិត្តសុភាពរាបសា។

លោកអភិបាលបានអរគុណលោកឪពុករស់ ចំពោះកិច្ចការបម្រើកន្លងមក ព្រមបានប្រកាសចាត់លោកឲ្យទៅរៀនបន្តនៅប្រទេសហ្វីលីពីន។ ជាមួយគ្នានេះដែរ លោកអភិបាលបានប្រកាសថា លោកបូជាចារ្យ កាឡូស ដែលមកពីប្រទេសកូឡុំប៊ីនៃក្រុមសាសនទូតយ៉ារ៉ូម៉ាល់ នឹងទទួលខុសត្រូវបន្តលើព្រះវិហារនៅប៉ៃលិន និងស្ទឹង ហើយបានអនុញ្ញាតឲ្យលោកបូជាចារ្យកូឡូស ស្នាក់នៅក្នុងព្រះវិហារប៉ៃលិនផងដែរ។

លោកអភិបាលក៏បានផ្តាំផ្ញើដល់គ្រីស្តបរិស័ទ បងប្រុស បងស្រី ឲ្យយកចិត្តទុកដាក់ថែរក្សារូបនេះផងដែរ។ លោកបន្តថា៖ «នេះជាលើកទីមួយដែលមានបូជាចារ្យមកស្នាក់ផ្ទាល់នៅព្រះវិហារប៉ៃលិននេះ។សូមជួយថែរក្សាលោក ដើម្បីឲ្យគាត់ នៅបម្រើបងប្អូនបានយូរអង្វែង»។

ព្រះសហគមន៍កាតូលិកនៅខេត្តប៉ៃលិនបានចាប់ផ្តើមពីដំបូងជាមួយប្រាំបីគ្រួសារដែលបានធ្វើចំណាកស្រុកមកពីខេត្តបាត់ដំបងក្រោយពេល សមាហរណកម្មឈប់បាញ់ រវាងខ្មែរក្រហម និងកងកម្លាំងរាជរដ្ឋាភិបាល ក្នុងឆ្នាំ ១៩៩៦ ។

សូមបញ្ជាក់ថា ខេត្តប៉ៃលិនជាមូលដ្ឋានដ៏រឹងមាំ របស់ខ្មែរក្រហម និងជាស្រុកមួយក្នុងខេត្តដំបងក្នុងសម័យសង្គ្រាម។ ដំបូងឡើយព្រះសហគមន៍បានជួលផ្ទះដើម្បីជួបជុំគ្នា ហើយបន្តិចម្តងៗក៏បានរៀបចំឲ្យមានដីធ្លី និងកសាងព្រះវិហារមួយឡើង ព្រមទាំងអាគារនានា សម្រាប់សកម្មភាពព្រះសហគមន៍កាតូលិករហូតដល់សព្វថ្ងៃ៕



## សម្តេច ប៉ាប ហ្វ្រង់ស៊ីស្កូ ចំពោះយុវជន

«យុវជនជាទីស្រឡាញ់ ដើម្បីរក្សាភ្លើងវិញ្ញាណឱ្យនៅឆេះ កូនត្រូវបើកភ្នែកនិងបញ្ចេះបេះដូងរបស់កូន ហើយត្រូវចាក់ឫសនៃជំនឿដូចបព្វការីជន គឺដូចឪពុកម្តាយ ជីដូនជីតា និងគ្រូរបស់កូន។ មិនដូច្នេះទេ កូននឹងជាប់គាំងក្នុងអតីតកាល ហើយកូនត្រូវរៀនស្វែងរកភាពក្លាហាន ដែលអាចជួយយើងឆ្លើយតបនូវហេតុការថ្មីៗបាន»។







កុមារ និងយុវជននៅក្នុងតំបន់ដែលកំពុងរៀនក្នុងថ្នាក់បំប៉នភាសាបរទេស។ រូបភាព៖ សហការី



សិស្សតូចៗកំពុងទទួលបានការសិក្សាក្នុងថ្នាក់បំប៉ន។ រូបភាព៖ សហការី

# ព្រះសហគមន៍បើកថ្នាក់បំប៉នភាសាបរទេស

ដោយ៖ ហៀម សុកខុន

ជាង១០ឆ្នាំមកហើយ ក្រោមគំនិតផ្តួចផ្តើមរបស់លោកបូជាចារ្យលូកា បូឡេល្លី បានបង្កើតនូវមណ្ឌលព្រះសហគមន៍កាតូលិកក្រូចឆ្មារ ដើម្បីផ្តល់ចំណេះដឹងបន្ថែមដល់កុមារនិងយុវជននៅក្នុងតំបន់ ដែលកំពុងរៀននៅថ្នាក់ទី១ដល់ទី៨ ជាង៥០នាក់ជារៀងរាល់ថ្ងៃចន្ទ ដល់សុក្រ។

កញ្ញា ឌី សុខលី ជាអ្នកទទួលខុសត្រូវ នឹងជាគ្រូបង្រៀនភាសារអង់គ្លេសបាននិយាយថា នេះជាកិច្ចការប្រកាសដំណឹងល្អមួយ ដែលព្រះសហគមន៍ចង់មានទំនាក់ទំនងជាមួយនឹងកុមារនិងយុវជនឯទៀតដែលមិនមែនជាគ្រីស្តបរិស័ទ ហើយម៉្យាងទៀត ព្រះសហគមន៍ក៏ចង់ផ្តល់នូវចំណេះដឹងបន្ថែមទៀតដល់ពួកគាត់ ក្រៅពីម៉ោងសិក្សានៅសាលារដ្ឋ។

សុខលី បានបន្តថា កុមារនិងយុវជនមិនមែនរៀនភាសាបរទេសតែមុខនោះទេ ព្រះសហគមន៍ក៏បញ្ចូលមេរៀនភាសារខ្មែរ គណិត សិល្បៈ និងបង្រៀនពីរបៀបរស់នៅ ក៏ដូចជាការធ្វើអនាម័យខ្លួនប្រាណប្រចាំថ្ងៃដែរ។

មណ្ឌលព្រះសហគមន៍ក្រូចឆ្មារនេះ មានសិស្សមកសិក្សាចំនួន៥០នាក់ និងមានគ្រូបង្រៀនចំនួន៣នាក់។ មណ្ឌលនេះ ស្ថិតនៅ ភូមិក្រូចឆ្មារ ឃុំក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កម្មវិធីវគ្គសិក្សានេះបង្កើតឡើងជាង១០ឆ្នាំមកហើយ ដោយ លោក បូជាចារ្យ លូកា បូឡេល្លី៕





សកម្មភាពមណ្ឌលព្រះសហគមន៍ក្រូចឆ្មារដែលបច្ចុប្បន្នមានសិស្សមកសិក្សាចំនួន៥០នាក់ និងមានគ្រូបង្រៀនចំនួន៣នាក់។ រូបភាព៖ សហការី

# ព្រះសហគមន៍ផ្តល់កន្លែង ស្នាក់នៅសម្រាប់ជនជាតិភាគតិច

ដោយ៖ ហៀម សុកខុន

ព្រះសហគមន៍រតនគិរីបានទទួលយុវជនជនជាតិដើមភាគតិចទំពួនចំនួន១០នាក់ឲ្យបន្តការសិក្សានៅទីរួមខេត្តនៅថ្នាក់អនុវិទ្យាល័យ និងវិទ្យាល័យ ដោយផ្តល់កន្លែងស្នាក់នៅ អាហារ និងប្រាក់ឧបត្ថម្ភមួយចំនួនជារៀងរាល់ខែ។

បងស្រី ញឹប សុខនី ជាអ្នកទទួលខុសត្រូវមណ្ឌលស្នាក់នៅនេះ មានប្រសាសន៍ថា ព្រះសហគមន៍រៀបចំឲ្យមានកម្មវិធីនេះឡើង ដើម្បីជួយដល់សង្គម លើកតម្លៃសេចក្តីថ្លៃថ្នូររបស់មនុស្ស ក៏ដូចជាការប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់ផងដែរ។ បងស្រីបន្តថា យុវជនដែលព្រះសហគមន៍បានផ្តល់កន្លែងស្នាក់នៅ ភាគច្រើនចេញមកពីគ្រួសារក្រីក្រនិងរស់នៅឆ្ងាយៗពីសាលា ហើយមានបំណងចង់បន្តការសិក្សា។



យុវជនយុវនារីបន្តការសិក្សា និងស្នាក់នៅដោយព្រះសហគមន៍ផ្តល់ឱ្យ។

បងស្រីសុខនី បន្តថា គ្រួសាររបស់សិស្សានុសិស្សទាំងនេះតម្រូវឲ្យបង់ប្រាក់ឧបត្ថម្ភចំនួនប្រាំម៉ឺនរៀល និងអង្ករ២០គីឡូក្នុងមួយខែ ដើម្បីចូលរួមចំណែកក្នុងការចំណាយប្រចាំថ្ងៃរបស់ពួកគាត់ រីឯមណ្ឌលមានភារៈកិច្ចចំណាយ ទៅលើអាហារ ថ្លៃរៀនគួរបន្ថែម និង កន្លែងស្នាក់នៅជាដើម។

បងស្រីបានឲ្យដឹងទៀតថា ក្រៅពីមណ្ឌលនៅខេត្តរតនគិរី នៅខេត្តស្ទឹងត្រែងក៏មានមណ្ឌលមួយទៀតដែរ ដែលបងស្រីកំពុងទទួលខុសត្រូវជាមួយលោកបូជាចារ្យ កាំប៉ាញ៉ា អ៊ីវ៉ាន់ ដែលមានសិស្សស្នាក់នៅចំនួន ១០នាក់ផ្សេងទៀត។

មណ្ឌលយុវជនកាតូលិកបានឡុងស្ថិតនៅ ភូមិ២ ឃុំបានឡុង ស្រុកបានឡុង ខេត្តរតនគិរី៕



យុវជនជនជាតិដើមភាគតិចទំពួនដែលស្នាក់នៅក្នុងមណ្ឌល។ រូបភាព៖ សហការី


*កម្មការិនីកាត់ដេរកំពុងបំពេញការងាររៀងខ្លួន។ ការបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធអាចជះឥទ្ធិពលខ្លាំងដល់វិស័យកាត់ដេរ។ រូបភាព៖ ស៊ីអេសស៊ី*


*ស្រូវអង្ករត្រូវបាននាំចេញមួយផ្នែកផងដែរទៅកាន់ប្រទេសក្នុងទ្វីបអឺរ៉ុប។ រូបភាព៖ សហការី*


*ក្រៅពីផលិតផលក្នុងវិស័យកាត់ដេរមាននៅមានកៅស៊ូ ម្រេច ត្រូវបាននាំចេញទៅកាន់អឺរ៉ុបផងដែរ ។ រូបភាព៖ សហការី*

# ការព្រួយបារម្ភរឿងបាត់ប្រព័ន្ធអនុគ្រោះពីអឺរ៉ុបនៅតែមាន ប៉ុន្តែពលរដ្ឋខ្លះហាក់មានជំនឿចិត្តលើអាជ្ញាធរ

**សម្រាប់ប្រជាពលរដ្ឋជាបញ្ញាជននៅក្នុងស្រុកគឺមានការព្រួយបារម្ភពិតមែន អំពីការបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជកម្មដែលផ្ដល់ឱ្យដោយសហភាពអឺរ៉ុប ចំពោះកម្ពុជា ស្របពេលដែលអ្នកខ្លះជាពិសេសអ្នកនៅស្រែទាប់ពលរដ្ឋសាមញ្ញ មិនចាប់អារម្មណ៍ពីរឿងនេះ ប៉ុន្តែខ្លះទៀតគឺមានជំនឿទៅលើចំណាត់ការ និង វិធានការដោះស្រាយរបស់មន្ត្រីជំនាញនៅក្នុង ការឆ្លើយតបនឹងបញ្ហា។**

*ដោយ៖ អរិយបុត្រ*

បន្ទាប់ពីមានការបែកធ្លាយនូវព័ត៌មានស្ដីអំពីរបាយការណ៍ចុងក្រោយកម្រាស់ប្រមាណជា ៧០ទំព័រ តាមរយៈវិទ្យុអាស៊ីសេរីកាលពីប៉ុន្មានថ្ងៃនេះ លោក ចេង មុនី ដែលជាបញ្ញវន្តវ័យ ៣៧ឆ្នាំមួយរូបបានចែករំលែកនូវការយល់ឃើញរបស់លោកនៅក្នុងនាមជាប្រជាពលរដ្ឋមួយរូបថា វាមិនមែនជារឿងលេងសើចទេ បើនិយាយអំពីតម្លៃនៃការអនុគ្រោះពន្ធពាណិជ្ជកម្មដែលសហភាពអឺរ៉ុបផ្ដល់មកឲ្យកម្ពុជារហូតមកដល់ពេលបច្ចុប្បន្ននេះ ហើយអ្នកជំនាញរបស់រាជរដ្ឋាភិបាលក៏មិនត្រូវព្រងើយកណ្ដើយនឹងចំណុចនេះដែរ ។

លោកបញ្ជាក់ថា៖ «ការនាំចេញ៧ទៅ ៨ពាន់លានដុល្លារនៅក្នុងមួយឆ្នាំទៅអឺរ៉ុប វាជាចរន្តសេដ្ឋកិច្ចដ៏មហាសាល និង ជាឆ្អឹងខ្នងរស់នៃសេដ្ឋកិច្ចកម្ពុជាដ៏ចំបង ដូច្នេះខ្ញុំសង្ឃឹមថារាជរដ្ឋាភិបាល និងអ្នកជំនាញមិន មើលស្រាលធ្វេសប្រហែសរឿងនេះ នោះទេ»។

លោកបានបន្តទៀតថា សព្វថ្ងៃនេះ រោងចក្រជាង ១០០០ កន្លែងនៅទូទាំងប្រទេស កម្មករជិត ១លាននាក់ និងអ្នកដែលជាប់ពាក់ព័ន្ធមានដូចជាគ្រួសារកម្មករ និងកម្មការនី អ្នករត់ឡានដឹកជញ្ជូនកម្មករ អ្នកលក់បាយម្ហូប រហូតដល់លក់គ្រឿងតុបតែងខ្លួន ខោអាវ គឺរស់ដោយសារតែចំណូលពីវិស័យកាត់ដេរ ដែលភាគច្រើននៃទីផ្សារនាំចេញគឺសហភាពអឺរ៉ុបនេះ ចំបង។

លោក ជិន ជាសេដ្ឋា ដែលជាប្រជាពលរដ្ឋមានវ័យ៤៤ ឆ្នាំ ក៏បានបន្ថែមថា ការព្រួយបារម្ភនោះ គឺមិនមែនត្រឹមតែវិស័យកាត់ដេរប៉ុណ្ណោះទេ សូម្បីតែផលិតផលកសិកម្ម ដូចជា អង្ករ ម្រេច ស្ករ និង ផលិតផលមួយចំនួនទៀតក៏កំពុងតែព្រួយបារម្ភផងដែរ ពីព្រោះតែទីផ្សារធំរបស់ទំនិញកម្ពុជាគ្រប់ប្រភេទ គឺនៅអឺរ៉ុប។

អ្នកដឹកនាំស្ថាប័នហិរញ្ញវត្ថុមួយរូបដែលសុំមិនបញ្ចេញអត្តសញ្ញាណក៏បានបង្ហាញនូវក្ដីព្រួយបារម្ភអំពី ការគម្រាមកំហែងពីសហភាពអឺរ៉ុប ដែលយកប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម នេះមកដាក់សំពាធមកលើ អាជ្ញាធរកម្ពុជាផងដែរ។

លោកបានអះអាងបន្ថែមទៀតថា លោកមានក្ដីសង្ឃឹមចំពោះ រាជរដ្ឋាភិបាលកម្ពុជានឹងមិនបណ្ដោយឲ្យការអនុគ្រោះនេះបាត់បង់ឡើយ ពីព្រោះតែការបាត់បង់នេះ អ្នកពិបាកជាងគេនោះមិនមែនមានតែកម្មករ កម្មការិនីរោងចក្រ និងអ្នកដែលទទួលផលពីវិស័យកាត់ដេរដោយប្រយោលប្រហែលជា ជិត២ លាននាក់នោះទេ សូម្បីតែស្ថាប័នហិរញ្ញវត្ថុក៏មានបញ្ហាដែរ។

លោកបាននិយាយថា៖ «នៅក្នុងមួយខែៗសាច់ប្រាក់ដែលចាក់ចូលសេដ្ឋកិច្ចដោយសារតែវិស័យកាត់ដេរ និងរោងចក្រនានា មានជាង ២០០ លានដុល្លារ ដូច្នេះតម្លៃនោះវាធំណាស់ ចុះបើរោងចក្របិទ ដោយសារមិនអាចប្រកួតប្រជែងបានពេលដែលគ្មាន EBA ( អ៊ីប៊ីអេ) នេះ?»។


*ផលិតផលម្រេចខេត្តកំពត ។ រូបភាព៖ សហការី*

លោកបានបន្តថា នេះគឺជាសាច់ប្រាក់ខែសុទ្ធដែលកម្មករ និងកម្មារិនីរោងចក្រទទួលបាន ចុះនៅអត្ថប្រយោជន៍ផ្សេងៗទៀត រាប់ទាំងពន្ធ ដឹកជញ្ជូន ...។ល។

លោកបានបន្តថា ដោយសារតែចរន្តសាច់ប្រាក់ទាំងនេះហើយបានវាបន្តហូរចែកចាយទៅវិស័យផ្សេងៗទៀត ដូចជា សេវាកម្ម អាជីវកម្មលក់រាយ ព្រមទាំងហិរញ្ញវត្ថុ ដែលនាំឲ្យពលរដ្ឋយើង មានថវិការ បង់កម្ចី ក្រោយពីពលរដ្ឋទៅស្វែងរកឥណទានទិញផ្ទះ សាងសង់ផ្ទះ ទិញនេះ ទិញនោះ ទិញម៉ូតូ ដែលសព្វថ្ងៃនេះ កំពុងតែពេញនិយម គឺសេវាបង់រំលោះផ្សេងៗនោះ។

លោកស្រី ជុំ កុម្ភៈ ដែលជាអ្នកលក់មីឆាតាមរទេះរុញមួយរូប បាននិយាយដោយស្មោះត្រង់ថា លោកស្រី មិនដឹងអ្វីនោះជាប្រព័ន្ធអនុគ្រោះការនាំចេញស្អីទេ គឺដឹងតែបើកភ្នែក ដុសលាងរទេះ ចានឆ្នាំង ខ្ទះ ហើយរៀបចំតុ កៅអីដាក់រទេះចប់ហើយយប់ដេកតែប៉ុណ្ណោះ។

ជុំវិញក្ដីបារម្ភនេះ លោកក៏មានក្ដីសង្ឃឹមផងដែរថា រាជរដ្ឋាភិបាល និងអ្នកជំនាញខាងសេដ្ឋកិច្ចគឺពិតជាបានរិះរកមធ្យោបាយរួចហើយ រឿងនេះពីព្រោះតាំងពីគម្រាមមកដល់ពេលនេះ គឺជាងមួយឆ្នាំ។ ហើយចាប់ពីពេលនេះរហូតដល់ គេប្រកាសថា ផ្ដាច់ឬមិនផ្ដាច់នៅខែកុម្ភៈ ឆ្នាំក្រោយទៀតនោះ ចឹងក៏នៅមានពេលរិះរកវិធានការថែរក្សាការពារ ឬ ក៏រិះរកការទប់ទល់ និងទ្រទ្រង់សភាពការណ៍សេដ្ឋកិច្ចបានហើយ។

ជាការពិត នេះគឺជាការព្រួយបារម្ភរបស់ប្រជាពលរដ្ឋ ពីព្រោះមកដល់ពេលនេះ ទីផ្សារនាំចេញធំបំផុតរបស់កម្ពុជាគឺសហភាពអឺរ៉ុប បន្ទាប់មកមានអាមេរិក ហើយក៏មានចិន ជប៉ុន អឺរ៉ុបខាងកើត អាស៊ាន និង ប្រទេស មួយចំនួនទៀតដែរ។ ការនាំចេញទៅអឺរ៉ុបនាពេលនេះ ត្រូវបានគេដឹងថា គឺកំពុងតែស្ថិតនៅក្រោមប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជកម្ម ដែលគេហៅថា «គ្រប់មុខទំនិញលើកលែងតែសព្វាវុធ» ដែល សឹងតែគ្រប់គ្នានៅពេលនេះស្គាល់យ៉ាងច្បាស់ថា ជា អ៊ីប៊ីអេ (EBA)។ ការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារអឺរ៉ុបនៅពេលនេះមាននៅក្នុងរង្វង់ប្រមាណជា ៤០ ភាគរយ ហើយទំនិញគឺគ្រប់ប្រភេទ រាប់តាំងពីផលិតផលកសិកម្មមានស្រូវ ម្រេច រហូតដល់សំលៀកបំពាក់ព្រមទាំងកង់ជាដើម។

គួររំលឹកថា សហភាពអឺរ៉ុបបានចាប់ផ្ដើមយកប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម អ៊ីប៊ីអេ នេះ មកដាក់គំនាបកម្ពុជា គឺចាប់តាំងពីអាជ្ញាធរកម្ពុជា បានចាប់ខ្លួនលោក កឹម សុខា កាលពីចុងឆ្នាំ២០១៧ ដែលកាលនោះ លោកជាប្រធានគណបក្សសង្គ្រោះជាតិ ហើយក្រោយការចាប់ខ្លួន តុលាការកំពូលក៏បានសម្រេចរំលាយគណបក្សដែលលោកដឹកនាំចោល និងបានចេញបម្រាមនូវមេដឹកនាំគណបក្សនេះ ចំនួន ១១៨នាក់ មិនឲ្យធ្វើនយោបាយ។ ហើយចាប់តាំងពីពេលនោះមក ក្រុមអ្នកនយោបាយមួយចំនួនក៏បានភៀសខ្លួន ចេញទៅក្រៅប្រទេស ហើយមួយចំនួនក៏គោរពតាមការសម្រេចរបស់តុលាការកំពូល។ ចាប់តាំងពីពេលនោះមក សហភាពអឺរ៉ុប ក៏ចាប់ផ្ដើមយកបញ្ហាប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជកម្មនេះមកដាក់សំពាធ លើអាជ្ញាធរកម្ពុជាជាបន្តបន្ទាប់រហូតដល់បច្ចុប្បន្ន។ ហើយថ្មីៗនេះ ក្រោយពេលដែលអាជ្ញាធរបាន ចាត់វិធានការណ៍សន្តិសុខរឹងមាំប្រឆាំងនឹងចលនា និងយុទ្ធនាការប្រឆាំងនឹងក្រុមអ្នកនយោបាយនិរទេសខ្លួន ដែលបានប៉ុនប៉ងត្រឡប់មកវិញ ដោយកម្លាំងមហាជន កាលពីថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ដែលអាជ្ញាធរហៅនិងបានចាត់ទុកសកម្មភាពនយោបាយនោះថា ជាចលនាឧទ្ទាមកម្មនោះ សហភាពអឺរ៉ុប ក៏បានចេញនូវរបាយការថ្មីមួយទៀត កាលពីថ្ងៃទី១២ ខែ វិច្ឆិកា ឆ្នាំ២០១៩ ដោយប្រកាសថា ការសម្រេចពិតប្រាកដនូវជោគវាសនា ប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជកម្មនេះនឹងអស់នៅក្នុងរង្វង់ខែ កុម្ភៈ ឆ្នាំ ២០២០ ខាងមុខ។

សារព័ត៌មានទូទៅបានទទួលភាគច្រើនត្រឹមតែជាសេចក្ដីប្រកាសព័ត៌មាន កម្រាស់មួយទំព័រប៉ុណ្ណោះ ដែលទាក់ទិននឹងរបាយការណ៍ចុងក្រោយទាក់ទិននឹងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មពីសហភាពអឺរ៉ុបនេះ ពោលមានតែវិទ្យុអាស៊ីសេរី មួយប៉ុណ្ណោះដែលអះអាងថា មានរបាយការណ៏កម្រាស់៧០ ទំព័រនោះ ប៉ុន្តែឆ្លើយតបនឹងសេចក្ដីរាយការណ៍អំពីរបាយការណ៍ដែលខ្លួនទទួលបាននោះ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិក៏បានចេញសេចក្ដីថ្លែងការមួយផ្ដោលទោសសេចក្ដីរាយការណ៍ព័ត៌មានរបស់ វិទ្យុដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិកមួយនេះ។

ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ បានប្រកាសថា អនុលោមតាមនីតិវិធី គណៈកម្មការអឺរ៉ុបបានបញ្ជូនមករាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៩ នូវរបាយការណ៍បឋមរបស់ខ្លួនអំពីការវាយតម្លៃពាក់ព័ន្ធនឹងប្រព័ន្ធអនុគ្រោះពន្ធ ពាណិជ្ជកម្ម«គ្រប់មុខទំនិញលើកលែងសព្វាវុធ-EBA» ដែលរាជរដ្ឋាភិបាលកម្ពុជានឹងត្រូវផ្ដល់យោបល់ទៅលើរបាយការណ៍នេះក្នុងកំឡុងពេលមួយខែ។ក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងធ្វើការពិនិត្យរបាយការណ៍នេះទាំងមូល ហើយនឹងផ្ដល់ការឆ្លើយតបសមស្របមួយតាមពេលវេលាកំណត់ ដែលនឹងឆ្លុះបញ្ចាំងពីបច្ចុប្បន្នភាពនៃការវិវត្តថ្មីៗ នៅក្នុងវិស័យដែលជាការព្រួយបារម្ភរបស់គណៈកម្មការអឺរ៉ុប។ តាមការរំពឹងទុក គណៈកម្មការអឺរ៉ុបនឹងធ្វើសេចក្ដីសម្រេចនៅខែកុម្ភៈ ឆ្នាំ២០២០ ខាងមុខ ថាតើនឹងត្រូវដកប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជកម្ម ឬយ៉ាងណា។

ដោយអនុលោមតាមការប្រតិបត្តិតាមផ្លូវការទូត និងល័ក្ខខ័ណ្ឌនានារបស់គណៈកម្មការអឺរ៉ុប របាយការណ៍នេះត្រូវបានចាត់ទុកជាឯកសារសម្ងាត់។រាជរដ្ឋាភិបាលកម្ពុជាមានការសោកស្ដាយ និងថ្កោលទោសចំពោះវិទ្យុអាស៊ីសេរី ដែលមានចេតនាផ្សាយព័ត៌មានមិនពិតក្នុងគោលបំណងបំភាន់សាធារណជនអំពីរបាយការណ៍របស់គណៈកម្មការអឺរ៉ុប។ យោងទៅលើពាក្យពេចន៍ និងកថាខណ្ឌដែលបានដកស្រង់យកមកផ្សព្វផ្សាយ ដោយយកចេញពីរបាយការណ៍នេះ មិនត្រឹមត្រូវតាមខ្លឹមសារដើមឡើយ។

ព័ត៌មានមិនពិតដូចនេះ បានបង្កើតនូវក្ដីបារម្ភមិនគួរមាន ដែលពាក់ព័ន្ធដល់កម្មកររាប់ម៉ឺននាក់ ធ្វើឱ្យសាធារណជនភាន់ច្រឡំ និងធ្វើឱ្យអាប់ឱនដល់កេរ្តិ៍ឈ្មោះមន្ត្រីរាជរដ្ឋាភិបាល ដែលវិទ្យុអាស៊ីសេរី អះអាងថាបានធ្វើឱ្យបែកធ្លាយឯកសារ។ ម្យ៉ាងវិញទៀត សកម្មភាពរបស់វិទ្យុអាស៊ីសេរីបញ្ជាក់យ៉ាងច្បាស់ថា វិទ្យុនេះមិនមែនជាប្រភពព័ត៌មានដែលគួរឱ្យទុកចិត្តបាន ប៉ុន្តែគ្រាន់តែជាស្ថានីយ៍ឃោសនាមួយដែលបម្រើដល់ក្រុមនយោបាយមួយប៉ុណ្ណោះ។

ក្រៅពីក្រសួងការបរទេស សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាក៏បានថ្លែងពន្យល់សាធារណជនអំពី ប្រព័ន្ធអនុគ្រោះពន្ធនាំចូលទៅអឺរ៉ុបនេះផងដែរ។


*សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។*
*រូបភាព៖ Facebook page នាយករដ្ឋមន្ត្រី*

ថ្លែងនៅក្នុងពិធីចែកសញ្ញាប័ត្រនិស្សិតសាកលវិទ្យាល័យធនធានមនុស្ស សម្ដេចតេជោ ហ៊ុន សែន បាន ថ្លែងថា រាជរដ្ឋាភិបាលកំពុងតែឆ្លើយតបនឹងបញ្ហាប៉ុន្តែ មិនអាចយកអធិបតេយ្យភាព និង ឯកភាពជាតិ ទៅប្ដូរដោយសារតែសំពាធបានឡើយ។

សម្ដេចតេជោ ហ៊ុន សែន បានថ្លែងថា៖ «អ្នកខ្លះ គេដើរនិយាយថា ប្រសិនបើមិនមានការអនុគ្រោះពន្ធនាំចូលពីអឺរ៉ុបទេនោះ យើងនឹងពិបាក ប៉ុន្តែនោះគឺជារឿងមិនពិត ដោយសារតែកម្ពុជាមកដល់ពេលនេះមិន បានពឹងតែលើប្រព័ន្ធអនុគ្រោះពន្ធនាំចូលអឺរ៉ុបនោះតែមួយនោះទេ ភាគច្រើនប្រាក់ចំណូលរដ្ឋ គឺបានមកពីការប្រមូលពន្ធ ហើយក្រៅពីនោះ នៅរកប្រាក់ចំណូលពីវិស័យរួមផ្សំផ្សេងទៀត ដែលរួមមានដូចជាទេសចរណ៍ជាដើម៕

# លោកអភិបាលអូលីវីយេ ជំរុញឲ្យក្រុមបូជាចារ្យរិះគិតពីសាររបស់សម្ដេចប៉ាបនៅអាស៊ី

*ដោយ៖ ដាលីស*

ក្រុមបូជាចារ្យទាំងអស់ដែលបម្រើការងារនៅក្នុងព្រះសហគមន៍ភូមិភាគភ្នំពេញ បានជួបជុំគ្នារិះគិតអំពីរដូវរង់ចាំ និងសាររបស់សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូដែលបានធ្វើដំណើរទស្សនកិច្ចនៅប្រទេសថៃនិងជប៉ុន។ កិច្ចប្រជុំនេះ ដឹកនាំដោយលោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ អូលីវីយេ ជ្មិតអឺស្ល័រ នាព្រឹកថ្ងៃទី ៤ ធ្នូ ២០១៩ នៅព្រះវិហារសន្តសិលា និងសន្តប៉ូល ភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី រាជធានីភ្នំពេញ។

នៅក្នុងជំនួបនេះ អស់លោកបូជាចារ្យទាំងអស់បានទស្សនាវីដេអូនៃទស្សនកិច្ចជាផ្លូវការរបស់សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ ដែលបានប្រព្រឹត្តទៅនៅប្រទេសថៃនិងជប៉ុននាចុងខែវិច្ឆិកាកន្លងទៅនេះ។ ជាកិច្ចបន្ទាប់លោកអភិបាលអឹលីវីយេ បានណែនាំក្រុមបូជាចារ្យទាំងអស់ដែលជាសាសនទូតឲ្យយកចិត្តទុកដាក់លើខ្លឹមសារ និងសកម្មភាពរបស់សម្ដេចប៉ាបដែលជាសញ្ញាមួយយ៉ាងពិសេសនៅក្នុងការប្រកាសដំណឹងល្អ ដើម្បីចូលទៅក្នុងដួងចិត្តប្រជាពលរដ្ឋ។ សារទាំងនោះ ជាគំរូសម្រាប់អស់លោកបូជាចារ្យមកអនុវត្តក្នុងការប្រកាសដំណឹងល្អនៅក្នុងប្រទេសកម្ពុជា។

> **សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ បានរំឭកយើងឲ្យភ្ញាក់ស្មារតីដើម្បីគិតពីសិទ្ធិមនុស្ស ដោយយកចិត្តទុកដាក់ចំពោះអ្នកតូចតាច ដូចជាអ្នកក្រីក្រ កូនក្មេង ស្ត្រីបម្រើសេវាកម្មកម្សាន្ត និងពលករចំណាកស្រុក...**

នៅក្នុងកិច្ចប្រជុំ លោកអភិបាលអូលីវីយេ បានលើកយករបៀបដែលប្រទេសថៃបានទទួលស្វាគមន៍សម្ដេចប៉ាប និងសក្ខីភាពរបស់គ្រីស្តបរិស័ទដែលកែប្រែចិត្តគំនិតក្រោយពេលជួបសម្ដេចប៉ាបដោយហ៊ានប្រកាសប្រាប់អ្នកផ្ទះថា ខ្លួនជាគ្រីស្តបរិស័ទ ដែលជានិមិត្តសញ្ញាបង្ហាញថាសម្ដេចប៉ាបកំពុងតែប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលកំពុងតែយាងមក និងបង្កើតសង្គមមួយថ្មីតាមរបៀបព្រះយេស៊ូ។ នៅក្នុងនេះផងដែរ លោកអភិបាល ក៏បានលើកឡើងថា៖ «សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ បានរំឭកយើងឲ្យភ្ញាក់ស្មារតីដើម្បីគិតពីសិទ្ធិមនុស្ស ដោយយកចិត្តទុកដាក់ចំពោះអ្នកតូចតាច ដូចជាអ្នកក្រីក្រ កូនក្មេង ស្ត្រីបម្រើសេវាកម្មកម្សាន្ត និងពលករចំណាកស្រុក»។

ជាងនេះទៅទៀតលោកអភិបាលក៏មិនភ្លេចណែនាំក្រុមបូជាចារ្យឲ្យយកចិត្តទុកដាក់ចំពោះទំនាក់ទំនងជាមួយសាសនាផ្សេងៗ ដោយយកគំរូតាមសម្ដេចប៉ាប ដើម្បីកសាងសន្តិភាព និងរួមគ្នាការពារបរិស្ថាន ដោយគ្មានភាពភ័យខ្លាចផងដែរ។

នៅក្នុងរដូវរង់ចាំនេះ អស់លោកបូជាចារ្យទាំងអស់ ត្រូវបានស្នើសូមឲ្យរិះរកវិធី ដើម្បីអាចប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ឲ្យចូលទៅក្នុងចិត្តគំនិត និងវប្បធម៌របស់សង្គមឬប្រទេសដែលអស់លោកកំពុងតែបំពេញបេសកកម្ម៕



*លោកអភិបាលអូលីវីយេ ជ្មិតអឺស្ល័រ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។*

# រាងកាយ និងវិញ្ញាណត្រូវចិញ្ចឹមដោយការអប់រំ

*ដោយ៖ ង៉ែត សុធីរិទ្ធ*



*លោកអភិបាលអូលីវីយេក្នុងពិធីបើកបវេសនកាល។*



*សិស្សកំពុងសិក្សាថ្នាក់កុំព្យូទ័រក្នុងវិទ្យាល័យសម្ដេចក្រុមព្រះ និង ព្រះអង្គម្ចាស់ក្សត្រិយ នរោត្តម ម៉ារីរណឫទ្ធិ។*

លោកអភិបាលអូលីវីយេ ជ្មិតអឺស្ល័រ ចូលរួមជាអធិបតីក្នុងពិធីបើកបវេសនកាលវិទ្យាល័យសម្ដេចក្រុមព្រះ និង ព្រះអង្គម្ចាស់ក្សត្រិយ នរោត្តម ម៉ារីរណឫទ្ធិ អង្គរនាប នាព្រឹកថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដោយរួមជាមួយ លោក សាយ វណ្ណៈ អភិបាលរងស្រុកត្រាំកក់ លោក យន់ យ៉ុង អនុប្រធានការិយាល័យមធ្យមសិក្សានៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ និងមានការចូលរួមដោយលោកគ្រូអ្នកគ្រូ បុគ្គលិកសិក្សា និងសិស្សានុសិស្ស ជិត២០០០នាក់។

លោកអភិបាល អូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានថ្លែងក្នុងអង្គពិធីថា លោកមកចូលរួមថ្ងៃនេះ ក្នុងនាមជាមិត្តសម្លាញ់នៃការសិក្សា។ លោកបានមានប្រសាសន៍ទៀតថា មនុស្សដែលពេញលក្ខណៈជាមនុស្សដែលចិញ្ចឹមខួរក្បាលផង ដែលថែរក្សារូបកាយផង ដែលយកចិត្តទុកដាក់លើផ្លូវវិញ្ញាណផង និងរស់នៅក្នុងពិភពដែលយើងបានទទួល។ ដូច្នេះ ចំណេះដឹងជាកត្តាសំខាន់ ហើយយើងត្រូវចេះថែរក្សាទេពកោសល្យ ថែរក្សាសាមគ្គីភាពជាមួយមនុស្សនៅក្នុងសង្គម និងចេះចិញ្ចឹមផ្លូវវិញ្ញាណ។

ក្នុងនោះដែរលោកអភិបាលបានផ្ដល់នូវពាក្យបួនឃ្លាដែលក្នុងនោះមាន សមត្ថភាព ឧត្តមភាព មេត្តា និងករុណា ដល់សិស្សានុសិស្សទាំងអស់។ លោកបញ្ជាក់ថា ការសិក្សាអប់រំគឺ ឲ្យយើងខិតខំអស់ពីសមត្ថភាព ឲ្យយើងថែរក្សាឧត្តមភាពដើម្បីចូលរួមនៅក្នុងអនាគតនៃប្រទេសជាតិ និងការពារថែរក្សាចិត្តមេត្តានិងករុណា ដែលណែនាំឲ្យយើងអភិវឌ្ឍនៅក្នុងសុខសន្តិភាព។

វិទ្យាល័យសម្ដេចក្រុមព្រះ និងព្រះអង្គម្ចាស់ក្សត្រិយ នរោត្តម ម៉ារីរណឫទ្ធិ អង្គរនាប ស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ៣ ក្នុងភូមិអង្គរនាប ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។

លោកគ្រូ អ៊ូ ហេង នាយកវិទ្យាល័យនេះ មានប្រសាសន៍ថា ទិសដៅរបស់សាលានេះ គឺពង្រឹងការបង្រៀននិងរៀនឲ្យមានប្រសិទ្ធភាព រៀបចំកែលម្អបរិស្ថាននិងអនាម័យសាលារៀនឲ្យបានល្អ ជំរុញផ្នែកបំណិនជីវិតឲ្យមានដំណើរការល្អ និងទទួលបានជោគជ័យ ធ្វើឲ្យមានការទំនាក់ទំនងល្អជាមួយសហគមន៍ជាតិ អន្តរជាតិ ដើម្បីជួយអភិវឌ្ឍន៍សាលារៀន។

លោកក៏បានថ្លែងអំណរអរគុណដល់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដែលមានលោកអភិបាលអូលីវីយេជាប្រមុខ ដែលតែងតែជួយឧបត្ថម្ភនិងមានទំនាក់ទំនងល្អរវាងគ្នានិងគ្នាតាំងពីដើមរៀងមក។

ក្នុងកម្មវិធីនោះដែរលោកអភិបាល បានជូនកុំព្យូទ័រលើតុចំនួន ២៥គ្រឿង និងសម្ភារការិយាល័យមួយចំនួនដល់សាលា សៀវភៅសរសេរចំនួន៣២០០ក្បាលដល់សិស្សានុសិស្ស និងផលិតផលសិប្បកម្មរបស់ព្រះសហគមន៍កាតូលិក ព្រមទាំងថវិកាមួយចំនួនជូនលោកគ្រូអ្នកគ្រូ និងបុគ្គលិកសិក្សា៕

# ព្រះសហគមន៍ផ្ដល់អាហារូបត្ថម្ភ ដល់កុមារក្រីក្រនៅ ព្រែកទាល់

*ដោយ៖ ហៀម សុកខុន*

ព្រះសហគមន៍ព្រែកទាល់បានផ្ដល់អាហារបំប៉នដល់កុមារក្រីក្រប្រហែល១០០នាក់ រៀងរាល់ថ្ងៃអាទិត្យ ដើម្បីបំប៉នសុខភាពកុមារបន្ថែម ដោយសារគ្រួសារកុមារមួយចំនួនធំ គ្មានអាហារគ្រប់គ្រាន់សម្រាប់កូនៗរបស់ពួកគាត់។

លោក ឈិត ប៊ុនលឹម ជាជំនួយការព្រះសហគមន៍បានមានប្រសាសន៍ថា ដោយសារភាពក្រីក្រ ការទទួលទានអាហាររបស់កុមារមិនគ្រប់ជីវជាតិឡើយ ដូច្នេះហើយទើបព្រះសហគមន៍បានរៀបចំអាហារជារៀងរាល់ថ្ងៃអាទិត្យដល់កុមារក្រីក្រទាំងនោះ សរុបជិត១០០នាក់។ លោកបន្តទៀតថា កម្មវិធីនេះបានចាប់ផ្ដើមជាង១០ឆ្នាំមកហើយ។



*កុមារតូចៗទទួលបានរៀបចំអាហារជារៀងរាល់ថ្ងៃអាទិត្យ។* រូបភាព៖ ឈិត ប៊ុនលឹម



*មធ្យោបាយធ្វើដំណើរក្នុងសហគមន៍ព្រែកទាល់។* រូបភាព៖ ឈិត ប៊ុនលឹម

លោក ប៊ុនលឹម បន្តថា ព្រះសហគមន៍មិនត្រឹមតែផ្ដល់អាហារបំប៉នតែមួយមុខដល់កុមារទាំងអស់នោះប៉ុណ្ណោះទេ ព្រះសហគមន៍ថែមទាំងបើកសាលាមត្តេយ្យជួយដល់កុមារទាំងនោះដោយមិនគិតថ្លៃ និងមានវគ្គបំប៉នភាសាអង់គ្លេសក្នុង១ថ្ងៃបីពេលសម្រាប់សិស្សបឋមសិក្សានិងអនុវិទ្យាល័យ។

សាលាបំប៉នសន្តីម៉ារី របស់ព្រះសហមន៍សន្តយ៉ូសែបព្រែកទាល់ ស្ថិតនៅភូមិព្រែក ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែលបានសាងសង់នៅលើទឹក បានចាប់ផ្ដើមក្នុងឆ្នាំ២០១៦ ដែលមានសិស្សមត្តេយ្យសរុបចំនួន២២នាក់និងមានគ្រូបង្រៀនម្នាក់។ ហើយសិស្សដែរមករៀនវគ្គបំប៉នភាសាអង់គ្លេសមានចំនួនជាង៧០នាក់ មានគ្រូបង្រៀនម្នាក់ ដែលសិស្សទាំងអស់នោះ ៩៩% ជាកូនពុទ្ធបរិស័ទ។ សព្វថ្ងៃសាលានេះទទួលខុសត្រូវដោយលោកបូជាចារ្យ បាណេណាល់ តូតែត៕







*កុមារជាច្រើនមកពីគ្រួសារក្រីក្រខ្វះអាហារូបត្ថម្ភទទួលបានការបំប៉នសុខភាពបន្ថែម ក៏ដូចជាការអប់រំតាមរយៈព្រះសហគមន៍។* រូបភាព៖ ឈិត ប៊ុនលឹម

# ព្រះសហគមន៍កោះស្លា យកចិត្តទុកដាក់ជាមួយ ជនក្រីក្រនៅតាមភូមិ



*ព្រះសហគមន៍តែងតែជួយដល់អ្នកខ្វះខាតនៅក្នុងភូមិ ដោយមិនគិតអំពីសាសនានោះទេ។* រូបភាព៖ ព្រះសហគមន៍កោះស្លា

*ដោយ៖ ដាលីស*

ក្រុមសង្គហៈ និងក្រុមយុវជននៃព្រះវិហារសន្តប៉ូល កោះស្លារួមជាមួយលោកបូជាចារ្យ កាលេណានី ឆាល បានអញ្ជើញទៅចូលរួមរំលែកមរណទុក្ខដល់ក្រុមគ្រួសារសពលោក ជា កើត ដែលជាជនក្រីក្រនៅភូមិទួលដូនតី ឃុំត្រពាំងភ្លាំង ស្រុកឈូកខេត្តកំពត នាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ។

លោក ជា កើត អាយុ៥១ឆ្នាំ ទទួលមរណភាពដោយសារ ជំងឺ។ ក្រោយពីលោកបូជាចារ្យបានសួរនាំក្រុមគ្រួសារសព និងចូលរួមគោរពវិញ្ញាណក្ខន្ធនិងអធិដ្ឋានតាមបែបគ្រីស្តសាសនារួចរាល់។ព្រះសហគមន៍ផ្ដល់អង្ករមួយបាវ និងជូនថវិកាមួយចំនួនសម្រាប់គ្រួសារក្រីក្រមួយនេះ ដោយបានមកពីអង្គាសថវិកាពីគ្រីស្តបរិស័ទ។ នេះបើតាមប្រសាសន៍របស់លោក សិលា ចាន់ម៉ានុត ប្រធានក្រុមយុវជន និងក្រុមសង្គហៈរបស់ព្រះសហគមន៍កោះស្លា។

លោកបន្ថែមទៀតថា កូនៗរបស់សពមានចំនួន៧នាក់ដែលក្នុងនោះបីនាក់ទៀតកំពុងសិក្សានៅសាលា ហើយព្រះសហគមន៍បានរិះគិតថា នឹងជួយឧបត្ថម្ភពួកគាត់ ប្រសិនបើគ្រួសារនេះស្នើសុំ។

លោក ម៉ានុត ឲ្យដឹងទៀតថា ព្រះសហគមន៍តែងតែជួយដល់អ្នកខ្វះខាតនៅក្នុងភូមិ ដោយមិនគិតអំពីសាសនានោះទេ តួយ៉ាងដូចគ្រួសារសពលោក ជា កើតនេះ៕

# គ្រីស្តបរិស័ទជិត២០០នាក់ធ្វើដំណើរទៅកាន់ទីក្រុងបាងកកជួបជាមួយសម្ដេចប៉ាប

*ដោយ៖ ដាលីស*


*គ្រីស្តបរិស័ទដែលបានធ្វើដំណើរទៅកាន់ទីក្រុងបាងកកជួបជាមួយសម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ។*

គ្រីស្តបរិស័ទចំនួនជិត២០០នាក់ធ្វើដំណើរទៅកាន់ទីក្រុងបាងកកប្រទេសថៃ ក្នុងគោលបំណងធ្វើបូជនីយេសក៍ជួបជាមួយសម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ ដែលជាតំណាងគ្រីស្តទូតដ៏កំពូលតាមជំនឿព្រះសហគមន៍កាតូលិក ក្រោមការដឹកនាំដោយលោកបូជាចារ្យ ប៉ូល រឿង ឆ័ត្រសិរី ដែលជាអគ្គលេខារបស់លោកអូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ ដំណើរបូជនីយេសក៍នេះធ្វើឡើងរយៈពេល៤ថ្ងៃ៣យប់គឺចេញដំណើរពីថ្ងៃទី២០ ដល់២៣វិច្ឆិកា ២០១៩នេះ។

គួរបញ្ជាក់ផងដែរថា សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ បានមានបន្ទូលពីដំណើរទស្សនកិច្ចរបស់លោកនេះកាលពីថ្ងៃទី១៥វិច្ឆិកា ២០១៩ ថាលោកនឹងមានឱកាសជួបគ្រីស្តបរិស័ទកាតូលិកនៅប្រទេសថៃ ដើម្បីលើកទឹកចិត្តគ្រីស្តបរិស័ទនៅក្នុងជំនឿ និងការសហការគ្នាដើម្បីចែករំលែកឲ្យសង្គមនានា។ សម្ដេចប៉ាបក៏បានរំឭកដល់គ្រីស្តបរិស័ទជនជាតិថៃ ត្រូវបំពេញតួនាទីគាត់ដើម្បីប្រទេសជាតិរបស់ពួកគាត់ ហើយសង្ឃឹមថា នឹងជួយពង្រឹងទំនាក់ទំនងមិត្តភាព ឲ្យមានការចែករំលែកជាមួយបងប្អូន ពុទ្ធបរិស័ទប្រុសស្រី ព្រោះពួកគាត់ជាសាក្សីនៃភាពអត់ធ្មត់និងសាមគ្គីភាព ដែលជាអត្តសញ្ញាណ របស់ជនជាតិ ថៃ យ៉ាងពិតប្រាកដ។ សម្ដេចប៉ាបក៏មានបន្ទូលបង្ហាញនូវការជឿជាក់ថា ការសួរសុខទុក្ខរបស់ពុកលើកនេះ នឹងជួយឲ្យយើង យល់ដឹងសារៈសំខាន់រឿងទំនាក់ទំនងរវាងសាសនាយ៉ាងច្បាស់លាស់ ដោយយល់ចិត្តគ្នាយ៉ាងស៊ីជម្រៅមួយទៀតគឺ សហការគ្នាជួយគ្នាទៅវិញទៅមកដូចជាបងប្អូន ជាពិសេសរឿងការបម្រើសេវាដល់ជនក្រីក្រ សម្រាប់អ្នកដែលត្រូវការជំនួយជាទីបំផុត និងធ្វើការដើម្បីសន្តិភាព។

បងប្រុស ប្រាក់ ហុង និស្សិតទេវវិទ្យាន័យបានឲ្យដឹងថា ប្រសិនបើបានជួបសម្ដេចប៉ាបខ្ញុំនឹងសូមសម្ដេចគិតពីស្ថានភាពនយោបាយនៅកម្ពុជា និងសូមលោកអធិដ្ឋានសម្រាប់ព្រះសហគមន៍ ជាពិសេសសូមឲ្យទេវវិទ្យាល័យកម្ពុជាមានភាពរីកចម្រើនដោយមានយុវជនជាច្រើនអាចឆ្លើយតបនឹងការត្រាស់ហៅជាបូជាចារ្យ។

រីឯលោក គុយ លីហៀង ក៏បានរិះគិតផងដែរថាប្រសិនបើខ្ញុំបានជួបសម្ដេចប៉ាបខ្ញុំនឹងទូលសូមលោកប្រទានព្រះពរដល់ប្រទេសកម្ពុជាក៏ដូចជាពិភពលោកទាំងមូលឲ្យមានសុខសន្តិភាព និងអធិដ្ឋានដល់អស់កុមារកំព្រា អ្នកក្រីក្រខ្វះអាហារ ខ្វះសេចក្ដីស្រឡាញ់ ជាពិសេសដល់អស់វិញ្ញាណក្ខន្ធទារកដែលត្រូវឪពុកម្ដាយរំលូតចោល ព្រមទាំងអធិដ្ឋានចំពោះការបម្រែបម្រួលអាកាសធាតុនៅក្នុងពិភពលោកនេះផងដែរ៕

## រួមដំណើរជាមួយព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ពីពេលនេះទៅ


*បេក្ខជនបានសិក្សាឈ្វេងនៅក្នុងកម្មវិធីអប់រំជំនឿឱ្យចូលក្នុងព្រះសហគមន៍។*

នាកាលពីថ្ងៃអាទិត្យ ទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ កន្លងទៅនេះ នៅព្រះវិហារគង្វាលដ៏សប្បុរសនៃព្រះសហគមន៍អ្នកលឿង បានទទួលបេក្ខជនចំនួន២៨នាក់ដែលបានសិក្សាឈ្វេងយល់ជាច្រើនឆ្នាំក្នុងកម្មវិធីអប់រំជំនឿឲ្យចូលក្នុងព្រះសហគមន៍ ដោយមានលោកបូជាចារ្យ សេរ៉ាល់ រ៉ូសាំង ជាអធិបតី ដោយរួមជាមួយគ្រីស្តបរិស័ទជាច្រើនកុះករ។

លោកបូជាចារ្យសេរ៉ាល់ជាអ្នកទទួលខុសត្រូវនៅព្រះសហគមន៍អ្នកលឿងបានហៅឈ្មោះរបស់បេក្ខជនម្នាក់ឲ្យមកបង្ហាញខ្លួននៅមុខព្រះសហគមន៍របស់ព្រះជាម្ចាស់ ដោយអមមកជាមួយនូវបងធម៌ដែលជាគ្រីស្តបរិស័ទដើម្បីណែនាំពួកគាត់ក្នុងជំនឿជាកាតូលិក ដោយប្រកាសខ្លួនថា នឹងយកព្រះគ្រីស្តជាទីពឹង ព្រះបន្ទូលជាទីពឹង និងព្រះសហគមន៍ជាទីពឹង។

លោកបូជាចារ្យមានប្រសាសន៍ក្នុងធម្មទេសនាថា ពេលស្លាប់ទៅអ្វីដែលសំខាន់គឺយើងរួមជាមួយសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ដូច្នេះ ក្នុងពេលរស់នៅ គឺយើងត្រូវរស់នៅដោយសេចក្ដីស្រឡាញ់ ព្រោះនៅពេលស្លាប់ទៅគឺមានតែសេចក្ដីស្រឡាញ់ទេដែលនាំឲ្យយើងជួបព្រះជាម្ចាស់។ លោកបូជាចារ្យបន្ថែមថា៖ «សំខាន់គឺយើងត្រៀមខ្លួនពីពេលនេះទៅដើម្បីជាប់លាប់នឹងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់»។

លោកសេរ៉ាល់ បានរំលឹកដល់អ្នកដែលសុំចូលព្រះសហគមន៍ថា ពាក្យប្រកាសរបស់បងប្អូនមុននេះជាចំណែកមួយនៃអគ្គសញ្ញាជ្រមុជទឹក ដែលពួកគាត់នឹងត្រូវទទួលក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ ហើយសូមឲ្យបេក្ខជនត្រូវចេះភ្ជាប់នូវសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ក្នុងខ្លួនដើម្បីរួមដំណើរជាមួយព្រះជាម្ចាស់នឹងព្រះសហគមន៍៕





# សន្ទរកថារបស់សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ក្នុងដំណើរទស្សនកិច្ចនៅប្រទេសថៃ




### ជាមួយរដ្ឋាភិបាលថៃ៖

ពាក្យថា «ថៃ» មានន័យថា «សេរីភាព»។ ន័យនេះអាចទទួលបានប្រសិនបើមនុស្សមានចិត្តទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក ហើយប្រឆាំងនិងការរើសអើងវណ្ណៈ។ ខ្ញុំសូមគុណាចំពោះការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលថៃ ដលែបុរយុទ្ធបុរឆាំង នឹងទេសចរណ៍ផ្លូវភេទ។ «ខ្ញុំគិតដល់ស្ត្រីនិងកុមារនាពេលបច្ចុប្បន្ននេះ ពិសេស ជនរងគ្រោះពីការកេងប្រវ័ញ្ចគ្រប់ទម្រង់ ទាសភាព អំពើហឹង្សា និងការរំលោភបំពាន។ ខ្ញុំសូមថ្លែងអំណរគុណចំពោះការខិតខំរបស់រដ្ឋាភិបាលថៃក្នុងការបញ្ចប់បញ្ហាទាំងនេះ។» កាលពីអតីតកាលប្រទេសថៃបានស្វាគមន៍ជនជាតិវៀតណាម ហើយឥឡូវនេះទទួលស្វាគមន៍ ជនជាតិរ៉ូហ៊ីងយ៉ារាប់ពាន់នាក់ ដែលបានចាកចេញពីប្រទេសមីយ៉ាន់ម៉ាមក។

### ជាមួយព្រះសង្ឃរាជខាងពុទ្ធសាសនា៖

សម្ដេចព្រះសង្ឃរាជ ជាទីគោរពដ៏ខ្ពង់ខ្ពស់ ខ្ញុំសូមអរគុណាចំពោះបន្ទូលស្វាគមន៍យ៉ាងកក់ក្ដៅរបស់សម្ដេច។ ដើមដំបូងនៃដំណើរទស្សនកិច្ចរបស់ខ្ញុំមកកាន់ប្រទេសនេះ ខ្ញុំរីករាយដែលបានមកទស្សនា ព្រះវិហារដ៏ល្អនេះ ដែលជានិមិត្តរូបនៃគុណតម្លៃ និងការបង្រៀន អំពីកិរិយា ល្អនៃប្រជាជនជាទីស្រឡាញ់នៅទីនេះ។ អ្វីដែលខ្ញុំ បានជួបកន្លងមក រវាងថ្នាក់ដឹកនាំមុនៗ និង កោតសរសើរពីទិដ្ឋភាពនៃរបៀបរស់នៅបែបពុទ្ធសាសនា ការគិត និង ពុទ្ធិ។ វិធីនៃការចិញ្ចឹមបំប៉នេះមានលក្ខណៈរួមពិសេសរបស់ប្រជាជនថៃទាំងអស់គឺ «ស្នាមញញឹមរបស់គេ។

### សម្ដេចប៉ាបនៅមន្ទីរពេទ្យសន្តល្វីស

ខ្ញុំមានក្ដីរីករាយ ដែលមានឱកាស បានជួបជាមួយ វេជ្ជបណ្ឌិត គិលានុបដ្ឋាកយិការ គិលានុបដ្ឋាក និង បុគ្គលិកនៃមន្ទីរពេទ្យសន្តល្វីស (St. Louis) និង មន្ទីរពេទ្យកាតូលិកព្រមទាំងទីភ្នាក់ងារសប្បុរសធម៌ដទៃទៀត។ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកនាយកកិច្ចស្វាគមន៍ដ៏ល្អ។ ខ្ញុំមានសេចក្ដីរីករាយណាស់ដែលបានឃើញផ្ទាល់នឹងភ្នែកនូវសេវាកម្មដ៏មានតម្លៃនេះ ដែលព្រះសហគមន៍បានផ្ដល់ដល់ប្រជាជនថៃ ជាពិសេសដល់អ្នកដែលត្រូវការបំផុត។ ដោយក្ដីស្រឡាញ់ ខ្ញុំសូមផ្ញើសេចក្ដីនឹករលឹកដល់ក្រុមបងស្រី សន្តប៉ូលនៃឆាត្រេស (Saint Paul of Chartres) និងបងស្រីទាំងអស់ដែលមានវត្តមាននៅថ្ងៃនេះ។ ខ្ញុំសូមអរគុណាចំពោះការលះបង់ដ៏ស្ងប់ស្ងាត់និងរីករាយរបស់បងស្រី ចំពោះកិច្ចការបម្រើបងប្អូនអស់រយៈពេលជាច្រើនឆ្នាំមកនេះ។ បងប្អូនបានបង្ហាញវត្តមាននិងព្រះភក្ត្ររបស់ព្រះជាម្ចាស់ដែលបានយាងមកចាក់ប្រេង និងថែរក្សាបុត្រធីតារបស់ព្រះអង្គ «សូមអរគុណាច្រើន»។

ខ្ញុំមានសេចក្ដីរីករាយ ដែលបានស្ដាប់របាយការណ៍របស់លោកនាយក ស្ដីពីគោលការណ៍ដែលមន្ទីរពេទ្យនេះដំណើរការគឺ៖ ការីតាយូប៊ី ដេសអ៊ីប៊ី - ទីណាមានសេចក្ដីស្រឡាញ់ ព្រះជាម្ចាស់គង់នៅទីនោះ។ ពិតណាស់នៅក្នុងការអនុវត្តសកម្មភាពមេត្តាករុណាដែលយើងជាគ្រីស្តបរិស័ទ បានទទួលការត្រាស់ហៅឲ្យធ្វើជាសាសនទូត ប៉ុន្តែក៏ត្រូវប្រកាន់ភ្ជាប់ភាពស្មោះត្រង់ផ្ទាល់ខ្លួន និងចំពោះស្ថាប័ន ជាចាំបាច់ក្នុងជានាមជាសាសនទូត។

ព្រះអម្ចាស់យេស៊ូមានព្រះបន្ទូលថា៖ «យើងសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា គ្រប់ពេលដែលអ្នករាល់គ្នាប្រព្រឹត្តអំពើទាំងនោះចំពោះអ្នកតូចតាចជាងគេបំផុតម្នាក់ ដែលជាបងប្អូនរបស់យើងនេះ អ្នករាល់គ្នាក៏ដូចជាបានប្រព្រឹត្តចំពោះយើងដែរ» (មថ ២៥,៤០)។ បងប្អូនគឺសាសនទូតបម្រើក្នុងវិស័យថែទាំសុខភាព គឺបងប្អូនបើកដួងចិត្តរបស់បងប្អូនទៅរក «ភាពអាថ៌កំបាំងនៃភាពរភាពដ៏ឥតខ្ចោះ ការសញ្ជឹងគិតដ៏អស្ចារ្យ» បងប្អូនបានមើលឃើញភាពអស្ចារ្យអំពីវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងមនុស្សគ្រប់រូប ដោយភាពអត់ធ្មត់ក្នុងជីវិត។ បងប្អូនបានបើកចិត្តទៅរកសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ហើយភ្ជាប់វាក្នុងអំណរសប្បាយរបស់បងប្អូន ដូចជាព្រះបិតានៃស្ថានបរមសុខបានប្រព្រឹត្ត។

### សម្ដេចប៉ាបនៅពហុកីឡាដ្ឋានជាតិ៖

បើមិនបានជួបគ្រីស្តបរិស័ទនឹងមិនស្គាល់មុខលោកឡើយ។ នេះជាបទចម្រៀងនិងរបាំដែលបង្ហាញពីស្នាមញញឹមរបស់ប្រជាជនថៃ ជាអត្តសញ្ញាណនៅលើទឹកដីនេះ។ សាសនទូតបានយល់ច្បាស់ អំពីផែនការនៃក្ដីស្រឡាញ់របស់ព្រះបិតាហួសពីការគិតរបស់មនុស្ស។ សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់មានចំពោះមនុស្សគ្រប់គ្នា សូម្បីតែមនុស្សដែលគេបោះបង់ចោល ឬមនុស្សដែលសង្គមមើលងាយ។

នៅទីនេះ ខ្ញុំគិតពីកុមារនិងស្ត្រីដែលរងគ្រោះដោយអំពើពេស្យាចារ និងការជួញដូរមនុស្សដែលធ្វើឱ្យអាម៉ាស់មុខ និងសេចក្ដីថ្លៃថ្នូររបស់មនុស្ស។ ខ្ញុំគិតពីកុមារ និងជំទង់ដែលជាប់ឃុំឃាំងដោយការប្រើប្រាស់គ្រឿងញៀន និងអស់សង្ឃឹម ធ្វើឱ្យពួកគេធ្លាក់ទឹកចិត្ត និងបាត់បង់ក្ដីសុបិននាពេលអនាគតរបស់គេ។ ខ្ញុំគិតពីជនចំណាកស្រុក អស់អ្នកដែលគេដកហូតផ្ទះសំបែងដីធ្លីនិងធ្វើឲ្យបែកបាក់គ្រួសារ និងមនុស្សជាច្រើនទៀត ដែលស្រដៀងគ្នាដែលគេបោះបង់ចោល ក្មេងកំព្រា ឬមនុស្សដែលគេមិនរាប់រក និងបំភ្លេចចោល ។

### សម្ដេចប៉ាបជាមួយបព្វជិត-បព្វជិតា៖

ម្ដងទៀត ខ្ញុំសូមអរគុណាចំពោះការរស់នៅ និងចំពោះការធ្វើសាក្សីនិងការប្ដេជ្ញាចិត្តដ៏សប្បុរសរបស់បងប្អូន។ ខ្ញុំសូមលើកទឹកចិត្តបងប្អូនថា សូមកុំចាញ់ការល្បួង ដោយគិតថាអ្នកមានចំនួនតិចតួច។ ផ្ទុយទៅវិញត្រូវគិតថាបងប្អូនជាឧបករណ៍ដ៏តូចមួយក្នុងព្រះហស្តព្រះជាម្ចាស់សម្រាប់ព្រះអង្គប្រើប្រាស់។ ព្រះអង្គនឹងសរសេរទំព័រជីវិតដ៏ល្អបំផុតអំពីប្រវត្តិសាស្ត្រនៃការសង្គ្រោះក្នុងប្រទេសទាំងនេះ។

### សម្ដេចប៉ាបជាមួយក្រុមលោកអភិបាល៖

ខ្ញុំសង្កេតឃើញថា គ្រប់កិច្ចការទាំងអស់មុននឹងធ្វើបានសម្រេច រឺគំរោងការដែលត្រូវអនុវត្តល្អប្រសើរ តម្រូវឲ្យមានអ្នកច្រូតកាត់ និងស្គាល់ស្ថានភាពជាក់ច្បាស់។ បេសកកម្ម បានត្រាស់ហៅយើងឱ្យមានការយកចិត្តទុកដាក់ដូចជាឪពុក និងដូចជាម្ដាយ។ គង្វាលចៀមបានទុកចៀមផ្សេងៗចោល ដើម្បីស្វែងរកចៀមតែមួយដែលបាត់។

គ្រីស្តបរិស័ទជាគ្រហស្ថគឺមានទំនាក់ទំនងផ្ទាល់ជាមួយប្រជាជនក្នុងស្រុកភូមិ ហេតុនេះហើយ ពួកគេត្រូវដើរតួសំខាន់ក្នុងការប្រកាសដំណឹងល្អ។

កុំឲ្យយើងភ្លេចថា ក្នុងទឹកដីជាច្រើននៅទ្វីបអាស៊ីនេះ ដំណឹងល្អត្រូវបានផ្សព្វផ្សាយដោយគ្រីស្តបរិស័ទជាគ្រហស្ថ។ កុំឲ្យយើងតែងតាំងតាមបេសកកម្ម គឺកុំតែងតាំងគ្រីស្តបរិស័ទជាគ្រហស្ថ។

### សម្ដេចប៉ាបជាមួយយុវជន៖

ព្រះអម្ចាស់ដឹងថា តាមរយៈកូនៗជាយុវវ័យអនាគតនឹងមកដល់ទឹកដីនេះនិងពិភពលោកទាំងមូល។ ព្រះអង្គកំពុងពឹងផ្អែកលើកូនៗ ដើម្បីបំពេញបេសកកម្មរបស់កូននៅថ្ងៃនេះ។ ដូចព្រះអង្គមានគំរោងការសម្រាប់មនុស្សដែលព្រះអង្គបានជ្រើសរើស ដូច្នេះព្រះអង្គមានផែនការសម្រាប់កូនម្នាក់ៗ។ «តើកូនៗចង់ឲ្យភ្លើងខាងក្នុងដួងចិត្តរបស់កូន ឆេះខ្លាំងៗឡើងឬទេ? តើកូនៗបានរៀបចំខ្លួន ដើម្បីឆ្លើយតបការត្រាស់ហៅរបស់ព្រះជាម្ចាស់ឬនៅ? តើកូនបានត្រៀមខ្លួនដើម្បីធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គដែរឬទេ?»

យុវជនជាទីស្រឡាញ់ ដើម្បីរក្សាភ្លើងវិញ្ញាណឱ្យនៅឆេះ កូនត្រូវបើកភ្នែកនិងបញ្ចេះបេះដូងរបស់កូន ហើយត្រូវចាក់ឫសនៃជំនឿដូចបព្វការីជន គឺដូចឪពុកម្ដាយ ជីដូនជីតានិងគ្រូរបស់កូន។ មិនដូច្នេះទេ កូននឹងជាប់គាំងក្នុងអតីតកាល ហើយកូនត្រូវរៀនស្វែងរកភាពក្លាហាន ដែលអាចជួយយើងឆ្លើយតបនូវហេតុការថ្មីៗបាន៕

# ព្រះសហគមន៍បង្កើតការប្រកួតថែរក្សាសម្បត្តិវប្បធម៌ជាតិ

*ដោយ៖ លី សុវណ្ណា*

ដើម្បីអបអរសាទរ ឆ្នាំសកលនាថ្ងៃទី១ មករានេះ ព្រះវិហារសន្តីម៉ារីញញឹម នៃព្រះសហគមន៍កាតូលិកចម្ការទៀង បានរៀបចំឲ្យមានការប្រកួតខ្លែងឯកចំនួន ១៨០ ការប្រណាំងរទេះគោ១០នឹម ប្រណាំងជិះសេះ១០ក្បាល ដែលមានប្រជាពលរដ្ឋមកពីបណ្ដាភូមិឃុំនានាក្នុងស្រុកត្រាំកក់ នៃខេត្តតាកែវ។

ក្នុងកម្មវិធីនេះ មានការចូលរួមពីលោកអភិបាលអូលីវីយេ រួមនិងប្រធានស្ដីទីនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តតាកែវ អនុប្រធានមន្ទីរធម្មការនិងសាសនាខេត្តតាកែវ ថ្នាក់ដឹកនាំឃុំគូស និងព្រះសង្ឃ និងគណៈកម្មការវត្តអង្គមន្ត្រី និងប្រជាពលរដ្ឋនានាដែលមកចូលរួមទស្សនាយ៉ាងច្រើនកុះករ។









*សកម្មភាពប្រកួតខ្លែងឯក រទេះគោ និងប្រណាំងសេះរបស់ប្រជាពលរដ្ឋមកពីបណ្ដាភូមិឃុំនានាក្នុងស្រុកត្រាំកក់ នៃខេត្តតាកែវ ។ រូបភាព៖ ស៊ីអេសស៊ី*

លោកអភិបាលអូលីវីយេ បានមានប្រសាសន៍សំណេះសំណាលបើកកម្មវិធីនេះថា លោកសូមស្វាគមន៍ដល់អស់លោកមន្ត្រីនិងប្រជាពលរដ្ឋទាំងអស់ដែលបានមកចូលរួមក្នុងថ្ងៃនេះ។ កម្មវិធីថ្ងៃនេះ គឺហាក់ដូចជាអបអរសាទរឆ្នាំថ្មី។

លោកអភិបាលអូលីវីយ៖ «យើងមានលោកតាលោកយាយទាំងអ្នកភូមិយ៉ាងច្រើនដែលមកពីឃុំគូស ដែលយើងមាន៣០ភូមិដែលចូលរួមថ្ងៃនេះ។ ដូច្នេះ នេះជាឱកាសមួយឆ្លងឆ្នាំនៅក្នុងលក្ខណៈ ដែលជាគ្រួសារមួយ ដែលចេះសហការជាមួយគ្នា ចេះសប្បាយជាមួយគ្នារួមជាមួយវត្តអង្គមន្ត្រី...ជាលក្ខណៈមួយបង្ហាញថា យើងទាំងអស់គ្នាខិតខំកសាងប្រទេសរបស់យើងជាគ្រួសារតែមួយដែលថែរក្សាសុខដុមរមនា ថែរក្សាមិត្តភាព ភាតរភាព»។

លោកអភិបាលសង្ឃឹមថា ការជួបជុំនេះ នឹងនាំឲ្យមានភាពរួមគ្នាដើម្បីកសាងប្រទេសកម្ពុជានាពេលខាងមុខ។ លោកអភិបាល៖ «ខ្ញុំជឿថា កម្មវិធីថ្ងៃនេះ អាចមានឥទ្ធិពលសម្រាប់មួយឆ្នាំខាងមុខ ដោយយល់ថា យើងជាប្រជាជនតែមួយដែលនឹកឃើញវប្បធម៌របស់យើង ដែលនឹកឃើញបុព្វបុរសដែលបានកសាងប្រទេសអស់ពីសមត្ថភាព ហើយយើងបន្តតួនាទីនិងការងាររបស់បុព្វបុរសរបស់យើងដើម្បីកសាងប្រទេសរបស់យើងនៅថ្ងៃអនាគតទៀត»។

កម្មវិធីបង្ហោះខ្លែងឯកនេះ បានធ្វើឡើងរយៈពេល១០ឆ្នាំមកហើយ ក្រោមគំនិតផ្ដួចផ្ដើមរបស់លោកអភិបាលអូលីវីយេ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។

លោកមាគ ស៊ីន ជាគណៈកម្មការរៀបចំកម្មវិធីនេះ មានប្រសាសន៍ថាកម្មវិធីនេះ គឺធ្វើឡើងដើម្បីថែរក្សាវប្បធម៌របស់ខ្មែរដែលមានតាំងពីយូរយារមកហើយ។ លោក មាគ ស៊ីន «លើកទី១០ហើយ ដែលយើងបានរៀបចំ កម្មវិធីនេះ ដែលនាំឲ្យបងប្អូនមានអំណរសប្បាយចូលរួមថែរក្សាប្រពៃណីវប្បធម៌ ក៏ដូចជាថែរក្សាកេរ្តិ៍មរតកដូនតាយើង ដែលបានបន្សល់ទុកសម្រាប់កូនចៅ ជំនាន់ក្រោយ»។

កម្មវិធីនេះ មានជារៀងរាល់ឆ្នាំស្ថិតក្នុងភូមិចម្ការទៀង។ លោកស៊ីន៖ «នេះជាអ្វីមួយដែលបញ្ជាក់ថា យើងកំពុងតែធ្វើអ្វីមួយដើម្បីការពារឲ្យយើងមានសមិទ្ធផលពីបុរាណរបស់យើង មាននៅក្នុងស្រុកភូមិរបស់យើងផងដែរ»៕

# លោកបូជាចារ្យ មួង រស់ ទៅបន្តការសិក្សានៅប្រទេសហ្វីលីពីន១ឆ្នាំ

*ដោយ៖ កែវ កញ្ញា*



*លោកបូជាចារ្យ យ៉ូសែប មួង រស់ យុវជនជាតិកម្ពុជា ដែលបានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យកាតូលិក ក្នុងឆ្នាំ២០១៤ ក្នុងភូមិភាគបាត់ដំបង។*

លោកបូជាចារ្យ មួង រស់ បានចាកចេញពីប្រទេសកម្ពុជា ដើម្បីបន្តការសិក្សានៅប្រទេសហ្វីលីពីនរយៈពេល១ឆ្នាំ។ លោកបានចេញប្រទេសកម្ពុជាកាលពីយប់ថ្ងៃទី២ ខែមករា ឆ្នាំ២០២០នេះ។ លោកបូជាចារ្យ មួង រស់ បានឲ្យដឹងថា លោកនឹងសិក្សាលើមុខវិជ្ជា២ គឺ Pastoral Leadership and Management for the Mission និង Pastoral Renewal for Discipleship។ លោកបូជាចារ្យបានបញ្ជាក់ថា មុខវិជ្ជាទី១ គឺជាការងារសម្រាប់បម្រើព្រះសហគមន៍និងរៀបចំកិច្ចការប្រកាសដំណឹងល្អ ហើយមុខវិជ្ជាទី២ គឺការមើលកិច្ចការងាររបស់យើងឡើងវិញក្នុងនាមយើងជាសាវ័ករបស់ព្រះយេស៊ូគ្រីស្ត។

លោកបូជាចារ្យរូបនេះ រំពឹងថា ក្រោយពេលរៀនចប់ នឹងអាចយកចំណេះដឹងនិងជំនឿថែមទៀតត្រឡប់មកភូមិភាគបាត់ដំបង ដើម្បីបម្រើកិច្ចការងារក្នុងការប្រកាសដំណឹងល្អនៅប្រទេសកម្ពុជា។

លោកបូជាចារ្យមួងរស់ បានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យកាតូលិកនាថ្ងៃទី៦ ខែធ្នូ ឆ្នាំ ២០១៤។

លោកមានប្រសាសន៍ថា ក្នុងរយៈពេល៥ឆ្នាំមកនេះ លោកបានទទួលខុសត្រូវលើព្រះសហគមន៍ចំនួន២ គឺព្រះសហគមន៍ស្ទឹង និងព្រះសហគមន៍ប៉ៃលិន។ ជាមួយគ្នានោះដែរ លោកក៏ទទួលខុសត្រូវលើកម្មវិធីយុវជនទូទាំងភូមិភាគបាត់ដំបងផងដែរ និងកិច្ចការងារមួយចំនួនទៀត។

លោកមានប្រសាសន៍ថា ក្នុងរយៈពេល៥ឆ្នាំនេះ លោកសប្បាយរីករាយដែលបានបម្រើព្រះសហគមន៍ ទោះបីកិច្ចការងារខ្លះមិនសូវស្រួល តែលោកពេញចិត្តបម្រើ «ធ្វើឲ្យខ្ញុំរីកចម្រើន មានភាពចាស់ទុំបន្តិចម្ដងៗតាមផ្លូវវិញ្ញាណ...ដែលបានធ្វើការងាររបស់ព្រះជាម្ចាស់»៕





# លោកអភិបាល អូលីវីយេ ទទួល មេដាយមាសស្ថាបនាជាតិ ពីរាជរដ្ឋាភិបាលកម្ពុជា

លោកអូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ទទួលមេដាយមាសស្ថាបនាជាតិពីរាជរដ្ឋាភិបាលកម្ពុជា ដោយសារលោកបានចូលរួមយ៉ាងសកម្មក្នុងកិច្ចការងារសង្គម និងអភិវឌ្ឍន៍មូលដ្ឋានរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ពិធីនេះបានប្រារព្ធធ្វើក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការសមិទ្ធផលនានានៅក្នុងវត្តអង្គមន្ត្រីនៃស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមអធិបតីរបស់លោក ចាន់ សារុន អ្នកតំណាងរាស្ត្រមណ្ឌលតាកែវ និងលោកជំទាវ នាព្រឹកថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៩ កន្លងទៅ។

តាមរបាយការណ៍របស់លោក អ៊ឹង ណាយ មេឃុំគូសបានឲ្យដឹងថា ស្របតាមការរីកចម្រើន របស់ប្រទេសជាតិទាំងផ្នែកពុទ្ធចក្រនិងអាណាចក្រ និងដោយការខិតខំប្រឹងប្រែងរបស់ព្រះគ្រូចៅអធិកា លោកអាចារ្យ គណៈកម្មការវត្តបានកសាងសមិទ្ធផលថ្មីៗមានដូចជា ជួសជុលផ្លូវលំ១ខ្សែប្រវែង ១.៥០០ម ក្រាលការ៉ូសាលាឆាន់ជាន់ក្រោម តសំយាបសាលាភត្ត និងចាក់សាបក្នុងវត្ត សរុបការចំណាយមានចំនួន ៧៣.៩៦០.០០០ ៛ ដែលនឹងត្រូវដាក់សម្ពោធឆ្លងនាឱកាសនេះ។

លោកមេឃុំបានបន្តថា ក្នុងចំណោមថវិកាចំណាយលើសមិទ្ធផលទាំងនោះបានមកពីសប្បុរសជននានា ក្នុងនោះមានលោកអូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញជាដើម។ ក្នុងនាមអាជ្ញាក្នុងមូលដ្ឋានលោកសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកអូលីវីយេ ដែលបានចូលរួមយ៉ាងសកម្មអភិវឌ្ឍមូលដ្ឋាន មានទាំងសាលារៀន ផ្លូវថ្នល់ និងវត្តអារាមជាដើម។ល។



លោកអភិបាលអូលីវីយេ ដែលសកម្មក្នុងការអភិវឌ្ឍនៅតំបន់ស្រុកត្រាំកក់ ក្នុងទស្សនវិស័យដ៏ជ្រាលជ្រៅនៃការប្រកាសដំណឹងល្អ និងការអភិវឌ្ឍបានមានប្រសាសន៍រលឹកឡើងវិញ នូវទំនាក់ទំនងរវាង ព្រះសហគមន៍កាតូលិក ជាពិសេសរូបលោកផ្ទាល់ជាមួយវត្តអង្គមន្ត្រីនេះ ។ ក្នុងឆ្នាំ២០០២មក លោកបានកសាងផ្លូវលំ១ខ្សែប្រវែង២២០០ម៉ែត្រ តាមសំណូមពររបស់ប្រជាពលរដ្ឋ គណៈកម្មការវត្ត និងព្រះសង្ឃ។ ជាបន្តបន្ទាប់លោកអភិបាល មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ផ្លាស់ប្ដូរការសន្ទនាគ្នា អំពីសាសនាគ្រីស្ត និងព្រះពុទ្ធសាសនា។ លោកនៅបន្តសកម្មភាពជួយគ្នាតាមសេចក្តីត្រូវការរបស់វត្ត។ លោកអភិបាលបន្តថា៖ «យើងស្គាល់គ្នាតាំងពីឆ្នាំ២០០២ ហើយមានតាយាយមួយចំនួនបានលាចាកលោកនេះហើយ។ យើងសូមនឹករលឹកដល់ពួកគេផងដែរ»។

សម្រាប់ការងារអភិវឌ្ឍក្នុងតំបន់នេះ គឺអភិវឌ្ឍធនធានមនុស្ស និងអភិវឌ្ឍមនុស្សតូចតាច ជាពិសេសស្ត្រីមេម៉ាយ ឲ្យមានការងារធ្វើ កុមារពិការ និងជនមានពិការភាពជាដើម តាមមណ្ឌលភូមិសុខសាន្តដែលទទួលកុមារពិការ សាលារៀនពីមត្តេយ្យដល់វិទ្យាល័យ ដែលទទួលសិស្សបានចំនួនជាង៦០០នាក់ និងភូមិសិប្បកម្ម។

ក្នុងឱកាសនោះលោកអភិបាលក៏បានរំលឹកឡើងវិញនូវគោលការណ៍របស់ព្រះសហគមន៍កាតូលិកដលែបានយកចិត្តទុកដាក់លើកិច្ចសន្ទនាជាមួយសាសនានានា។ លោកអភិបាលមានប្រសាសន៍ថា៖ «ការសន្ទនាជោគជ័យ គឺត្រូវការយើងបង្កើតទំនាក់ទំនងផ្ទាល់ មិនគ្រាន់តែនិយាយអំពីទស្សនៈអស្ចារ្យៗ ប៉ុន្តែទំនាក់ទំនងដែលយើងមានផ្ទាល់ដើម្បីយល់ចិត្ត ដែលនាំឲ្យសាសនាទាំងពីរអាចរស់នៅក្នុងភាពសុខដុមរមនាពិតប្រាកដមែន»។

លោកអភិបាលអូលីវីយេក៏បានវាយតម្លៃខ្ពស់ពីការយកចិត្តទុកដាក់ និងផ្តល់សិទ្ធិសេរីភាពពេញលេញពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ចំពោះពលរដ្ឋក្នុងជំនឿសាសនា ដែលប្រជាជនអាចជឿសាសនាក៏បាន។

ក្នុងពិធីប្រសើរនេះលោក ចាន់ សារុន អ្នកតំណាងរាស្ត្រ មានប្រសាស៍ កោតសរសើរចំពោះសប្បុរសជនទាំងអស់ ជាពិសេស លោក អូលីវីយេ ដែលបានចូលរួមយ៉ាងសកម្មអភិវឌ្ឍរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ទាំងសាសនា និងសង្គម។ លោកបន្តថា នេះក៏ដោយសារតែប្រទេសកម្ពុជានាពេលនេះពោរពេញដោយសន្តិភាពពិតប្រាកដ។ ហេតុនេះសូមចូលរួមទាំងអស់គ្នាថែរក្សាសន្តិភាពកុំឲ្យបាត់បង់ទៅវិញ។ លោកអ្នកតំណាងរាស្ត្រខេត្តតាកែវ ក៏បានជំរុញឲ្យប្រជាពលរដ្ឋយកចិត្តទុកដាក់ខិតខំប្រកបរបរបន្ថែម និងថែរក្សាសុខភាពផងដែរក្នុងពេលរដូវត្រជាក់នេះ។

បន្ទាប់មក លោកតំណាងរាស្ត្រ ចាន់ សារុន បានបំពាក់មេដាយមាសស្ថាបនាជាតិដល់លោកអភិបាលអូលីវីយេនិងសប្បុរសជននានាព្រមទាំងកាត់ខ្សែបូរសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នូវសមិទ្ធផលទាំងឡាយក្នុងវត្តអង្គមន្ត្រីយ៉ាងឱឡារិក។

ក្រោយពីកាត់ខ្សែបូររួច លោកចាន់សារុន បានអញ្ជើញទស្សនកិច្ចភូមិសិប្បកម្មរបស់ព្រះសហគមន៍កាតូលិក ដែលបង្កើតដោយផ្ទាល់ដោយលោកអភិបាលអូលីវីយេ។ ក្នុងភូមិសិប្បកម្មនេះមានរោងចក្រផលិតស្ករគ្រាប់ដូង តម្បាញ កាត់ដេរនិងប៉ាក់ សិប្បកម្មដូង ជាងទងភោជនីយដ្ឋាន និងការផលិតសាប៊ូ ប្រេងដូង។ល។ ក្នុងភូមិនេះបានបង្កើតការងារយ៉ាងល្អសម្រាប់ប្រជាពលរដ្ឋ ដែលគេអាចទទួលប្រាក់កម្រៃតាមកម្រិតនៃការងាររបស់គេយ៉ាងសមរម្យ៕

# គ្រីស្តបរិស័ទនៅកម្ពុជាចូលរួម ខួប៥០ឆ្នាំ នៃការ បង្កើត ព្រះសហគមន៍ឫស្សីកែវ នៅវៀតណាម

*ដោយ៖ លោកបូជាចារ្យ រឿង ឆ័ត្រសិរី*

លោកបូជាចារ្យរឿង ឆ័ត្រសិរី និង លោកបូជាចារ្យដាវីឌ រួមជាមួយគ្រីស្តបរិស័ទពីភ្នំពេញជាង ៦០ នាក់ បានចូលរួមអបអរសាទរខួប ៥០ ឆ្នាំ នៃការបង្កើតព្រះសហគមន៍ព្រះនាងម៉ារី ជាមាតាព្រះជាម្ចាស់ឫស្សីកែវ នៅភូមិស៊ួយកាត ភូមិភាគស្ទួងឡុក ប្រទេសវៀតណាម នៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០២០ ក្រោមអធិបតីភាពលោកអភិបាលស៊ូសេ ឌីង ឌុក ដាវ (Giuse Đinh Đức Đạo) ព្រមទាំងបូជាចារ្យជិត ២០ អង្គ និងគ្រីស្តបរិស័ទប្រហែល ២០០០ នាក់។




*រូបភាពព្រះវិហារដំបូងដែលគ្រីស្តបរិស័ទបានតាំងទីនៅលើទឹកដីនៃប្រទេសវៀតណាម ក្នុងឆ្នាំ១៩៧១។*



*គ្រឿងសក្ការបូជាដែលគ្រីស្តបរិស័ទបាននាំមកជាមួយក្នុងពេលមានសង្គ្រាមនៅកម្ពុជា។*




*ព្រះវិហារឫស្សីកែវនៅក្នុងទីក្រុងភ្នំពេញក្នុងឆ្នាំ១៩២០។*

## ប្រវត្តិព្រះសហគមន៍ឫស្សីកែវ នៅប្រទេសវៀតណាមសព្វថ្ងៃ

ព្រះសហគមន៍ឫស្សីកែវ ជាព្រះសហគមន៍ចំណាស់មួយនៅខណ្ឌឫស្សីកែវ នៅរាជធានីភ្នំពេញ ដែលធ្លាប់មានទីតាំងនៅកណ្តាលភូមិសាមគ្គីសព្វថ្ងៃនេះ។

តាមរយៈការខិតខំប្រកាសដំណឹងល្អរបស់សាសនទូតពីក្រុងប៉ារីស បានបង្កើតព្រះសហគមន៍ នៅតំបន់នោះនៅឆ្នាំ ១៨៦២ នៅសម័យលោកអភិបាលហ្សង់ ខ្លូត មីស្ស (Jean-Claude Miche, 1850 –1869) ដែលមានគ្រីស្តបរិស័ទភាគច្រើនជាវៀតណាម។ លោកបូជាចារ្យ និងគ្រីស្តបរិស័ទបានដាំដើមឫស្សីពណ៌បន្ថែមទៀតនៅក្នុងព្រះវិហារ។ នៅសម័យនោះអ្នកទទួលមើលការខុសត្រូវព្រះសហគមន៍ គឺជាលោកបូជាចារ្យបរទេសសាសនទូតជាច្រើន ហើយមានគ្រីស្តបរិស័ទនៅព្រះវិហារនេះឡើងដល់មួយម៉ឺននាក់។ រហូតដល់ឆ្នាំ ១៩៧០

ជនជាតិវៀតណាមទាំងនោះត្រូវបង្ខំចិត្ត ឲ្យចាកចេញពីទឹកដីដែលពួកគាត់ធ្លាប់រស់នៅរាប់រយឆ្នាំ ដោយបោះចោលផ្ទះរបស់ជីដូនជីតាទៅរស់នៅ នៅប្រទេសវៀតណាម។

នៅពេលនោះចាប់ពីខែមិថុនា ដល់ ខែសីហា ឆ្នាំ ១៩៧០ ជនជាតិវៀតណាមត្រូវប្រមូលនៅ ៣ កន្លែងធំៗ គឺ នៅព្រះវិហារឫស្សីកែវចំនួន ២ម៉ឺននាក់ នៅទេវវិទ្យាល័យផ្សារតូច ១៣,០០០ នាក់និង សាលារៀនបងស្រីឧបការគុណ ១៦,០០០ នាក់ ហើយត្រូវបញ្ជូនទៅវៀតណាមវិញ។

ការបញ្ជូនជើងចុងក្រោយនៅខែកញ្ញា មានប្រហែល៣០០នាវា នាំពួកគេចេញទៅតាមដងទន្លេមេគង្គ ទៅដាក់នៅ ត្រាណោក (Trà Nóc -Cần Thơ) និងវាចឹមើយ(và Chợ Mới-An Giang)។

មាន បូជាចារ្យម្នាក់ ដែលគួរឲ្យចងចាំគឺ លោកពុក យ៉ូអាគីម ហូ វ៉ាងឡាត (Gioakim Hồ Quang Luật) បានប្រមូលគ្រីស្តបរិស័ទដែលចេញពីខណ្ឌឫស្សីកែវ ដែលខ្ចាត់ខ្ចាយ នៅតំបន់ផ្សេងៗគ្នា ប្រហែល ២០០ គ្រួសារ មករស់នៅក្នុងតំបន់ព្រៃជិតភ្នំជីចាន (Chứa Chan) នៅភូមិភាគស្ទួងឡុក ហើយបង្កើតព្រះសហគមន៍ស៊ួយកាតទី ១ ដោយរក្សាឈ្មោះ "ឫស្សីកែវ" បន្តជីវិតព្រះសហគមន៍ដែលមកពីកម្ពុជា។ ក្រៅពីគ្រួសារនីមួយៗត្រូវតស៊ូតាំងទីលំនៅផ្ទាល់ខ្លួននៅទីនោះ លោកយ៉ូអាគីម បានប្រមូលគ្រីស្តបរិស័ទជួយគ្នាសាងសង់ព្រះវិហារពីឫស្សី ប្រកគង់ពណ៌ខៀវ ដើម្បីប្រារព្ធបុណ្យព្រះយេស៊ូប្រសូតនៅឆ្នាំ១៩៧០។

ព្រះវិហារទីពីរ សាងសង់ពីឈើនៅឆ្នាំ ១៩៧២ ដោយអ្នកភូមិនិងយុវជន។ បន្តិចម្តងៗ ព្រះសហគមន៍បានរៀបចំរចនាសម្ពន្ធមានគណៈកម្មការ។ ចាប់ពីឆ្នាំ ១៩៩៣ គណៈកម្មការបានរៀបចំឡើង ហើយទទួលស្គាល់ពីភូមិភាគ។

លោកពុកយ៉ូអាគីម បានណែនាំថែទាំ អប់រំគ្រីស្តបរិស័ទក្នុងសភាពការដ៏លំបាកខាងសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយ ព្រះវិហារក្នុងព្រះសហគមន៍គឺ កន្លែងលើកទឹកចិត្តពួកគេ។ លោកយ៉ូអាគីម ទោះបីសុខភាពខ្សោយ តែលោកហ៊ានសម្រេចចិត្តកសាងព្រះវិហារថ្មី ដែលជាព្រះវិហារសព្វថ្ងៃនេះ នៅឆ្នាំ ២០០២ ហើយលោកបានចូលនិវត្តន៍។

លោកបូជាចារ្យថ្មីដែលមកបន្តបេសកកម្មនៅទីនេះ គឺលោកពុក យ៉ូហាន បាទីស្ត ង៉ូ វ៉ាន់ បាវ (Ngô Văn Bao) លោកបន្តជំរុញគ្រីស្តបរិស័ទរួមដៃគ្នាសាងសង់រហូតបានចប់សព្វគ្រប់។



*លោកបូជាចារ្យដាវីឌ លោកអភិបាលស៊ូសេ ឌីង ឌុក ដាវ និងលោកបូជាចារ្យរឿង ឆ័ត្រសិរី។*

ហើយបានសម្ពោធ នៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤។ លោកពុកមានសកម្មភាពជាច្រើនទៀត ដើម្បីឆ្លើយតបសេចក្តីត្រូវការខាងផ្លូវវិញ្ញាណ និងខាងសង្គមសម្រាប់កូនក្មេង និងអ្នកក្រីក្រ។

នៅឆ្នាំ ២០១៣ ព្រះសហគមន៍នេះបានប្រារព្ធខួបគម្រប់ ១៥០ឆ្នាំ របស់ព្រះសហគមន៍ ដែលកកើតឡើង តាំងពីក្នុងទឹកដីកម្ពុជា រហូតដល់មកតាំងទីលំនៅថ្មីនៅវៀតណាមនេះ។

លោកបូជាចារ្យ ប៉ូល សុង ថាញ់ ហ្វុង (Dong Thành phong) ជាអ្នកទទួលខុសត្រូវថ្មី បានសហការជាមួយគ្រីស្តបរិស័ទសាងសង់អាគារសម្រាប់ការណែនាំថែទាំព្រះសហគមន៍ហើយបានសម្ពោធ នៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៧។

ថ្ងៃនេះគឺទី ១ ខែមករា ឆ្នាំ ២០២០ រួមជាមួយព្រះនាងម៉ារី ដែលជាមាតាព្រះជាម្ចាស់ ព្រះសហគមន៍ឫស្សីកែវនេះ បានប្រារព្ធបុណ្យគម្រប់ខួប ៥០ ឆ្នាំ របស់ព្រះសហគមន៍នេះដែលមានវត្តមាននៅវៀតណាម ក្រោមអធិបតីភាពលោកអភិបាលស៊ូសេ ឌីង ឌុក ដាវ (Giuse Đinh Đức Đạo) ព្រមទាំងបូជាចារ្យជិត ២០ អង្គ និងគ្រីស្តបរិស័ទប្រហែល ២០០០ នាក់។

បច្ចុប្បន្ននេះ ព្រះសហគមន៍ឫស្សីកែវ នៅ ស៊ួយកាតទី ១ នេះ មានគ្រីស្តបរិស័ទជិត ៨០០០ នាក់ នៅភូមិស៊ួយកាត ស្រុកស្ទួនឡុក ខេត្តដងណាយ ប្រទេសវៀតណាម៕



*ទីសក្ការដ្ឋានគោរពព្រះនាងម៉ារីនៅបរិវេនព្រះវិហារឫស្សីកែវនៅវៀតណាម។*





# ព្រះសង្ឃ និងគណៈកម្មការ អាចារ្យវត្តជូនពរបុណ្យព្រះយេស៊ូប្រសូត

*ដោយ៖ លី សុវណ្ណា*

ព្រះសង្ឃ គណៈកម្មការ អាចារ្យវត្តអង្គមន្ត្រី ស្ថិតក្នុងស្រុកត្រាំកក់ នាខេត្តតាកែវ បាននិមន្ត និងអញ្ជើញមកកាន់ព្រះវិហារសន្តីម៉ារីញញឹម នៃព្រះសហគមន៍កាតូលិកភូមិចំការទៀង ដើម្បីអបអរសាទរ និងជូនពរក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត នៃរសៀលថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១៩នេះ។

ក្នុងជំនួបបែបកិច្ចសន្ទនាអន្តរសាសនា ដើម្បីសេចក្តីសុខដុមរមនានេះត្រូវបានទទួលប្រកបដោយភាពកក់ក្តៅបំផុតពីសំណាក់លោក កុល ជាង ប្រធានគណៈកម្មការព្រះសហគមន៍កាតូលិកចំការទៀង និង លោក អូលីវីយេ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។





*លោក អូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញជួបសំណេះសំណាលជាមួយព្រះសង្ឃ គណៈកម្មការ អាចារ្យវត្តអង្គមន្ត្រី។ រូបភាពៈ ស៊ីអេសស៊ី*

ប្រធានគណៈកម្មការវត្តអង្គមន្ត្រី លោកវណ្ណាបានប្រសាសន៍ថា នៅថ្ងៃនេះ ជាថ្ងៃបុណ្យព្រះយេស៊ូប្រសូត យ៉ាងឱឡារិក ដែលគ្រីស្តបរិស័ទប្រារព្ធ ហើយគណៈកម្មការវត្តចូលរួមមិនដែលខកខាន។ ដូច្នេះ គណៈកម្មការវត្តអង្គមន្ត្រីមាន ជាសម្ភារ មានទាំងអំបុក ផ្លែដូង អង្ករ និង ថវិកាប្រមាណ៤០ម៉ឺនរៀល ដែលលោកយាយលោកតា និងសិស្សសាលាអង្គមន្ត្រីចូលរួមគ្នា មកជូន និងអបអរសាទរ បុណ្យដោយអំណរសប្បាយ រួមជាមួយព្រះសហគមន៍កាតូលិក។

លោកបន្តទៀតថា អ្វីៗទាំងអស់នេះគិតទៅតិចតួចណាស់ចំពោះអ្វីដែលលោកអភិបាលអូលីវីយេ បានចូលរួមឧបត្ថម្ភ គាំទ្រដល់វត្តអង្គមន្ត្រី ជាច្រើនឆ្នាំកន្លងមកហើយនេះ ស្ទើរគ្រប់កម្មវិធីបុណ្យធំក្នុងវត្តអង្គមន្ត្រី។

លោក វណ្ណាបន្តថា ដូច្នេះតាំងនាមឲ្យព្រះសង្ឃ និងគណៈកម្មការវត្តព្រមទាំងសាលាអង្គមន្ត្រីដែលបានមានទំនាក់ទំនង ភ្ជាប់សាច់ ភ្ជាប់ឈាម និងសម្ពន្ធមេត្រីជាមួយព្រះសហគមន៍កាតូលិក ហើយឆ្នាំនេះជាកិត្តិយសណាស់ដែលគណៈកម្មការបានធ្វើកិច្ចថ្លែងអំណរគុណ ចំពោះលោកអភិបាល។

លោកអភិបាល តែងតែមានទំនាក់ទំនង និងគាំទ្រវត្តអង្គមន្ត្រី តាំងពី២០០២មក តាំងតែពីលោកនៅជាបូជាចារ្យ។ ថ្មីៗនេះលោកអភិបាលបានទទួលមេដាយមាសស្ថាបនាជាតិពីរាជរដ្ឋាភិបាល ដែលបានស្នើសុំដោយវត្តនេះផ្ទាល់។

ក្នុងឱកាសដ៏វិសេសវិសាលនេះ លោកវណ្ណា សូមព្រះប្រទានពរដល់លោកអភិបាល និងសហការី សូមជួបតែសេចក្តីគ្រប់ប្រការ។

ក្នុងកិច្ចសន្ទនានេះដែរ លោកអភិបាលអូលីវីយេ ក៏បានមានប្រសាសន៍ អរគុណ ព្រះសង្ឃ និងគណៈកម្មការវត្តអង្គមន្ត្រី ដែលបានរៀបចំដើម្បីរាជរដ្ឋាភិបាល ប្រគល់មេដាយមាស ស្ថាបនាជាតិជូនដល់លោក។ អរគុណចំពោះការជូនពរ និងជូនរូបសំណាកព្រះពុទ្ធដ៏ស្រស់ស្អាតដែលមកពីប្រទេសឥណ្ឌា ពីសំណាក់ចៅអធិការវត្តអង្គមន្ត្រី។ លោកបានបន្តថា ក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត លោកបានជួបបងប្អូនជាច្រើន ទាំងពុទ្ធបរិស័ទ ឥស្លាមបរិស័ទ និងទាំងគ្រីស្តបរិស័ទ ជាឱកាសដើម្បីចែកសេចក្តីសុខអំណរសប្បាយ និងជីវិតរបស់យើងដែលចង់កសាងសេចក្តីសុខ។ ថ្ងៃនេះនៅក្នុងព្រះវិហារកាតូលិក សូមឲ្យយើងទាំងអស់គ្នាបានចម្រើនពរ ថែមទៀត ដើម្បីកសាងស្រុក និងភូមិរបស់យើង។

លោកអភិបាល ក៏បានអញ្ជើញគណៈកម្មការវត្ត ដើម្បីចូលរួម កម្មវិធីប្រកួតខ្លែងឯក លើកទី១០ដែលរៀបចំដោយ គណៈកម្មការព្រះសហគមន៍កាតូលិកភូមិចំការទៀង នាថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ខាងមុខនេះ៕

# លោកយាយលោកតាជាង១០០ នាក់ចូលរួមអបអរបុណ្យព្រះយេស៊ូប្រសូត

*ដោយ៖ លី សុវណ្ណា*

លោកយាយ លោកតាចំនួន១០៥ នាក់ មកពីភូមិនានាក្នុងឃុំគូស បានអញ្ជើញចូលរួមទទួលអំណរសប្បាយ រួមជាមួយគ្រីស្តបរិស័ទព្រះសហគមន៍កាតូលិក ព្រះវិហារសន្តីញញឹម ភូមិចំការទៀង ស្រុកត្រាំកក់ ខេត្តតាកែវ នាព្រឹកថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩។

មានប្រសាសន៍ក្នុងពិធីនេះលោក អ៊ឹន ធីវ តំណាងគណៈកម្មការសង្គហៈព្រះសហគមន៍ព្រះវិហារសន្តីម៉ារីញញឹម បានឲ្យដឹងថា៖ « ក្រុមសង្គហៈនៃព្រះសហគមន៍កាតូលិកភូមិចំការទៀង មានសមាជិកចំនួន ១០នាក់ បានចែកជាប្រាំក្រុម ដើម្បីទៅសួរសុខទុក្ខបងប្អូនតាមភូមិនានា ដែលគេរស់នៅ មានចាស់ជរា អ្នកជំងឺ បងប្អូនក្រីក្រខ្វះខាត ជនមានពិការភាពជាដើម។ ជារៀងរាល់ខែ យើងបានឧបត្ថម្ភខ្លះៗ ដល់បងប្អូនមួយចំនួនតាមលទ្ធភាពរបស់ព្រះសហគមន៍យើង និងបានជួយសង់ផ្ទះ បង្គន់អនាម័យមួយចំនួនដែរ»។

លោកបន្តថា៖ «ជាងនេះទៅទៀត ក្នុងកាសបុណ្យណូអែល (បុណ្យព្រះយេស៊ូប្រសូត) ដោយមានជំនួយសង្គហៈពីព្រះសហគមន៍ ដែលមានការគាំទ្រយ៉ាងពេញទំហឹងពីលោកអភិបាល អូលីវីយេ ក្រុមសង្គហៈយើងបានទៅតាមភូមិសួរសុខទុក្ខ និងបានប្រជុំ ជ្រើសរើសលោកយាយ លោកតា និងបងប្អូនក្រីក្រខ្វះខាតមួយចំនួន ដើម្បីជួយឧបត្ថម្ភនៅក្នុងរដូវបុណ្យព្រះយេស៊ូប្រសូត»។

លោកតំណាង ក្រុមសង្គហៈ បញ្ជាក់បន្ថែមថា៖ «ពិតមែន លោកយាយ លោកតា និងបងប្អូនទាំងអស់មានអំណរសប្បាយខ្លាំងដោយព្រះសហគមន៍យកចិត្តទុកដាក់ជាមួយពួកគាត់។ ចំណែកយើងទាំងអស់ដែលបំពេញកិច្ចការនេះ ក៏មានអំណរសប្បាយចែករំលែកជាមួយបងប្អូន ដោយចេញពីចិត្ត និងជំនឿលើព្រះយេស៊ូ ។ ដោយសារ ជំនឿលើព្រះយេស៊ូ ដែលជំរុញយើងឲ្យបំពេញកិច្ចទាំងនេះ ជាជំនឿចេញពីដួងចិត្តរបស់យើងម្នាក់ៗ»។

លោកអភិបាលអូលីវីយេ ដែលជាអធិបតី មានប្រសាសន៍សំណេះសំណាលជាមួយលោកតា លោកយាយ និងបងប្អូនថា៖ «ខ្ញុំគាំទ្រ ចំពោះសេចក្តីបញ្ជាក់របស់តំណាងក្រុមសង្គហៈព្រះសហគមន៍។ ជាការពិត ជារៀងរាល់ខែ ព្រះសហគមន៍បានជួយឧបត្ថម្ភបងប្អូន ចំនួនជាង១០គ្រួសារ ផ្ទះក៏បានធ្វើជូនច្រើនដែរ។ នេះជាសញ្ញាសំគាល់នៃព្រះសហគមន៍ដែលចេះតែយកចិត្តទុកដាក់ ចំពោះគ្នាទៅវិញទៅមក ទោះបីមិនអាចសង្គ្រោះមនុស្សទាំងអស់ តែអាចជួយខ្លះបាន»។

លោកអភិបាលក៏បានជូនពរដល់លោកយាយ លោកតា ក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូតនេះ សូមឲ្យមានសុខភាពល្អ មានកំលាំងកាយកំលាំងចិត្តជានិច្ច ដើម្បីអប់រំណែនាំកូនចៅ ព្រោះគេចង់ស្តាប់នូវពាក្យពេជ្រទូន្មាន ដើម្បីឲ្យមានពន្លឺក្នុងដួងចិត្ត និងទៅជាមនុស្សដ៏ល្អ។

ជាមួយគ្នានេះ លោកអភិបាលក៏បានរំលឹកលោកយាយ លោកតា និងបងប្អូនទាំងអស់ ឲ្យមានការយកចិត្តទុកដាក់ថែរក្សាសុខភាព និងទទួលទានឲ្យបានត្រឹមត្រូវ មិនប្រើគ្រឿងទេសដែលមានគីមីច្រើន និងសូមយកចិត្តទុកដាក់បង្ករបង្កើនផល ដាំដំណាំ បន្លែ ផ្លែឈើ



*លោកអភិបាល អូលីវីយេ អបអរបុណ្យព្រះយេស៊ូប្រសូតជាមួយលោកយាយ លោកតាជាង១០០នាក់។ រូបភាពៈ ស៊ីអេសស៊ី*

តាមសលក្ខណៈធម្មជាតិ ដោយមិនប្រើជីគីមីច្រើនលើលកម្រិតខ្លាំង ដែលបំផ្លាញសុខភាពរបស់មនុស្ស។ សូមជួយកូនចៅ ឲ្យរក្សាទម្លាប់ដែលលោកយាយ លោកតាបានធ្វើពេលកន្លងមក ដោយប្រើជីធម្មជាតិ។

ក្រោយពីសំណេះសំណាល និងបានស្តាប់ចម្រៀងអំពីបុណ្យព្រះយេស៊ូប្រសូត លោកយាយ លោកតា បានទទួលទានអាហារយ៉ាងឆ្ងាញ់រួមគ្នា និងទទួលបានសម្ភារប្រើប្រាស់មួយចំនួន និងគ្រឿងឧបភោគបរិភោគ មានអង្ករជាដើម ព្រមទាំងបច្ច័យមួយចំនួនផងដែរ។

ក្នុងអំឡុងពេលនេះ គ្រីស្តបរិស័ទគ្រប់និកាយក្នុងពិភពលោកកំពុងចែករំលែកអំណរសប្បាយ និងប្រារព្ធបុណ្យព្រះយេស៊ូប្រសូត។ តាមពិតយើងពិតជាមិនដឹងថាព្រះយេស៊ូប្រសូតនៅថ្ងៃណាច្បាស់លាស់ទេ ប៉ុន្តែអ្នកប្រវត្តិសាស្ត្រព្រះសហគមន៍បានកំណត់យកថ្ងៃទី២៥ ខែធ្នូ ជារៀងរាល់ឆ្នាំ ជាថ្ងៃប្រារព្ធបុណ្យកំណើតព្រះយេស៊ូ ដែលជាព្រះអម្ចាស់បានប្រសូតជាមនុស្ស។ ព្រះអង្គប្រសូតសម្រាប់មនុស្សទាំងអស់ និងនាំអំណរដល់មនុស្សគ្រប់ជាតិគ្រប់សាសន៍។ ព្រះសហគមន៍ភូមិភាគភ្នំពេញបានបន្តកិច្ចការទាំងនេះជាប់ជានិច្ច។ រីករាយបុណ្យព្រះយេស៊ូប្រសូត!៕

# អង្គការជេស្វីតសឺវីសកម្ពុជារំលឹក ខួបទី២៥ឆ្នាំ នៃវត្តមាននៅក្នុងប្រទេសកម្ពុជា



*លោកអភិបាល អេនរីកេ ហ្វីការេដូ ក្នុងពិធីរំលឹកខួបទី២៥ឆ្នាំអង្គការជេស្វីតសឺវីសកម្ពុជា។*

នៅថ្ងៃទី១៥វិច្ឆិកានេះ សមាជិកមន្ត្រីអង្គការជេស្វីតសឺវីសកម្ពុជា (JSC) បានរៀបចំកម្មវិធីខួប២៥ឆ្នាំដែលស្ថាបននេះមានវត្តមាននៅក្នុងប្រទេសកម្ពុជាក្រោមអធិបតីរបស់ លោក អ៊ូអ៊ីនដុន ប្រធានក្រុមបព្វជិត សហជីវិនព្រះយេស៊ូនៅកម្ពុជា លោកអភិបាលអេនរីគេ ហ្វីកាវេដូ អមជាមួយលោកបូជាចារ្យប្រធានអង្គការ JSC ប្រចាំប្រទេសកម្ពុជា កាព្រីអែល ឡាមុហ្គណាយ៉ាវ៉ា និងតំបន់ រួមនឹងភ្ញៀវជាតិនិងអន្តរជាតិប្រមាណជាង២០០នាក់ នៅមណ្ឌលមេត្តាករុណា ស្ថិតនៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប។

លោកបូជាចារ្យកាព្រីអែល ឡាមុហ្គណាយ៉ាវ៉ា ជាប្រធានប្រចាំប្រទេសកម្ពុជាបានឲ្យដឹងថា អង្គការជេស្វីត បានមានសកម្មភាពជាមួយប្រជាជនកម្ពុជាជាយូរមកហើយគឺប្រហែល ៣០ឆ្នាំ ដោយធ្វើការងារនៅជំរំខ្មែរថៃ។ អង្គការនេះបានចូលមកក្នុងប្រទេសកម្ពុជាអំឡុងឆ្នាំ១៩៩៤ ដោយផ្ដោតសំខាន់ទៅលើសម្មភាពជួយអ្នកក្រីក្រ និងជនពិការដោយសារសង្គ្រាម។

លោកបូជាចារ្យ កាព្រីអែល «ដូច្នេះការងារដំបូង ដែលJRS, JSC បានធ្វើជាបន្ទាយព្រាបជាសាលាបណ្ដុះបណ្ដាលសម្រាប់អ្នករងគ្រោះដោយសារសង្គ្រាម ប៉ុន្តែរហូតមកដល់សព្វថ្ងៃនេះ សាលានោះមានផ្នែកមួយចំនួនសម្រាប់ជនមានពិការភាពផងទាក់ទងនឹងរាងកាយ និងខ្សោយសតិបញ្ញា។ ក្រៅពីការងារនេះ យើងមានសកម្មភាពមួយចំនួទាក់ទងនឹងការអភិវឌ្ឍជនបទ សុខភាពត្រចៀក អប់រំ និងបរិស្ថាន»។

លោកបូជាចារ្យរូបនេះ បន្ថែមថា សម្រាប់វគ្គបណ្ដុះបណ្ដាលលោកបានសង្កេតឃើញថា យុវជនកម្ពុជាបានផ្លាស់ប្ដូរឥរិយាបទមួយចំនួនពីអវិជ្ជមានទៅជាវិជ្ជមាន។ លោកបូជាចារ្យកាព្រីអែល «ពេលគាត់ចូលរៀនខែ១ខែ២ ពួកគាត់អត់ស្ទូវបានចេញពីភូមិ ពួកគាត់អត់មានទំនុកចិត្តនិងឲ្យតម្លៃខ្លួនឯងផង ក្រោយពេលបានចូលបន្ទាយព្រាបហើយ រៀន ការរស់នៅជាមួយគ្នាដល់ពេលបិទវគ្គ ពួកគាត់ដូចសប្បាយជាងមុន មានកំលាងចិត្តជាងមុន មានសង្ឃឹម ហើយទៅអនាគតដូចជាមានសង្ឃឹមនិងមានពន្លឺ ដូចជាមានប្រសិទ្ធភាព»។

អង្គការជេស្វីតសឺវីសកម្ពុជាមានការិយាល័យចំនួន៦ និងបំពេញបេសកកម្មរបស់ខ្លួនក្នុងខេត្តចំនួន៨ ដូចជា ភ្នំពេញ កណ្ដាល កំពង់ស្ពឺ កំពង់ឆ្នាំង សៀមរាប កំពង់ធំ បាត់ដំបង និងបន្ទាយមានជ័យ។

ក្នុងរយៈពេល២៥ឆ្នាំនេះ អង្គការនេះ មានបណ្ដុះបណ្ដាលសិស្សពិការចំនួន២៨១០នាក់ ជួយជនពិការសតិបញ្ញាចំនួន១៧នាក់ និងបានជួយដល់កុមារនិងសិស្សពិការជាច្រើនឲ្យបញ្ចប់ការសិក្សា។ ករណីខ្លះបានសង់ផ្ទះជូនគ្រួសារក្រីក្រ ផ្ដល់ដើមទុនបង្កើតអាជីវកម្មខ្នាតតូច អណ្ដូងទឹក បង្គន់អនាម័យ និងឧបត្ថម្ភការសិក្សារបស់កូនៗរបស់ពួកគាត់ជាដើម។ អង្គការនេះ ក៏បានផ្ដល់រទេះដល់ជនពិការចំនួន២៥,១៦១គ្រឿង និងបានបង្កើតមណ្ឌលថែទាំកុមារពិការឈ្មោះពន្លឺនៃមេត្តាដែលសព្វថ្ងៃនេះ មានកុមារចំនួន៣២នាក់កំពុងស្នាក់នៅ។


*អង្គការជេស្វីតសឺវីស បានផ្ដល់នូវបណ្ណសរសើរនិងវត្ថុអនុស្សាវរីយ៍លើកទឹកចិត្តដល់បុគ្គលិក។*

លោកអភិបាលអេនរីកេហ្វីកាវេដូអភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ដែលធ្លាប់បានបម្រើកិច្ចការងារជាច្រើនតាមរយៈអង្គការនេះជាមួយប្រជាជនខ្មែរតាំងពីនៅជំរំជនភៀសខ្លួនរហូតមកដល់ពេលនេះមានប្រសាសន៍ថា អង្គការនេះ បានចូលរួមយ៉ាងសកម្មក្នុងយុទ្ធនាការលុបបំបាត់គ្រាប់មីន ដើម្បីឲ្យរដ្ឋាភិបាលខ្មែរចូលរួម និងឲ្យពិភពលោកដឹងអំពីបញ្ហាដែលកើតមាននៅក្នុងប្រទេសនេះ ហើយកុំឲ្យកើតមានបញ្ហានេះនៅប្រទេសដទៃទៀត។ត្រង់ចំណុចនេះលោកអភិបាលបានសង្កត់ធ្ងន់ថា អង្គការនេះបានទទួលជោគជ័យច្រើន។

លោកអភិបាលអេនរីកេ «អ្វីដែលនាំឲ្យយើងជោគជ័យ គឺអ្វីដែលយើងបានទំនាក់ទំនងជាមួយជនពិការ និងទំនាក់ទំនងជាមួយរដ្ឋាភិបាល និងទំនាក់ទំនងជាមួយសមាគមនិងអង្គការនានាដែលយើងមាន ដើម្បីជួយជនពិការមានជីវិតប្រសើរជាង និងឲ្យយើងផ្លាស់ប្ដូរច្បាប់នៅក្នុងពិភពលោក»។

លោកអភិបាលបានបន្ថែមទៀតថា ក្នុងរយៈពេល៣០ឆ្នាំទៅមុខទៀត តាមរយៈបទពិសោធជាមួយជនពិការ អង្គការជេស្វីតសឺវីសចង់ចូលរួមកសាងប្រទេសក្នុងទស្សនៈផ្ដល់ការអប់រំ ដោយមិនត្រឹមតែកសាងសាលារៀនប៉ុណ្ណោះ ប៉ុន្តែត្រូវគិតអំពីសហគមន៍ និងព្រះសហគមន៍ ដើម្បីឲ្យមនុស្សអាចចេះថ្លឹងថ្លែង និងបែងចែកអ្វីដែលល្អ និងមិនល្អ។

លោកអភិបាលមានប្រសាសន៍យ៉ាងនេះថា៖ «ប៉ុន្តែនៅពេលយើងគិតអំពីអប់រំ យើងមិនគិតតែសាលារៀន គិតអំពីសង្គម គិតអំពីសហគមន៍ដែលមាននៅតាមភូមិ អំពីព្រះសហគមន៍ ដែលឲ្យមានអប់រំល្អ ដែលឲ្យយើងស្គាល់អ្វីដែលត្រូវ អ្វីដែលខុស អ្វីដែលយើងត្រូវជ្រើសរើស អ្វីដែលយើងត្រូវបដិសេធ។ ហើយឲ្យយើងកសាងសង្គមមួយដែលមានយុត្តិធម៌សម្រាប់អ្នកក្រីក្រ ហើយឲ្យទាំងអស់គ្នាចូលរួមបាន ជាពិសេសអ្នកក្រីក្រ»។

លោកបូជាចារ្យតូតែត បាណោណាល់ធ្លាប់បម្រើការងារនៅអង្គការជេស្វីតសឺវីសកាលពី២៥ឆ្នាំមុន មានប្រសាសន៍ថា លោកសូមអរគុណព្រះជាម្ចាស់ដែលឱកាសដល់លោកសហការជាមួយបុគ្គលិកនិងប្រជាជនកម្ពុជា។ លោកបូជាចារ្យរូបនេះបន្តថា «ការងាររបស់អង្គការគឺលើកស្ទួយតម្លៃនៃជីវិតរបស់មនុស្ស និងសេចក្ដីថ្លៃថ្នូររបស់មនុស្សជាបុត្រធីតារបស់ព្រះជាម្ចាស់...។ ខ្ញុំជាម្នាក់ដែលមកដើម្បីចូលរួមជាមួយបងប្អូនគឺដើម្បីដើរជាមួយបងប្អូន ឲ្យបងប្អូនដឹងថាក្នុងជីវិតនេះ គេមិនម្នាក់ឯងទេ។ គេមានមិត្តភក្តិដែលហ៊ានដើរជាមួយគាត់»។ លោកបន្តថា ប្រជាជនខ្មែរបានបង្រៀនលោកឲ្យស្គាល់អំពីជីវិត។ «អ្វីៗដែលខ្ញុំអភិវឌ្ឍ ដោយសារបងប្អូនខ្មែរបង្រៀនខ្ញុំ។ ខ្ញុំយល់ច្រើនអំពីជីវិត»។

មុនពេលបិទបញ្ចប់កម្មវិធី អង្គការជេស្វីតសឺវីស បានផ្ដល់នូវបណ្ណសរសើរនិងវត្ថុអនុស្សាវរីយ៍លើកទឹកចិត្តដល់បុគ្គលិករបស់ខ្លួនដែលបានធ្វើការជាច្រើនឆ្នាំ និងបានលះបង់កាយចិត្តនិងកំលាំងដើម្បីឲ្យកម្មវិធីនីមួយៗរបស់អង្គការនេះអាចដំណើរការទៅមុខបាន៕


*ភ្ញៀវជាតិ និងអន្តរជាតិប្រមាណជាង២០០នាក់ចូលរួមក្នុងពិធីរំលឹកខួប២៥ឆ្នាំអង្គការជេស្វីតសឺវីស។*


*បុគ្គលិករបស់អង្គការជេស្វីតសឺវីសថតរូបអនុស្សាវរីយ៍។*





# កុមារប្រមាណ៣០០០នាក់ ទទួលអំណរសប្បាយ បុណ្យកំណើតព្រះយេស៊ូ

*ដោយ៖ លី សុវណ្ណា*

កុមារាកុមារីមកពីភូមិនានា នៅជុំវិញព្រះសហគមន៍កាតូលិកព្រះវិហារសន្តីម៉ារីញញឹម ប្រមាណ៣០០០នាក់ ជួបជុំគ្នាក្នុងពិធីបុណ្យព្រះយេស៊ូប្រសូត ប្រកបដោយអំណរសប្បាយ និងរីករាយយ៉ាងក្រៃលែង។

កុមារាកុមារីបានទទួលដំណឹងទាំងអស់អំពីបុណ្យកំណើតព្រះយេស៊ូតាមរយៈក្រុមកាយឫទ្ធិដែលបានប្រាប់មិត្តភក្តិរបស់គេតៗគ្នា នៅតាមសាលាតាមភូមិដែលគេនៅ។


*កុមារាកុមារីមកពីភូមិនានាប្រមាណ៣០០០នាក់ ជួបជុំគ្នាក្នុងពិធីបុណ្យព្រះយេស៊ូប្រសូត។* *រូបភាព៖ ស៊ីអេសស៊ី*

តាមប្រសាសន៍លោកអភិបាលអូលីវីយេ ដែលបានមកដល់ភូមិដ៏តូចមួយ ក្នុងឃុំគួសស្រុកត្រាំកក់នេះ កាលលោកនៅជាបូជាចារ្យវ័យក្មេងម្នាក់បានឲ្យដឹងថា៖ «តាមពិតកម្មវិធីនេះបានចាប់ផ្ដើមតាំងពីឆ្នាំ ២០០៩ ជាមួយនឹងក្រុមកាយឫទ្ធិមួយចំនួន បន្តិចម្ដងៗគេនិយាយតៗគ្នាថាបុណ្យណូអែលបានមកដល់ហើយ។ យើងចែករំលែកអំណរសប្បាយជាមួយគ្នា។ ក្រោយមកគេថា យើងចង់ចូលព្រះវិហារម្ដង ដូច្នេះគេបបួលគ្នាមកហើយពីមួយឆ្នាំទៅមួយឆ្នាំមានចំនួនការកើនឡើងជាលំដាប់ ពី២០០ ៥០០០ ១០០០ ១៥០០ ២០០០ ២៥០០ និងពេលនេះដល់ជិត ៣០០០ ឬ ៣០០០ ហើយ»។

លោកអភិបាលបន្តថា៖ «យើងដឹងថា នេះគឺកូនក្មេងដែលអញ្ជើញគ្នាទៅវិញទៅមក ដើម្បីមកអបអរសាទរព្រះយេស៊ូប្រសូត។ ខ្លះជាមេកកាយឫទ្ធិ និងជាយុវជនដែលមានទំនាក់ទំនងនៅក្នុងភូមិ ដើម្បីចែកអំណរសប្បាយនៅបុណ្យអែលព្រះយេស៊ូប្រសូត»។

លោកអភិបាលបានបញ្ជាក់ថា ព្រះយេស៊ូប្រសូតមិនមែនសម្រាប់តែគ្រីស្តបរិស័ទ មិនមែនសម្រាប់តែគ្នាយើង ប៉ុន្តែព្រះយេស៊ូប្រសូតសម្រាប់ជាពន្លឺដើម្បីបំភ្លឺមនុស្សទាំងអស់។

លោកអភិបាលបន្តថា៖ «នៅទីនេះ កុមារបានឃើញការសម្ដែងអំពីព្រះយេស៊ូប្រសូត គេច្រៀងបទចម្រៀងសរសើរផង នាំឲ្យនឹកឃើញដល់អំពីជីវិតរបស់គេ។ ខ្លះទៀតបាននឹកឃើញថា គេមិនឯកោ ហើយគេមានគ្រួសារមួយដែលមានចំនួនរាប់ពាន់នាក់ មានបងៗ មានមនុស្សពេញវ័យជាមនុស្សចាស់ ដែលឃើញកូនយើងជាអ្នកជំនាន់ក្រោយជាកម្លាំង ដើម្បីកសាងប្រទេសកម្ពុជាមែន ដើម្បីឲ្យស្រុករបស់យើងរីកចម្រើនតទៅទៀត»។

កុមារាកុមារីទាំងនោះខ្លះបានមកតាំងពីព្រលឹម ដោយចិត្តអន្ទះសារ ក្នុងការចូលរួម និងចង់មើលការសម្ដែងអំពីកំណើតព្រះយេស៊ូផង។

កុមារភារី ដែលមកដល់ព្រះវិហារតាំងពីមុនម៉ោង៦ព្រឹកបាននិយាយថា៖ «ខ្ញុំក្រោកតាំងពីព្រលឹម រួមជាមួយប្អូននិងមិត្តភក្តិ៣នាក់ទៀតជិះកង់ចេញពីផ្ទះ ដើម្បីមកព្រះវិហារនេះ ដើម្បីចូលរួមបុណ្យណូអែល។ ម៉ែ និងឪមិនថាអីទេ។ ខ្ញុំបានសុំគាត់ហើយ»។ ភារីបន្តថា គេធ្លាប់ចូលរួមពីរដងហើយ ពិតជាសប្បាយណាស់។

ក្នុងពេលជួបជុំនេះដែរ ក៏មានសម្ដែងអំពីកំណើតព្រះយេស៊ូដោយកុមារាកុមារី សិស្សសាលាមត្តេយ្យសន្តប្រេង់ស្វ័រ ឲ្យកុមារទាំងអស់បានទស្សនា ព្រមទាំងចែកវត្ថុអនុស្សាវរីយ៍អប់អរសាទរបុណ្យព្រះយេស៊ូប្រសូតដល់កុមាទាំងនោះម្នាក់មួយកញ្ចប់ផងដែរ។

លោកអភិបាលអូលីវីយេមានប្រសាសន៍ដែរថា អ្វីៗដែលរៀបចំចែករំលែកអំណរសប្បាយជាមួយកុមារប្រមាណ៣០០០ ដោយអលូននិងអំណរសប្បាយ ដោយសារការចេះសហការណ៍គ្នាទៅវិញទៅមក ជាលក្ខណៈគ្រួសារ។ ពិតជាពិសេសណាស់។

លោកបានលើកនូវទស្សនៈដែលលោកតែងអប់រំត្រូវប្រកាន់យកគឺ មេត្តាករុណា ឧត្ដមភាព និង គុណភាព៕

# បុណ្យព្រះយេស៊ូប្រសូតនាំយើងឲ្យមានតួនាទីពិសេស

*ដោយ៖ កែវ កញ្ញា*

ក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត នាថ្ងៃទី២៥ ខែធ្នូ កន្លងទៅ លោកអភិបាលគីគេ ហ្វីការេដូ អភិបាលនៃព្រះសហគមន៍ភូមិភាគបាត់ដំបង ជំរុញឲ្យគ្រីស្តអធិដ្ឋាន និងប្រកាសដំណឹងល្អដល់អ្នកដែលមិនទាន់ជឿ។


*លោកអភិបាលគីគេ ហ្វីការេដូ និងបងប្អូនគ្រីស្តបរិស័ទក្នុងព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ។* *រូបភាព៖ ស៊ីអេសស៊ី*

លោកអភិបាលមានប្រសាសន៍ក្នុងធម្មទេសនាទៅកាន់គ្រីស្តបរិស័ទនៅព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខប្រមាណជាង២០០នាក់ថា ក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូតនេះ សូមឲ្យយើងយកចិត្តទុកដាក់អធិដ្ឋានអរព្រះគុណព្រះជាម្ចាស់។

លោកបន្តថា ព្រះជាម្ចាស់សព្វថ្ងៃបង្ហាញខ្លួនឲ្យយើងស្គាល់ច្បាស់តាមរយៈវត្តមានរបស់ព្រះយេស៊ូដែលប្រសូតជាមនុស្ស។ ព្រះបិតាបានប្រទានឲ្យយើងនូវព្រះបុត្រាតែមួយឲ្យមនុស្សយើង ដូច្នេះយើងអាចឃើញច្បាស់ព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ ហើយឲ្យយើងឃើញច្បាស់នូវសេចក្ដីស្រឡាញ់របស់ព្រះអង្គ។

លោកអភិបាលថា៖ «យើងត្រូវត្រេកអរ ព្រោះព្រះជាម្ចាស់មកគង់នៅជាមួយយើង និងបង្ហាញឲ្យយើងស្គាល់ថា ព្រះអង្គជានរណា»។

លោកអភិបាលបានប្រៀបធៀបគង្វាលនិងគ្រីស្តបរិស័ទផ្ទាល់ ដែលស្វះស្វែងរកព្រះជាម្ចាស់ដើម្បីថ្វាយបង្គំ។ លោកអភិបាលបន្ថែមថា៖ «សូមឲ្យយើងទទួលព្រះអង្គដោយពិសេសដែលគង់នៅជាមួយយើង»។ លោកបន្តថា ពេលយើងមកបុណ្យព្រះយេស៊ូប្រសូតជារៀងរាល់ឆ្នាំ សូមឲ្យយើងចេះគិតពិចារណា និងអធិដ្ឋាន សូមឲ្យព្រះជាម្ចាស់ប្រសិទ្ធពរក្នុងដួងចិត្តរបស់យើង ដើម្បីឲ្យយើងយល់រឿងអាថ៌កំបាំងនៃការប្រសូតនេះ។

លោកអភិបាល៖ «ព្រះជាម្ចាស់កើតជាមនុស្សសាមញ្ញដូចយើង ក្រដូចយើង ខ្សោយដូចយើង និងយាងមកដើម្បីបង្ហាញព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ និងធម៌មេត្តាករុណាចំពោះយើង»។

លោកអភិបាលរំលឹករឿងនេះ ដើម្បីឲ្យគ្រីស្តបរិស័ទចេះអរព្រះគុណព្រះជាម្ចាស់ និងបន្តអធិដ្ឋាន ដែលនឹងនាំឲ្យយើងយល់អំពីព្រះហឫទ័យរបស់ព្រះអង្គ។

លោកអភិបាលមានប្រសាសន៍ទៀតថា ព្រះជាម្ចាស់កើតជាមនុស្សសម្រាប់ពិភពលោកទាំងមូល សម្រាប់យើងទាំងអស់គ្នា។ ហើយយើងមានសំណាងល្អ ដោយយើងបានទទួលការអប់រំច្រើន ដើម្បីស្គាល់វត្តមានរបស់ព្រះជាម្ចាស់។

លោកបានសង្កត់ធ្ងន់ថា៖ «បុណ្យណូអែលគឺឲ្យយើងទទួលតួនាទីមួយគឺឲ្យបងប្អូន និងមិត្តភក្តិដែលមិនមែនជាគ្រីស្តបរិស័ទ ស្គាល់ព្រះយេស៊ូតាមរបៀបដែលយើងរស់នៅ ការបង្ហាញធម៌មេត្តាករុណា តាមរបៀបដែលយើងធ្វើការ តាមបប្ញូរមាត់ប្រកាសជំនឿ តាមរបៀបដែលយើងរាប់អានគ្នា»។

ក្រោយអភិបូជានាពេលព្រឹក ក៏មាននូវពិធីជ្រមុជទឹកសម្រាប់ទារកនិងកុមារចំនួន១៥នាក់ ក្រោមអធិបតីភាពរបស់លោកអភិបាលគីគេ។ នៅថ្ងៃដដែលនោះ នាពេលល្ងាចព្រះសហគមន៍បានរៀបចំឲ្យមានការប្រគុំតន្ត្រីដើម្បីអបអរសប្បាយក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូតផងដែរ៕

# សកម្មភាពអបអរក្នុងពិធីបុណ្យព្រះយេស៊ូប្រសូត (គ្រីស្តស្មាស់) ប្រចាំឆ្នាំ២០១៩

## បុណ្យព្រះយេស៊ូប្រសូតនៅព្រះសហគមន៍បាត់ដំបងក្រុង ក្នុងភូមិភាគបាត់ដំបង







## បុណ្យព្រះយេស៊ូប្រសូតសម្រាប់កុមារសាលាមត្តេយ្យ នៅព្រះសហគមន៍ខ្នាចរមាស ក្នុងភូមិភាគបាត់ដំបង








## បុណ្យព្រះយេស៊ូ ប្រសូតនៅព្រះសហគមន៍កំពង់ចាមក្រុង ក្នុងភូមិភាគកំពង់ចាម









## បុណ្យព្រះយេស៊ូប្រសូតនៅព្រះសហគមន៍ព្រៃវែង ក្នុងភូមិភាគកំពង់ចាម





## បុណ្យព្រះយេស៊ូប្រសូតនៅព្រះសហគមន៍កំពង់ស្ពឺ ក្នុងភូមិភាគភ្នំពេញ







# អបអរសាទរលោកអភិបាល
# អេនរីគេ ហ្វីហ្គារ៉េដូ

អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ទទួលបានសញ្ញាតិកម្ពុជា
ដោយមាននាមថា **ខេត ច័ន្ទពិសិដ្ឋ** នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៩នេះ ដោយព្រះរាជក្រឹត្យ
នស/រកត/១២១៩/១៨២៥ ចុះព្រះហស្ថលេខាដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី**។



# អបអរសាទរ

ក្លារ៉ា ដួត ស្រីឡៃ និង ក្លារ៉ា យៀន កញ្ញា
ចូលជា Postulances និង
តេរេសា ខុន គឹមឈាន់ ជា aspirance ក្នុងក្រុម
ដូនជីស្រឡាញ់ឈើឆ្កាងព្រះយេស៊ូ
នាថ្ងៃទី១ មករា ២០២០ នៅកំពង់ចាមក្រុង។

## សូមបងប្អូនជួយអធិដ្ឋាន
## សម្រាប់ពួកគាត់!